ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 14-Jun-2012, 13:37
CMS/CFO: Sann Rada

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង</u>

## <u>សាធារណៈ</u>

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២**

**ម៉ោង ០៩:០០ នាទី**

**សវនាការលើកទី៧៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍

*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា

*(Mr.Matteo CRIPPA)*

កញ្ញា ណាតាចា វីសែល រីសឺ

*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក ថារីក អាប់ឌុលឡាក់

*(Mr. Tarik ABDULHAK)*

លោក កែត រេយ៍ន័រ *(Mr. Keith RAYNOR)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វ៉ែកកែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក សំ សុគង់

លោក គីម ម៉េងឃី

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក អាប់ឌុលឡាក់ ថារីក | អង់គ្លេស |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អាកឌូរ វែកគែន | បារាំង |
| លោក គីម ម៉េងឃី | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោក សេង រិទ្ធី (មេធាវីប្រឹក្សាសាក្សី) | ខ្មែរ |
| លោក អឿន តាន (TCW-488) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក អឿន តាន** (TCW-488)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖........ ទំព័រ ៥
សួរដោយលោក វ៉េង ហ៊ាត់ ផ្ដើមពី៖........ ទំព័រ ១០
សួរដោយលោក អាប់ឌុលឡាក់ ថារីក ផ្ដើមពី៖........ ទំព័រ ៣១
សួរដោយលោក គឹម ម៉េងឃីផ្ដើមពី៖........ ទំព័រ ៦៩
សួរដោយលោក ពេជ អង្គ ផ្ដើមពី៖........ ទំព័រ ៨០
សួរដោយលោក ហ្សង់ម៉ាក ឡាវ៉ែន៍ ផ្ដើមពី៖........ ទំព័រ ៨៦
សួរបន្តដោយប្រធានអង្គជំនុំ ផ្ដើមពី៖........ ទំព័រ ៨៨

# **កិច្ចដំណើរការនីតិវិធី**

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៤៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានកំណត់ និងបានជម្រាបជូនភាគី និងសាធារណជនរួចហើយកាលពីម្សិលមិញ គឺនៅថ្ងៃនេះអង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-488។

ហើយមុននឹងកោះអញ្ជើញសាក្សីចូលមកកាន់បន្ទប់សវនាការ ក្រឡាបញ្ជីសវនាការឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះបានកោះហៅឱ្យមកចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះសម្រាប់រយៈពេលពេញមួយថ្ងៃ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

[០៩:០២:២០]

សាក្សីដែលអង្គជំនុំជម្រះបានកោះហៅមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម TCW-488 មានវត្តមាននៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយកាលពីថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១២។ កត់សម្គាល់ផងដែរអំពីវត្តមានរបស់មេធាវីប្រឹក្សារបស់សាក្សីដែលមានឈ្មោះថាលោកមេធាវី សេង រិទ្ធី។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្តីរបស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយ

ផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលកិច្ចដំណើរការសវនាការពេញមួយថ្ងៃនេះ។ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាមដានស្តាប់នូវកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។

[០៩:០៣:២៣]

ហើយទន្ទឹមនឹងដែរក៏មានអនុសាសន៍របស់វេជ្ជបណ្ឌិតមកពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដែលទទួលបន្ទុកពិនិត្យថែទាំព្យាបាលសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំង អ.វ.ត.ក បានផ្តល់យោបល់ថា ដោយបញ្ហាសាក្សី-- ដោយជនជាប់ចោទរូបនេះមានបញ្ហាសុខភាពមិន-- ពិបាកឡើងជណ្តើរ និងពុំអាចផ្តល់លទ្ធភាពឲ្យអង្គុយនៅក្នុងបន្ទប់សវនាការនេះយូរបាន ដែលគប្បីអនុញ្ញាតឲ្យគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការដោយផ្ទាល់ ដែលគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បាន។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលនៃដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៤:៥៣]

មន្ត្រីរដ្ឋបាលតុលាការតុលាការកោះអញ្ជើញសាក្សី 488 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

កុំអាល១ទាន់! មន្ត្រីតុលាការកុំអាលទាន់ អញ្ជើញគាត់មក!

សូមអញ្ជើញលោកមេធាវី ម៉ៃខល កាណាវាស មុន ព្រោះគាត់ដើបមុនបាទ។

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម អស់លោក លោកស្រី នៅក្នុងបន្ទប់សវនាការ និងក្រៅបន្ទប់សវនាការ។

[០៩:០៥:២៨]

ខ្ញុំមានសំណើសូមបញ្ជាក់មួយទៅលើសេចក្ដីសម្រេចកាលពីម្សិលមិញ ប្រហែលជាពីរនាទីទេ ខ្ញុំសូមលើកឡើង សូមឲ្យបញ្ជាក់។ គឺសូមឲ្យបំភ្លឺទៅលើសេចក្ដីសម្រេចដែលបានធ្វើឡើងលើការជំទាស់របស់សហព្រះរាជអាជ្ញា នៅពេលដែលមេធាវី នួន ជា ព្យាយាមផ្ទៀងផ្ទាត់សាក្សីនៅមុនពេលផ្ដល់សក្ខីកម្ម ដែលនៅពេលនោះអង្គជំនុំជម្រះបានសម្រេចថា វា-- សំណួរនោះវាជាន់គ្នា។ ដូច្នេះហើយការជំទាស់របស់មេធាវី-- ការជំទាស់នោះទើបបានមានសុពលភាព។

ខ្ញុំយល់ឃើញថា អង្គជំនុំជម្រះឲ្យសហព្រះរាជអាជ្ញាធ្វើការដឹកនាំការតាំងសំណួរ។ ចំពោះករណីនេះ គឺជាមិនបញ្ហាអ្វីនោះទេ។ យើងខ្ញុំជឿថា យើងខ្ញុំក៏មានសិទ្ធិក្នុងការសួរសំណួរនាំមុខដែរ ក៏ប៉ុន្តែសួរសំណួរត្រូវជំទាស់ គឺខ្ញុំក៏មិនគិតថាជាបញ្ហាសម្រាប់យើងខ្ញុំដែរ។ ចំពោះការផ្ទៀងផ្ទាត់ និងការតទល់ទៅលើសាក្សី ដោយផ្អែកទៅលើសំណួរដែលជាន់គ្នានោះ គឺថាយើងខ្ញុំសូមបញ្ជាក់ទៅលើចំណុចហ្នឹង។ ប្រហែលជា ខ្ញុំសូមបញ្ជាក់ទៅលើចំណុចហ្នឹងក្នុងនាមជាភាគី។

[០៩:០៦:៥៦]

ខ្ញុំសូមឲ្យអង្គជំនុំជម្រះធ្វើការប្រឹក្សា ឬក៏ផ្ដល់ការណែនាំដល់យើងខ្ញុំ ដើម្បីឲ្យយើងខ្ញុំបានដឹងថាតើយើងខ្ញុំអាចយកសក្ខីកម្ម ដែលលើកឡើងដោយភាគីម្ខាងនោះ យកមកសួរបញ្ជាក់ដោយរបៀបណានៅពេលដែលយើងខ្ញុំចង់សួរផ្ទៀងផ្ទាត់? យើងខ្ញុំសូមរក្សាសិទ្ធិក្នុងការប្រើប្រាស់សក្ខីកម្ម ដែលយើងបានទាញយកចេញពីសាក្សី។ ហើយដោយសារតែពេលខ្លះទៅ យើងឃើញថាយើងខ្ញុំចង់យកមកសួរផ្ទៀងផ្ទាត់ ហើយពិនិត្យមើលទៅលើសក្ខីកម្មនោះឡើងវិញ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ អរុណសួស្ដីអស់លោក លោកស្រីទាំងអស់គ្នា។ ខ្ញុំសូមគាំទ្រសេចក្ដីសន្និដ្ឋានលើកឡើងដោយលោកមេធាវី អៀង សារី។ ខ្ញុំជឿថាកាលពីម្សិលមិញរសៀល នៅពេល

មួយនោះ គឺយើងខ្ញុំត្រូវបានទទួលការអនុញ្ញាតប្រើប្រាស់សក្ខីកម្ម សាក្សីដែលបានផ្តល់ក្នុងអាទិត្យនេះ និងអាទិត្យមុន។ ក៏ប៉ុន្តែគឺខ្ញុំសូមឲ្យមានការបញ្ជាក់បំភ្លឺ។ ខ្ញុំសូមលើកឡើង*អ៊ីម៉ែល* ដែលខ្ញុំបានបញ្ជូននៅថ្ងៃទី២៤ ខែមេសា ទៅដល់មន្ត្រីច្បាប់ ដែលពាក់ព័ន្ធទៅនឹងការបោះពុម្ពផ្សាយនិងការផ្សព្វផ្សាយ។ ដូច្នេះ ខ្ញុំមិនទាន់បានទទួលបានការឆ្លើយតបទៅលើឯកសារ*អ៊ីម៉ែល*នោះទេ--

**ប្រធានអង្គជំនុំ៖**

យើងមិនអនុញ្ញាតឲ្យលោកលើកបញ្ហាអ្វីផ្សេង ក្រៅពីបញ្ហាដែលត្រូវពិភាក្សាដេញដោលនេះទេ។ អ៊ីចឹងហើយបានជាយើងប្រាប់អ្នកឯងថា ឲ្យប្រាប់អំពីរបៀបវារៈ និងកម្មវត្ថុនៃការនិយាយ។ ថ្ងៃនេះយើងតាំង-- កំណត់កាលបរិច្ឆេទសវនាការសួរដេញដោលសាក្សី TCW-488។

[០៩:០៩:០២]

ប្រសិនបើមានបញ្ហាត្រឹមតែមានបញ្ហាកត់សម្គាល់នូវការសម្រេចសេចក្តីរបស់-- នៃការសម្រេចរបស់អង្គជំនុំជម្រះ នោះយើងនឹងធ្វើការកត់សម្គាល់ដើម្បីយកទៅពិចារណា រៀបចំនូវសេចក្តីណែនាំអនុវត្តឲ្យបានត្រឹមត្រូវ។ បញ្ហាផ្សេងទៀតលោកត្រូវធ្វើលាយលក្ខណ៍អក្សរ ទាំងសេចក្តីសន្និដ្ឋាន ទាំងសំណើសុំផ្សេងៗ។ បញ្ហាមិនពាក់ព័ន្ធនឹងកិច្ចដំណើរការនីតិវិធីដេញដោលទេ នៅចំពោះកម្មវត្ថុសំខាន់នៃការកំណត់កាលបរិច្ឆេទសម្រាប់ដេញដោលសាក្សីថ្ងៃនេះទេ យើងមិនអនុញ្ញាតឲ្យលោកនិយាយទេ។

[០៩:០៩:៥៤]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ចំណុចនេះច្បាស់ហើយ ក៏ប៉ុន្តែជាសំណើដែលថានៅពេលណាដែលយើងខ្ញុំអាចទទួលចម្លើយដែលយើងខ្ញុំបានដាក់-- ទៅនឹងសំណើដែលយើងខ្ញុំបានដាក់នៅថ្ងៃទី២៤ ខែមេសា។ ខ្ញុំមិនទាន់បានទទួលចម្លើយនោះទេ។ ចំណុចនេះ គឺខ្ញុំសូមគ្រាន់តែបញ្ជាក់បំភ្លឺទេ នៅពេលណាដែលយើងខ្ញុំបានទទួលចម្លើយតបទៅនឹងសំណើរបស់យើងខ្ញុំនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះនឹងពិនិត្យបញ្ហានេះ ហើយនឹងចេញសេចក្តីសម្រេចឆ្លើយតបឆាប់ៗក្នុងពេលវេលាសមស្រប។

មន្ត្រីរដ្ឋបាលតុលាការ កោះអញ្ជើញសាក្សី TCW-488 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[០៩:១២:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:១២:៤៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ លោក កាណាវាស អង្គជំនុំជម្រះមិនយល់ច្បាស់ទៅលើបញ្ហាជាក់លាក់ណាមួយដែលលោកបានលើកឡើង។ យើងមិនចង់ចំណាយពេលនៅពេលនេះទេ ក៏ប៉ុន្តែសូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់លាស់នៅក្នុងអនុស្សរណៈបញ្ជូនទៅមន្ត្រីច្បាប់ ដើម្បីឲ្យយើងអាចដោះស្រាយបាន។ តើអាចទទួលយកបានដែរឬទេលោក?

**លោក ម៉ៃខល កាណាវាស៖**

បាទ គឺខ្ញុំអាចធ្វើបាន ប្រតិចារឹកជាភាសាអង់គ្លេស គឺវាមាន ដូច្នេះហើយ គឺខ្ញុំអាចធ្វើការពិនិត្យមើលចំណុចហ្នឹង ហើយបញ្ជូនទៅលោកស្រី។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អ៊ីចឹងយើងខ្ញុំចង់ឲ្យលោកសរសេរក្នុងអនុស្សរណៈ ហើយបញ្ជូនមកយើងខ្ញុំ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកស្រី យើងខ្ញុំអាចធ្វើទៅបាន។

[០៩:១៣:៥៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

អរុណសួស្តីសាក្សី។

**ស៖** តើលោកឈ្មោះ អឿន តាន អ៊ីចឹងពិតមែនដែរទេ?

**លោក អឿន តាន៖**

**ឆ៖** ពិតមែនហើយ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីជួយលើកអាក្បាលមេក្រូឡើងលើបន្តិចបាទ អរគុណ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក អឿន តាន តើក្រៅពីឈ្មោះ អឿន តាន ហ្នឹង តើលោកដែលធ្លាប់ប្រើឈ្មោះអ្វីផ្សេងទៀតដែរឬទេ?

**លោក អឿន តាន៖**

**ឆ៖** អ្ហឺ! អត់មានទេ។

**ស៖** លោកមានដែលប្រើឈ្មោះ ជូ តាន ដែរឬទេ?

**ឆ៖** បច្ចុប្បន្នប្រើ។

**ស៖** បច្ចុប្បន្ននេះ លោកប្រើជាផ្លូវការនៅក្នុងមូលដ្ឋានរបស់លោកហ្នឹង លោកប្រើឈ្មោះអីទៅឈ្មោះ អឿន តាន ឬក៏ឈ្មោះ ជូ តាន?

**ឆ៖** អឿន តាន។

**ស៖** អរគុណ។ តើលោកមានអាយុប៉ុន្មានឆ្នាំហើយ។

[០៩:១៥:០០]

**ឆ៖** ខ្ញុំអាយុ នែ៎-- កើតឆ្នាំ១៩៤៣។

**ស៖** បាទ អរគុណ។ តើលោកមានទីលំនៅសព្វថ្ងៃនេះនៅទីកន្លែងណាដែរ?

**ឆ៖** បច្ចុប្បន្ន ខ្ញុំនៅភូមិដូនត្រឹក ឃុំដូនត្រឹក ស្រុកសំឡូត ឃុំតាសាញ។

**ស៖** បាទ អរគុណ។ តើលោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ?

**ឆ៖** បច្ចុប្បន្ន ខ្ញុំធ្វើរបររកស៊ីធ្វើចម្ការ។

**ស៖** បាទ អរគុណ។ តើឪពុកបង្កើតលោកឈ្មោះអី?

**ឆ៖** ឪពុកបង្កើតរបស់ខ្ញុំឈ្មោះ លួម។

[០៩:១៦:០០]

**ស៖** ត្រកូលអីទៅ?

**ឆ៖** អត់ចាំ។

**ស៖** ចុះម្ដាយបង្កើតរបស់លោកឈ្មោះអីដែរ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ស៖** ម្ដាយបង្កើតលោកឈ្មោះអី? ឈប់! លោកកុំអាលទាន់ឆ្លើយ រង់ចាំមើលភ្លើងសញ្ញាក្រហមសិន ដែលជាសញ្ញាថាឧបករណ៍នៅចំពោះមុខរបស់លោកហ្នឹងវានឹងប្រតិបត្តិការ។ តើម្ដាយរបស់លោកឈ្មោះអី?

**ឆ៖** ឈ្មោះ ប្លឹម។

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** មានកូនបីនាក់។

**ស៖** លោកមានជនជាតិ ជាជនជាតិអីដែរ លោក?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

[០៩:១៦:៥៤]

**ស៖** ម្ដងទៀត លោករង់ចាំភ្លើងក្រហម ដែលជាសញ្ញាថា ដល់ពេលដែលលោកត្រូវនិយាយ បើមិនទាន់មានភ្លើងទេ លោកនិយាយទៅអត់ៗស្ដាប់បានទេណា ព្រោះនេះយើងប្រើឧបករណ៍ស្ដាប់សំឡេងទាំងអស់គ្នាណា។

លោកមានជន-- ជាជនជាតិអីដែរ?

**ឆ៖** បាទ ខ្ញុំជនជាតិកាចក់។

**ស៖** លោក អឿន តាន តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីម្សិលមិញ គឺបានបង្ហាញរាយការណ៍ដល់អង្គជំនុំជម្រះថា តាមសមត្ថភាពដែលលោកអាចដឹង គឺលោកមិនមានចំណងទាក់ទងញាតិលោហិត ឬក៏ញាតិពន្ធជាមួយភាគីនៃរឿងក្ដីនេះទេ គឺជាមួយដើមបណ្ដឹងរដ្ឋប្បវេណី និងជាមួយជនជាប់ចោទទាំងបីនាក់ គឺមាន នួន ជា, អៀង សារី, ខៀវ សំផន។ តើពិតមែនដែរឬទេ?

**ឆ៖** ពិតមែន។

**ស៖** អរគុណ។ ហើយតាមរបាយការណ៍ដដែល គឺក្រឡាបញ្ជីបានរាយការណ៍ថា លោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយកាលពីម្សិលមិញ។ តើពិតមែនដែរឬទេ?

[០៩:១៨:១៤]

**ឆ៖** ពិតមែន។

**ស៖** លោក អឿន តាន អង្គជំនុំជម្រះសូមជម្រាបអំពីសិទ្ធិ និងករណីកិច្ចរបស់លោក។ សិទ្ធិក្នុង

នាមជាសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏ការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

អំពីករណីកិច្ច លោក អឿន តាន ក្នុងនាមលោកជាសាក្សី ត្រូវផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះតាំងសំណួរសួរចំពោះលោក លើកលែងតែក្នុងករណីឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។

[០៩:១៩:១៧]

លោកជាសាក្សីត្រូវឆ្លើយតែការណ៍ណាដែលពិត ដែលលោកបានឃើញ បានដឹង បានឮ បានចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬការធ្វើការអង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរដែលសួរ។

តើលោកយល់ដែរឬទេ អំពីសិទ្ធិ និងករណីយកិច្ចនេះ?

**ឆ៖** បាទ យល់។

**ស៖** លោក អឿន តាន តើលោកចេះអក្សរខ្មែរដែរឬទេ?

**ឆ៖** មិនសូវចេះទេ។

**ស៖** លោកបានរៀនសូត្រកម្រិតណាដែរ កន្លងមក?

[០៩:២០:០៨]

**ឆ៖** រៀនត្រឹមចេះអាន ចេះសរសេរខ្លះៗ។

**ស៖** បាទ អរគុណ។ លោក អឿន តាន ទាក់ទងនឹងកិច្ចសម្ភាសដែលលោកបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេត នៃការិយាល័យស៊ើបអង្កេតកន្លងមក តើលោកដែលធ្លាប់បានផ្តល់កិច្ចសម្ភាសជាមួយអ្នកស៊ើបអង្កេត នៃការិយាល័យស៊ើបអង្កេតដែរឬទេ?

**ឆ៖** បាទ ដែល។

**ស៖** លោកធ្លាប់ធ្វើបទសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត នៃការិយាល័យស៊ើបអង្កេតហ្នឹងប៉ុន្មានលើកដែរ?

**ឆ៖** ទើបៗមួយលើកៗ។

**ស៖** ហើយការធ្វើសម្ភាសន៍នុ៎ង គឺធ្វើសម្ភាសន៍នៅទីកន្លែងណាដែរ?

**ឆ៖** សម្ភាសនៅភូមិដូនត្រិត។

[០៩:២១:១១]

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោក អឿន តាន បានពិនិត្យមើល បានអាន ឬក៏បានស្ដាប់នូវការអានកំណត់ហេតុស្ដាប់សក្ខីកម្មរបស់លោក ដែលបានធ្វើជាមួយនឹងអ្នកស៊ើបអង្កេតកន្លងទៅ ដើម្បីជាការរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំបានអាន ចាំខ្លះ អត់ខ្លះ ព្រោះយូរ ភ្លេច។

**ស៖** បាទ អរគុណ។ ហើយបើតាមសមត្ថភាពដែលលោកអាចដឹង តើលោកអាចបញ្ជាក់បាន ដែរទេថា កំណត់ហេតុស្ដាប់ចម្លើយដែលលោកបានអាន ឬបានស្ដាប់ការអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នាទៅនឹងចម្លើយ ដែលលោកបានឆ្លើយចំពោះអ្នកស៊ើបអង្កេត ដែលធ្វើ ជាមួយលោកកន្លងទៅដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ អរគុណ។

**ប្រធានអង្គជំនុំ៖**

ហើយជាបន្តនេះ អង្គជំនុំជម្រះសូមជម្រាបជូនទៅតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ច ដំណើរការនីតិវិធីពិភាក្សាដេញដោលក្នុងការស្ដាប់សាក្សីរូបនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅតំណាង សហព្រះរាជអាជ្ញា តាំងសំណួរដេញដោលចំពោះសាក្សីនេះមុនភាគីឯទៀតនៃរឿងក្ដី។

សូមអញ្ជើញ!

**លោក វ៉េង ហ៊ត់៖**

សូមគោរពលោកប្រធាន សូមគោរពក្រុមប្រឹក្សាចៅក្រមទាំងអស់ សូមគោរពភាគីទាំងអស់ និង សូមគោរពប្អូនប្រុស ប្អូនស្រី លោក លោកស្រី ដែលបានអញ្ជើញចូលរួមនៅក្នុងអង្គសវនាការនេះ។

សួស្ដីលោក អឿន តាន។ ខ្ញុំឈ្មោះ វ៉េង ហ៊ត់ មកពីការិយាល័យសហព្រះរាជអាជ្ញា។ តើលោក ឮខ្ញុំនិយាយទេ លោក អឿន តាន?

**លោក អឿន តាន៖**

បាទញ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វេង ហ៊ត់៖**

**ស៖** អរគុណលោក។ ឥឡូវនេះខ្ញុំចាប់ផ្តើមសួរសំណួរទៅលោក ទាក់ទងជាមួយនឹងរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន។ ក៏ប៉ុន្តែដើម្បីសម្រួលពាក្យសម្តីនោះ ខ្ញុំសួរពាក្យសម្រាយជូនលោក ដើម្បីងាយស្រួលស្តាប់។ សំណួរទីមួយរបស់ខ្ញុំ ខ្ញុំសួរថា តើលោកបានដឹងពីចលនាបដិវត្តន៍នៅក្នុងតំបន់របស់លោកក្នុងអំឡុងឆ្នាំណាដែរ?

**ឆ៖** ឆ្នាំ១៩៦៨។

**ស៖** លោកចូលបដិវត្តន៍ដំបូងនៅទីកន្លែងណា? ហើយលោកកាលនោះលោកមានអាយុប៉ុន្មានដែរ?

[០៩:២៤:៥៣]

**ឆ៖** ខ្ញុំចូលបដិវត្តន៍ថ្ងៃ០២ ខែ៣ ឆ្នាំ១៩៦៨។

**ស៖** ខ្ញុំសួរលោកថា នៅទីកន្លែងណាដែលលោកចូលមុនដំបូងហ្នឹង?

**ឆ៖** ចូលភូមិណាយ ឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរី។

**ស៖** ការចូលបដិវត្តន៍ដំបូងនោះ គេមានប្រាប់លោកថា តើចូលនៅក្នុងគោលបំណងអ្វីទេ?

**ឆ៖** ចូលបដិវត្តន៍ដំបូងគឺ ឃើញគេចូលច្រើន ដល់អ៊ីចឹងក៏ចូលចិត្តចង់ចូលហ្នឹងគេដែរ។

**ស៖** គេមានប្រាប់លោកថា ចូលបដិវត្តន៍នេះដើម្បីធ្វើអ្វីទេ?

**ឆ៖** អត់អ្នកណាប្រាប់ទេ។

[០៩:២៦:៣១]

**ស៖** ខ្ញុំសួរលោកបញ្ជាក់ម្តងទៀត ពេលនោះគេមានរៀបចំមេដឹកនាំ ឬក៏អ្នកដែលរៀបចំឲ្យលោកចូលហ្នឹង មានមេ មានអីប្រាប់ ហើយគាត់ហ្នឹងឈ្មោះអីដែរ?

**ឆ៖** មានឈ្មោះ កង ដែង គណៈស្រុក បានប្រាប់ខ្ញុំចូលបដិវត្តន៍។

**ស៖** ខ្ញុំសូមសួរលោកមួយសាទៀត ឈ្មោះ ដែង គណៈស្រុកតើអ៊ីចឹងមែនទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយចាំៗ រង់ចាំឧបករណ៍ធ្វើប្រតិបត្តិការសិនចាំឆ្លើយណ៎ា!

**សួរដោយលោក វេង ហ៊ត់៖**

**ស៖** ខ្ញុំសូមសួរលោកមួយសាទៀត ពេលនោះគឺមានរចនាសម្ព័ន្ធគណៈស្រុកហ្នឹង គេបានមកប្រមូល ឬមួយក៏យ៉ាងម៉េចអញ្ជើញលោកចូលរួមនៅក្នុងចលនាបដិវត្តន៍ហ្នឹង?

**លោក អឿន តាន៖**

**ឆ៖** បាទ គណៈស្រុក កង ដែង ប្រមូលឱ្យមកចូលបដិវត្តន៍។

**ស៖** នៅពេលចូលដំបូង គេមានពិនិត្យប្រវត្តិរូបលោកទេ?

**ឆ៖** បាទ គេពិនិត្យដែរ។

[០៩:២៨:៤២]

**ស៖** របៀបនៃការជ្រើសរើស តើគេជ្រើសរើសយកវណ្ណៈល្អ ឬក៏វណ្ណៈបែបម៉េចដែរ? លោកជួយពន្យល់ផង។

**ឆ៖** បាទ គេអត់រើសទេ គេឱ្យតែយើងស្ម័គ្រចិត្ត គឺចូលហើយ។

**ស៖** នៅពេលដែលលោកចូល តើនៅពេលនោះអង្គភាពរបស់លោកនោះ គេមានបែងចែកថាប្រធានឈ្មោះអី? អនុប្រធានឈ្មោះអ្វី? ហើយលោកចូលដំបូងហ្នឹងស្ថិតនៅក្នុងអង្គភាពអីដែរ?

**ឆ៖** បាទ នែ៎ខ្ញុំពេលនោះៗ-- ខ្ញុំមិនទាន់ច្បាស់ទេ សូមបញ្ជាក់ម្តងទៀត។

**ស៖** អរគុណលោក តាន។ ខ្ញុំបញ្ជាក់ជូនលោកមួយសាទៀត។ នៅពេលដែលលោកចូលដំបូងនោះ ប្រធានរបស់លោកហ្នឹងឈ្មោះអ្វី? ហើយប្រសិនបើលោកអាចស្គាល់អនុប្រធានទៀត គឺលោកប្រាប់ឈ្មោះគាត់មក ហើយបន្ទាប់មក អង្គភាពហ្នឹង គេហៅឈ្មោះថាម៉េច?

**ឆ៖** ពេលនោះ គឺ ផៃ អ្នកដឹកនាំចូលកន្លែងនីរសារ។

**ស៖** អរគុណលោក។ ក្នុងនាមលោក គេហៅថា "អង្គភាពនីរសារ"។ អ៊ីចឹង លោកចូលក្នុងនីរសារ កាលណាយើងចូលជាក្រុមហើយ តើគេមានធ្វើកិច្ចប្រជុំស្តីពីទិតៀននិងស្វ័យទិតៀន ឬទេ?

**ឆ៖** ក្រៅ-- ពីក្រោយធ្វើការងាររងមក គឺមានការប្រជុំ ដើម្បីណែនាំពីរត់នីរសារ ទៅណាដល់ណា ប៉ុណ្ណឹង។

[០៩:៣១:២៥]

**សៈ** នីរសារនេះ គេឲ្យរត់សំបុត្រ ឬក៏រត់សារទូរលេខ ឬក៏គេបង្រៀនពីរបៀបតាមដានមនុស្ស ដែរទេ នៅក្នុងអង្គប្រជុំហ្នឹង?

**ផៈ** បាទ គឺរត់សំបុត្រ។

**សៈ** ចុះរត់សារទូរលេខ លោកដែលស្គាល់ទេ?

**ផៈ** ទូរលេខ ដែលឮគេថា។

**សៈ** ខ្ញុំសួរលោកបញ្ជាក់មួយសាទៀត នៅក្នុងរបៀបនៃការបង្រៀនទាក់ទងនឹងរបៀបរត់សំបុត្រ ក្រៅពីនេះ គេមានបង្រៀន ថានីរសារមានសារៈសំខាន់នៅក្នុងការតាមដានបុគ្គលមួយចំនួននៅក្នុងបក្ស ដែរទេ?

**ផៈ** អត់មានទេ គ្រាន់តែថា រត់សំបុត្រឲ្យទៅ "ក" ទៅ ពី "ក" ទៅ "ខ" ទៅ តែប៉ុណ្ណឹងទេ។

**សៈ** ឥឡូវនេះ ខ្ញុំចូលពីអង្គភាពរដ្ឋបាល។ ខ្ញុំសួរលោកទាក់ទងអង្គភាពរដ្ឋបាលវិញម្តងទៀត។ តើលោកដឹងថា អំឡុងពេលមុនឆ្នាំ៧៥ នៅតាមតំបន់រំដោះ តើមានការបែងចែកសហករណ៍ឃុំ ស្រុក មន្ទីរសន្តិសុខ ភូមិភាគហើយឬនៅលោក?

[០៩:៣៣:៤១]

**ផៈ** បាទ ពេលនោះ ខ្ញុំគ្រាន់តែឮគេថា បែងចែកសហករណ៍ បែងចែកភូមិភាគ បែងចែកតំបន់ តែប៉ុណ្ណឹងទេ គ្រាន់តែឮ។

**សៈ** អរគុណលោក តាន។ ខ្ញុំសួរលោកមួយទៀត អង្គការមានបង្រៀនអំពីសារៈសំខាន់នៃការ បង្កើតរចនាសម្ព័ន្ធរដ្ឋបាលបែបនេះ ដើម្បីងាយស្រួលក្នុងការបញ្ជូនសំបុត្រ ឬក៏បញ្ជាពីថ្នាក់លើមក ក្រោមឲ្យចំទិសដៅដែរទេ?

**ផៈ** បាទ ខ្ញុំអត់ដឹងទេបញ្ហាហ្នឹង ព្រោះ ក្រុមខ្ញុំគឺថា មានសំបុត្រ ឲ្យរត់សំបុត្រ តែប៉ុណ្ណឹងទេ អត់ដែលដឹងថាណែនាំពីអីៗទេ អត់ទេ។

[០៩:៣៤:០១]

**សៈ** អរគុណលោក។ តើលោកទទួលខុសត្រូវភារកិច្ចអ្វីដែរ នៅក្នុងអំឡុងពេលឆ្នាំ១៩៦៥ ដល់ ៧០ ហ្នឹង?

**ផៈ** បាទ ពេលឆ្នាំ១៩៧០ ខ្ញុំទទួលផ្នែករត់សំបុត្រជាបន្តបន្ទាប់ដែរ។

**សៈ** ក្រៅពីរត់សំបុត្រ តើនីរសារនេះមានទំនាក់ទំនងអ្វីខ្លះដែរទេ?

**ឆ៖** បាទ អត់មានទេ។

**ស៖** ខ្ញុំចង់ដឹងពាក្យមួយទៀត "នីរសារ" នេះគេមានបង្រៀនលោកថា "នីរសារ" នេះគឺជា-- គឺមានន័យយ៉ាងម៉េចដែរ "នីរសារ" ហ្នឹង?

**ឆ៖** បាទ មានន័យ "នីរសារ" នោះ គឺយកសំបុត្រ ដូចថាខ្ញុំបញ្ជូនទៅឲ្យ "ក" អ៊ីចឹងទៅ "ក" ជូនទៅ "ខ" អ៊ីចឹងទៅ តែប៉ុណ្ណឹងទេ។

**ស៖** តើគេ លោកមានដែលគេប្រាប់ថាបញ្ជូនទៅមន្ទីរ ឬក៏អង្គភាពនេះក្រៅពីឈ្មោះ "ក", "ខ" ហ្នឹង ដូចថាបញ្ជូនទៅតំបន់នេះ បញ្ជូនសំបុត្រទៅមន្ទីរសន្តិសុខនេះ បញ្ជូនសំបុត្រទៅភូមិភាគនេះ ភូមិភាគនោះ។ តើមានគេណែនាំលោកអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ មិនដែលមានទេ។

**ស៖** នៅក្នុងខ្លឹមសារសំបុត្រនីមួយៗ ដែលលោកបានបញ្ជូនដូចលោកបាននិយាយអម្បាញ់មិញ ថាបញ្ជូនទៅ "ក" បញ្ជូនទៅ "ខ" តើនៅក្នុងសេចក្តីរាយការណ៍នៃសំបុត្រនោះ លោកបានពិនិត្យមើលទេ? ហើយលោកបានដឹងថា សំបុត្រនោះគេបញ្ជូនស្តីពីការចាប់ខ្លួនមនុស្ស ឬក៏យកមនុស្សទៅរៀនសូត្រ លោកបានដឹងទេ ពេលហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ គ្រាន់តែកាន់សំបុត្រ។ ពេលនោះ ខ្ញុំអត់ចេះអក្សរផង ដូច្នេះអត់ចេះមើល គ្រាន់តែកាន់សំបុត្រជូនទៅកន្លែង "ក" អ៊ីចឹងទៅ ខ្ញុំបកមកវិញមក។ អត់ដែលដឹងទេ។

**ស៖** បាទ ឥឡូវនៅក្នុងចន្លោះពេលដែលលោកធ្វើជានីរសារ ខ្ញុំសួរទាក់ទងជាមួយនឹងមេដឹកនាំ ខ្ញុំសូមសួរលោកនៅឆ្នាំ១៩៧០ តើលោកនៅតែជានីរសារ ឬលោកធ្វើការអ្វីផ្សេងពីនីរសារ?

**ឆ៖** បាទ ពេលនៅឆ្នាំ៧០ ខ្ញុំធ្វើជានីរសាររហូត រត់សំបុត្ររហូត។

[០៩:៣៨:៥៨]

**ស៖** បន្ទាប់ពីឆ្នាំ៧០ មក លោកធ្វើអីដែរ?

**ឆ៖** បន្ទាប់ពីឆ្នាំ៧០ ខ្ញុំធ្វើជានីរសាររហូតដែរ។

**ស៖** លោកដែលធ្លាប់ធ្វើជាកងការពារទេ?

**ឆ៖** បាទ នីរសារហ្នឹងគេភ្ជាប់នឹងកងការពារ។

**ស៖** អរគុណលោក។ លោកស្គាល់សម្ងាត់របស់ អ៊ំប៉ុល ទេ? ឈ្មោះសម្ងាត់ ប៉ុល លោកស្គាល់ទេ?

ឆ៖ បាទ អត់ដែលដឹងទេអង្កាល់នុ៎ង។

ស៖ ចុះដែលឮឈ្មោះ អ៊ំនួន ទេ?

ឆ៖ បាទ ស្គាល់។

ស៖ ឈ្មោះពេញរបស់គាត់ឈ្មោះអីដែរ លោកដឹងទេ?

ឆ៖ នួនៗ នួន ជា។

ស៖ បាទ អរគុណ។ លោកស្គាល់ឈ្មោះសម្ងាត់ អ៊ំវ៉ាន់ ទេ?

[០៩:៤០:៤៤]

ឆ៖ បាទ អ៊ំវ៉ាន់ លោក អៀង សារី។

ស៖ បាទ អរគុណ។ លោកស្គាល់ឈ្មោះ ហែម ទេ នៅក្នុងសម័យមុនឆ្នាំ៧៥ ហ្នឹង?

ឆ៖ បាទ ខ្ញុំស្គាល់ឈ្មោះ ហែម ហៅ ខៀវ សំផន។

ស៖ បាទ អរគុណលោក។ ឥឡូវនេះខ្ញុំសួរលោក លោកស្គាល់មេដឹកនាំ លោកស្គាល់ អ៊ំនួន ស្គាល់ អ៊ំវ៉ាន់ ស្គាល់ ហែម តើពេលនោះលោកដឹងថាគាត់ទាំងបីនាក់ហ្នឹងមានតួនាទីជាអ្វីដែរលោក?

ឆ៖ បាទ ខ្ញុំអត់ដឹងតួនាទីជាអីទេ។

ស៖ បាទ អរគុណ។ នៅពេលមេដឹកនាំទៅណា តើកងការពារដូចលោកអ៊ីចឹងទៅតាមមេដឹកនាំដែរឬទេ?

ឆ៖ ដូចខ្ញុំជាកងការពារ ពេលខ្លះក៏ចែកគ្នា ខ្ញុំម្តង គេម្តងអ៊ីចឹងទៅ តាមអ្នកដឹកនាំត្រូវការ តាមមូលដ្ឋានបាទ។

[០៩:៤២:២៥]

ស៖ បាទ លោកថាលោកជាកងការពារ គឺតាមមេដឹកនាំទៅដល់មូលដ្ឋាន។ តើមេដឹកនាំឈ្មោះអ្វីដែលៗលោកទៅតាមហ្នឹងបាទ?

ឆ៖ បាទ គឺឈ្មោះ ប៉ុល ពត។

ស៖ ប៉ុល ពត ហ្នឹងគាត់ចុះទៅមូលដ្ឋានហ្នឹង ទៅតាមភូមិភាគ ឬក៏ទៅតាមតំបន់ណាមួយលោក?

ឆ៖ គឺតាមតំបន់ តាមស្រុក តាមភូមិភាគ។

ស៖ បាទ កន្លែងនេះ ខ្ញុំចង់ឲ្យលោកនិយាយរឿងពន្យល់បន្តិច ថាតើគាត់ធ្លាប់ចុះទៅតំបន់ណា?

ភូមិភាគណា? សូមលោកជួយពន្យល់បន្តិចមក។

**ឆ៖** បាទ គឺចុះតាមតំបន់សៀមរាម តាមបាត់ដំបង តាមពោធិ៍សាត់ កំពង់ឆ្នាំង តែប៉ុណ្ណឹងទេ។

[០៩:៤៤:០៦]

**ស៖** ដោយសារលោកជាកងការពារ ដូច្នេះខ្ញុំសូមសួរលោកបន្តទៀត។ នៅពេលថ្នាក់ដឹកនាំប្រជុំ តើគេមានឲ្យកងការពារទៅការពារថ្នាក់ដឹកនាំហ្នឹងទេ?

**ឆ៖** បាទ ពេលដឹកនាំធ្វើការ គឺកងការពារគេឲ្យនៅឆ្ងាយពី២០ម៉ែត្រទៅ អត់ឲ្យនៅជិតទេ គេឲ្យនៅឆ្ងាយ២០ម៉ែត្រពីកន្លែងធ្វើការ។

**ស៖** តើលោកឃើញជាក់ស្តែងនោះ មេដឹកនាំទាំងនោះចូលរួមប្រជុំហ្នឹង គឺមានមេដឹកនាំឈ្មោះអីខ្លះ?

[០៩:៤៥:០០]

**ឆ៖** បាទ ខ្ញុំស្គាល់តិចណាស់ ខ្ញុំស្គាល់តែ អៀង សារី, នួន ជា, ខៀវ សំផន ហើយក្រៅពីហ្នឹងខ្ញុំអត់ស្គាល់។ មិនដឹងឈ្មោះអីៗ ខ្លះទេ។

**ស៖** នៅពេលដែលមេដឹកនាំប្រជុំ គឺមានឈ្មោះ អៀង សារី, ខៀវ សំផន, នួន ជា ហើយទីនោះលោកនិយាយអំមិញថា នៅប្រហែលជា២០ម៉ែត្រ។ ពេលដែលគេប្រជុំនោះ តើលោកដឹងថាគេប្រជុំពីអីដែរ គេនិយាយពីអ្វី លោកដឹងទេ?

**ឆ៖** បាទ អត់ដឹងទេ ព្រោះនៅឆ្ងាយ អត់ដឹងទេ។

[០៩:៤៦:១៨]

**ស៖** លោកដែលធ្លាប់ធ្វើកងការពាររបស់លោក អៀង សារី ទេ?

**ឆ៖** បាទ អត់ដែរទេ។

**ស៖** ឥឡូវនេះខ្ញុំសួរលោកបន្តទៀត ទាក់ទងនឹងជំនួយការនយោបាយ រដ្ឋបាល យោធា សន្តិសុខមុនឆ្នាំ១៩៧៥។ តើលោកស្គាល់ឈ្មោះ កែន ហៅ លីន ទេ?

**ឆ៖** បាទ ស្គាល់ កែន លីន។

**ស៖** លោកដឹងថា កែន ហៅ លីន ហ្នឹងគាត់មានតួនាទីអីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាហ្នឹង?

**ឆ៖** លីន គឺនែ៎ ប្រធាននីរសារនៅ ក-៧។

**ស៖** ចុះលោកស្គាល់ ប៉ង់ ទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** ប៉ង់ ហ្នឹងគាត់ទទួលខុសត្រូវលើអ្វីដែរ?

**ឆ៖** ប៉ង់ គឺទទួលខុសត្រូវរួមក្នុងមន្ទីរ៨៧០។

**ស៖** អរគុណលោក។

[០៩:៤៨:៤៦]

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញា គឺរៀបចំការតាំងសំណួរឲ្យបានច្បាស់លាស់លើកាលបរិច្ឆេទមុន៧៥ ឬក៏ក្រោយ៧៥ ដើម្បីឲ្យរំលេចអង្គហេតុដែលសាក្សីនឹងអាចឆ្លើយតបហ្នឹង គឺចំ ហើយនិងអាចមានតម្លៃនៅក្នុងការយកទៅពិនិត្យពិចារណា។ ព្រោះលោកអំមិញបាននិយាយច្បាស់ថាមុនឆ្នាំ១៩៧៥ទេ។ ប៉ុន្តែ អ្ហឺ! ព្រឹត្តិការណ៍ដែលកើតមានឡើង ដែលសាក្សីឆ្លើយតប ដូចជាមានការភ័ន្តច្រឡំអំពីកាលបរិច្ឆេទនេះ។

**លោក វ៉េង ហ៊ាត់៖**

អរគុណលោកប្រធាន ដែលបានជួយរំឭក។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** សាក្សី ខ្ញុំសូមសួរលោកម្តងទៀត។ ខ្ញុំសួរលោក មន្ទីរដែលលោកឆ្លើយថា ប៉ង់ ហ្នឹង គាត់ទទួលខុសត្រូវមន្ទីរ៨៧០។ តើមន្ទីរ៨៧០ហ្នឹងនៅមុនឆ្នាំ៧៥ហ្នឹង មានទីតាំងនៅត្រង់ណាដែរលោក?

**លោក អឿន តាន៖**

**ឆ៖** មុន៧៥ ទីតាំងនៅនែ៎ ភូមិត្រពាំងទឹម ខេត្តកំពង់ចាម។

[០៩:៥០:០៧]

**ស៖** អរគុណលោកសាក្សី លោក តាន។ ឥឡូវនេះ ខ្ញុំសួរលោកទាក់ទងជាមួយនឹងការងាររដ្ឋបាល និងភស្តុភារ ហើយគោលដៅនៃការសួររបស់ខ្ញុំ ៗផ្តោតទៅលើមុនឆ្នាំ១៩៧៥ ណ៎ាលោក បាទ។ តើលោកដឹងថា មន្ទីរដែលផ្តើមដោយព្យញ្ជនៈ ក ៗហ្នឹង។ តើគេធ្វើការងារអ្វីដែរ លោកដឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលដឹងទេ។

**ស៖** លោកបាននិយាយខាងដើមអំមិញនេះ គឺថាមុន៧៥នោះ គឺ លីន ហ្នឹងជានីរសារ ក-១ គេបានរៀបចំប្រព័ន្ធរចនាសម្ព័ន្ធហ្នឹងរួចហើយ។ អ៎ លីន ហ្នឹងជានីរសារប្រធាន ក-៧។ ឥឡូវនេះ ខ្ញុំចង់សួរ

ថាតើលោកស្គាល់ ក លើសពីប្រាំពីរ ឬក៏ ក យ៉ាងម៉េចដែរ? មាន ក-១, ក-២ ឬក៏យ៉ាងម៉េច សូមលោកជួយពន្យល់មើល៍?

[០៩:៥១:៣៤]

**ធ៖** បាទខ្ញុំដឹងតែ ក-១, ក-៧, ក-៣ តែប៉ុណ្ណឹងទេ ក្រៅពីហ្នឹង ខ្ញុំអត់ស្គាល់។

**ស៖** អម្បាញ់មិញនេះលោកបានប្រាប់អង្គសវនាការថា មន្ទីរ៨៧០ នេះគឺលោកបានដឹង។ តើ ៨៧០ នេះគេធ្វើការងារអីដែរ លោកដឹងទេ?

**ធ៖** មន្ទីរ៨៧០ ខ្ញុំអត់ដឹងគេធ្វើការងារអីទេ។

**ស៖** នៅមុនឆ្នាំ៧៥ តើលោកបានដឹងថា មន្ទីរសម្ងាត់មួយទៀត គឺមានលេខពីរខ្ទង់ គឺ ស-៧១។ លោកដែលឮទេពាក្យហ្នឹង?

**ធ៖** បាទ មិនដែលឮទេ។

**ស៖** បាទ អរគុណ។ តើលោកបានដឹងអំពីមន្ទីរ១០០ និងមន្ទីរ១០២ ទេ?

**ធ៖** បាទ អត់ដែលឮទេ។

**ស៖** លោកបានឮ ប-៥ ដែរទេ?

**ធ៖** បាទ ខ្ញុំមិនច្បាស់ទេ ខ្ញុំអត់ដែលឮ អត់ដែលដឹងទេ។

**ស៖** បាទ អរគុណលោក តាន។ ឥឡូវនេះ ខ្ញុំចូលទៅសំណួរមួយទៀត។ ដោយសារតែលោកធ្លាប់មានបទពិសោធន៍ជានីរសារផង ជាកងការពារផង ហើយលោកបានឆ្លើយអម្បាញ់មិញថា លោកនៅជិតអ៊ំៗ អ៊ំ នួន ជា, អ៊ំ អៀង សារី, អ៊ំ ខៀវ សំផន ហើយនិងឃើញគាត់ចូលប្រជុំ។ ហើយគាត់នៅចម្ងាយពីក្រុមមេដឹកនាំនេះតែចំនួនប្រហែល២០ម៉ែត្រទេ។ អ៊ីចឹងខ្ញុំអាចសួរលោកថា អ៊ំៗមាន ឬមួយក៏លោកឮពាក្យ “បដិវត្តន៍” ដែរទេ? ពាក្យ “បដិវត្តន៍” ហ្នឹងមានន័យយ៉ាងម៉េចដែរលោក?

[០៩:៥៤:៤៦]

**ធ៖** បាទ ខ្ញុំបាន គ្រាន់តែដឹង បដិវត្តន៍ហ្នឹងប្រែទៅជាម៉េចទេ ខ្ញុំអត់ដឹងដែរ។ ឃើញថាធ្វើបដិវត្តន៍ៗ ក៏ធ្វើតាមគេទៅ។

**ស៖** ចុះផ្ដាច់ការបដិវត្តន៍ លោកយល់ពាក្យហ្នឹងទេ?

**ធ៖** បាទ ខ្ញុំអត់ដែលទេ បញ្ហា ព្រោះខ្ញុំជនជាតិភាគតិច អត់ដែលយល់ អត់ដែលស្គាល់ទេបាទ។

**សៈ** នៅពេលដែលគេបង្រៀនលោក តើគេមានដែលឮលោកនិយាយអំពីពាក្យ “ផ្តាច់ការបដិវត្តន៍” ហ្នឹងទេ? គ្រាន់តែលោកឮនៅក្នុងសម័យនុ៎ង លោកធ្លាប់ឮទេ?

**ផៈ** បាទ អត់ដែលឮទេ ចំពោះខ្លួនខ្ញុំផ្ទាល់អត់ដែលឮទេ។

**សៈ** អរគុណលោក។ ពាក្យមួយទៀត ដែលគេធ្លាប់ប្រើ គឺពាក្យ “កម្ទេច” តើពាក្យហ្នឹងលោកដែលឮទេ ពាក្យ “កម្ទេច” ហ្នឹង?

**ផៈ** បាទ បញ្ហាហ្នឹង គេមិនដែលប្រាប់យើងទេ ព្រោះយើង-- ព្រោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំនៅក្រោមការដឹកនាំរបស់គេ។ ក្រោមផ្ទាល់យ៉ាងម៉េច? ត្រង់ថាខាងផ្នែកនីរសារ ខាងផ្នែកដាំបន្លែ យើងតូចយើងទាបគេមិនដែលប្រាប់យើងទេបាទ។

[០៩:៥៦:១៩]

**សៈ** ចុះពាក្យ “បីតោន” លោកដែលឮទេ?

**ផៈ** បាទ គ្រាន់តែឮ បីតោននោះគ្រាន់តែឮ។

**សៈ** គេសំដៅលើការផលិតអ្វីដែរ ឲ្យបានបីតោនហ្នឹង?

**ផៈ** ផលិត គឺផ្នែកដាំស្រូវ ធ្វើស្រែ ច្រូតកាត់ហ្នឹងមើលទៅ បានបីតោនហ្នឹង។ រឿងផលិតខាងស្រូវហ្នឹង។

**សៈ** ខ្ញុំសូមសួរលោកទាក់ទងនឹងសត្រូវ ៗរបស់បដិវត្តន៍ តើគេសំដៅទៅលើលោក លន់ នល់ តែម្នាក់ឯង ឬក៏សំដៅទៅលើទាហាន លន់ នល់ ទាំងអស់?

**ផៈ** បាទ ពេលនោះខ្ញុំមិនយល់ទេបញ្ហាជំនាន់ លន់ នល់ ជំនាន់អីខ្ញុំអត់ដែលដឹងទេ។

**សៈ** លោកធ្លាប់ឮ “អំណាចជិះជាន់” ទេ?

**ផៈ** បាទ ឮ ៗគេនិយាយថា “អំណាចជិះជាន់” ជិះជាន់កសិករ។ អ្នកមានជិះជាន់អ្នកកសិករហ្នឹងដែលឮ។

**សៈ** គេសំដៅទៅលើវណ្ណៈណាដែរ?

[០៩:៥៨:១២]

**ផៈ** តាមដឹង គេថាឲ្យតែវណ្ណៈកសិករ។

**សៈ** ខ្ញុំសួរលោកមួយសាទៀត។ “អំណាចជិះជាន់” លោកថាបានឮ បានដឹង។ តើ “អំណាចជិះជាន់” នេះនៅក្នុងកម្ពុជាប្រជាធិបតេយ្យ គេសំដៅនៅលើរបប លន់ នល់ ដែលកាន់អំណាចទៅលើ

មន្ត្រីទាំងអស់នោះ ឬមួយក៏យ៉ាងម៉េចដែរ លោកអាចពន្យល់បានទេ?

**ឆ៖** ខ្ញុំគ្រាន់តែដឹងទេ ព្រោះបញ្ហានេះ ខ្ញុំមិនដែលដឹង ព្រោះបញ្ហានេះគឺខ្ញុំដូចបានបញ្ជាក់ខាងដើមថា ខ្ញុំជាជនជាតិភាគតិច ដូច្នេះខ្ញុំមិនដែលដឹងបញ្ហានេះទេ។

**សៈ** តើលោកដឹងថា នៅពេលដែលគេចាប់បានទាហាន លន់ នល់ នោះ ឬមួយក៏គេយកទាហានហ្នឹងទៅណាដែរលោក?

**ឆ៖** បាទ ខ្ញុំមិនដែលដឹងទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

[០៩:៥៩:៤៦]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអភ័យទោស ដែលខ្ញុំកាត់ គឺថាសំណួរនេះសំណួរនាំមុខ គាត់បាន-- សហព្រះរាជអាជ្ញាបានស្នើនូវអង្គហេតុ ហើយឲ្យសាក្សីបញ្ជាក់។ នេះគឺជាសំណួរនាំមុខ ហើយសំណួរមួយចំនួនគឺថា ដូចជាខ្ពស់ជាងអ្វីដែលតំណែងគាត់បានដឹង គឺថា មិនសូម-- លោកសហព្រះរាជអាជ្ញាកុំយកអង្គហេតុទាំងមូល ឲ្យសាក្សីតែមួយហ្នឹងបញ្ជាក់ក្នុងរឿងក្តីទាំងមូល។ ដូច្នេះ សូមឲ្យបែងចែកសំណួរទៅតាមសាក្សីតាមមុខងាររបស់គាត់ ហើយដើម្បីឲ្យតបទៅនឹងមុខងាររបស់សាក្សី ដែលមកទីនេះផងបាទ។

[១០:០០:២៥]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការកត់សម្គាល់នេះ ប៉ុន្តែអង្គជំនុំជម្រះកត់សម្គាល់លោកមេធាវីដែរ លោកមេធាវីតែងតែ ការជំទាស់របស់លោក គឺយឺតពេល។ លោកគួរតែធ្វើឲ្យបានលឿន មុនពេលសាក្សីឆ្លើយដើម្បីឲ្យអង្គជំនុំជម្រះពិចារណា លើសេចក្តីជំទាស់ ហើយរំឭកឡើងវិញដល់លោកតំណាងសហព្រះរាជអាជ្ញាជាតិ សូមពិនិត្យលើសំណួរ ដែលលោកតាំងសួរចំពោះសាក្សី គោលដៅដែលត្រូវសួរ ហើយនិងការប្រើពាក្យពេចន៍ ការពន្យល់នូវពាក្យពេចន៍ ដែលមានអត្ថន័យជ្រាលជ្រៅ ហើយធៀបជាមួយនឹងសមត្ថភាពនៃការយល់ដឹង ហើយនិងមុខងារភារកិច្ចរបស់គាត់ នៅក្នុងអំឡុងពេលនៃព្រឹត្តិហេតុ ដែលគាត់ដឹងហើយតាំងសំណួរ។

ទីពីរ សំណួរដែលពាក់ព័ន្ធ គឺមាននៅក្នុងកំណត់ហេតុជាមូលដ្ឋាន នៃអ្នកស៊ើបអង្កេតរបស់ការិយាល័យសហស៊ើបអង្កេតបានរៀបចំរួចហើយ សំណួរជាមូលដ្ឋានថា សាក្សីណាដឹងរឿងអី ជាមូលដ្ឋានជាសំខាន់នោះ សាក្សីណាដឹងអង្គហេតុទូលំទូលាយ តាំងពីដើមរហូតដល់ចប់ រហូតដល់អង្គជំនុំជម្រះកំណត់ឲ្យតាំងសំណួរដេញដោលចំពោះសាក្សីនោះ ក្នុងវិសាលភាពនៃសំណុំរឿង០០២ ទាំងមូលដូចជាសាក្សីផ្តល់សក្ខីកម្មកាលពីម្សិលមិញ។ ហើយសាក្សីផ្សេងទៀត គឺមានមូលដ្ឋាននៅក្នុងការកត់សម្គាល់ដោយអ្នកស៊ើបអង្កេតរួចហើយថា គាត់ស្គាល់ គាត់ដឹងជាក់ច្បាស់ ពាក់ព័ន្ធទៅនឹងអង្គហេតុទៅនឹងព្រឹត្តិហេតុណាមួយនៅក្នុងដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសក្ខីកម្មរបស់គាត់។

[១០:០២:១៦]

សូមតម្រង់ទិសឲ្យចំបញ្ហា មិនមែនសួរដើម្បីបានសួរនោះទេ សួរដើម្បីបានចម្លើយដែលឆ្លុះបញ្ចាំងការពិតទៅនឹងអង្គហេតុដែលចោទប្រកាន់ ទៅនឹងបទល្មើសដែលចោទប្រកាន់ ជាភស្តុតាងដែលឆ្លុះបញ្ចាំងពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព ដែលជាមូលដ្ឋាននៃការពិចារណាសម្រេចចុងក្រោយនៃសាលក្រមរបស់អង្គជំនុំជម្រះ។ សូមកំណត់គោលដៅតាំងសំណួរឲ្យបានច្បាស់លាស់ កម្មវត្ថុ នៃការសួរចំពោះគោលដៅ ចំពោះសាក្សីនីមួយៗឲ្យបានត្រឹមត្រូវ ហើយឆាប់រហ័ស។ មានការយឺតយ៉ាវអង្គជំនុំជម្រះមិនពន្យារពេលឲ្យទេ ពេលវេលាគឺកំណត់ជាក់ច្បាស់ មានតែកាត់បន្ថយទេ រឿងថាដំឡើងពេលវេលាឲ្យគឺមិនមានទេ។

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន។ ខ្ញុំមិនជាជំទាស់លោកប្រធានទេ ក៏ប៉ុន្តែនៅក្នុងអង្គហេតុដែលខ្ញុំសួរ--

[១០:០៣:២០]

**ប្រធានអង្គជំនុំ៖**

លោកតាំងសំណួរបន្តទៀត! ជៀសវាងសំណួរដែលនាំមុខ សំណួរច្រំដែល សំណួរឧបមាណវិធីសំណួរក្រៅអង្គហេតុជាដើម ជៀសឲ្យផុតទៅបានហើយ ហើយសំណួរគួរតែខ្លីៗ ដើម្បីឲ្យសាក្សីដែលគាត់មានកម្រិតវប្បធម៌កម្រិតប៉ុននេះ ដែលគាត់បានបង្ហាញស្មោះត្រង់ចំពោះមុខអង្គជំនុំជម្រះរួចហើយគាត់ស្តាប់យល់ ហើយអាចឆ្លើយបាន។ មិនមែនសំណួរសំខាន់ សួររហូតដល់សាក្សីស្តាប់មិនយល់សំណួរថា សំណួរហ្នឹងវាអស្ចារ្យនោះទេ។

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** ខ្ញុំសួស្តីលោក អឿន តាន មួយសាទៀត។ ខ្ញុំដឹងថា លោកជាកងការពារ អ៊ីចឹងលោកស្គាល់ពីរបៀបរបបទាហាន អ៊ីចឹងលោកស្គាល់ លោកដឹងថា តើពាក្យ “ក្នុងជួរ” និង “ក្រៅជួរ” វាមានន័យយ៉ាងម៉េចដែរលោក?

**លោក អឿន តាន៖**

**ឆ៖** បាទ ពេលនោះខ្ញុំមិនយល់ទេ ក្រៅជួរ ក្នុងជួរ ក្រៅជួរ ខ្ញុំអត់ស្គាល់ អត់យល់បញ្ហាហ្នឹងទេ។

[១០:០៥:០១]

**ស៖** នៅពេលគេបង្រៀនលោក តើគេដែល-- លោកដែលឮនិយាយពាក្យថា ទង់បដិវត្ត និងទង់ -- និងទស្សនាវដ្ដីយុវជន យុវនារី បិដវត្តទេ?

**ឆ៖** បាទ ដែល ដែលឃើញ។

**ស៖** លោកដែលឮពាក្យ “សហករណ៍” ទេ?

**ឆ៖** បាទ ដឹង ពាក្យ “សហករណ៍” គឺដឹង។

**ស៖** ជាកន្លែងសម្រាប់ធ្វើអីដែរលោក?

**ឆ៖** សហករណ៍ហ្នឹង គឺកន្លែងធ្វើស្រែ ធ្វើចម្ការ ដាំនេះដាំនោះ។ កន្លែងសហករណ៍រួម។ ខ្ញុំដឹងតែប៉ុណ្ណឹង។

[១០:០៦:២៤]

**ស៖** ចុះ “កងចល័ត” វិញ គេសំដៅលើអីលោក?

**ឆ៖** “កងចល័ត” គេសំដៅទៅការលើកប្រឡាយ ជីកទំនប់ លើកភ្លឺ តែប៉ុណ្ណឹង។

**ស៖** ក្នុងនាមលោកជានីរសារ លោកដែលឮថា កងកុមារ ឬក៏លោកបញ្ជូនសារអី ទៅកងកុមារហ្នឹងដែរទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលទេ បញ្ជូនសំបុត្រទៅកន្លែងកុមារ អត់ដែល។

**ស៖** លោកដែលឮពាក្យ “កងកុមារ” ទេ?

**ឆ៖** ដែល។

**ស៖** គេសំដៅលើអី “កងកុមារ” ហ្នឹង?

**ឆ៖** មិនដឹងគេសំដៅលើអីទេ ព្រោះកន្លែងវាផ្សេងៗគ្នា ខ្ញុំមិនដែលដឹងទេ។

**ស៖** លោកដែលយកសំបុត្រទាក់ទងនឹងការរៀបការរបស់-- រៀបការរបស់កងទ័ពដែលពិការទេ?

[១០:០៧:៣៥]

**ឆ៖** បាទ គឺខ្ញុំអត់ដែលទេ។

**ស៖** លោកដែលឮនៅក្នុងសម័យហ្នឹង មានការរៀបការទេ?

**ឆ៖** បាទ គឺដែលឮ។

**ស៖** ចុះពាក្យ ខុសសីលធម៌ លោកដែលឮទេ?

**ឆ៖** បាទ ខ្ញុំដែលឮ។

**ស៖** វាមានន័យយ៉ាងម៉េចដែរ? មានខុសសីលធម៌ច្រើនទេ នៅក្នុងអង្គភាពនីរសាររបស់លោកហ្នឹង?

**ឆ៖** សីលធម៌ហ្នឹង គឺសំដៅទៅការប្រព្រឹត្ត ន៎ែ ប៉ះពាល់របស់ប្រជាជន ប៉ះពាល់ព្រទ្យសម្បត្តិប្រជាជន។ សីលធម៌គឺសំដៅតែហ្នឹងទេ សំដៅទៅការប៉ះពាល់ព្រទ្យសម្បត្តិប្រជាជន មាន់ទាប្រជាជន។ បើខុសឆ្គង គឺហៅគ្នាមកណែនាំ អប់រំ បាទ។

[១០:០៨:៥០]

**ស៖** ដែលឮខុសសីលធម៌ជាមួយស្ត្រីភេទទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលឮទេ បញ្ហានេះ។

**ស៖** ក្នុងនាមលោកជាកងការពារ និងលោកជានីរសារផង ប្រើបានទាំងពីរ។ តើលោកដែល-- នៅពេលដែលយើងរត់-- លោករត់សំបុត្រនោះ លោកដែលឃើញសំបុត្រ ឬក៏ឮពាក្យថា ប្រតិកិរិយាទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី! សាក្សីកុំអាល់ទាន់ឆ្លើយ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ គឺដោយសារតែលោកអង្គជំនុំជម្រះបានបញ្ជាក់ហើយ ខ្ញុំសូមជំទាស់នៅពេលនេះ។ សំណួរនេះសួរហើយ ហើយលោកសាក្សីបញ្ជាក់ហើយថា នៅពេលនោះ គាត់មិនអាចអានបាននោះទេ។ នៅពេលនេះ សំណួរនេះបានសួរម្តងទៀត ហើយសាក្សីបានបញ្ជាក់រួចមកហើយ ថាគាត់មិន

អាចអានទេ នៅពេលនោះ។ សំណួរនេះ មិនត្រឹមតែជាន់គ្នានោះទេ ហាក់ដូចជាមើលទៅ ស្តាប់ទៅក៏មិនគួរសមដែរ។ សូមអរគុណ។

[១០:១០:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

បើកក្បាលមីក្រូផង!

**លោក វ៉េង ហ៊ត់៖**

ខ្ញុំសួរអម្បាញ់មិញនេះ ខ្ញុំសួរថា លោកអាន ឬក៏លោកឮ?

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីការពារក្តីមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរដោយតំណាងសហព្រះរាជអាជ្ញានេះទេ វាឥតមានប្រយោជន៍ ក្នុងការស្វែងរកការពិតនៃរឿងក្តីនេះទេ។ អង្គជំនុំជម្រះមិនត្រូវការស្តាប់នូវការឆ្លើយតបនឹងសំណួរនេះទេ។ តំណាងសហព្រះរាជអាជ្ញារៀបចំសំណួរឲ្យបានត្រឹមត្រូវ ហើយឲ្យចំនូវអង្គហេតុដែលឯកសារបានចង្អុលបង្ហាញ ភាពពាក់ព័ន្ធនៃសាក្សីទៅលើអង្គហេតុដែលគាត់បានដឹងជាក់ច្បាស់នៅក្នុងកិច្ចដំណើរការស៊ើបអង្កេតកន្លងមក ហើយនៅក្នុងវិសាលភាពនៃក្របខ័ណ្ឌយុត្តាធិការ អ.វ.ត.ក ១៧ មេសា ៧៥, ០៦ មករា ១៩៧៩។

**លោក វ៉េង ហ៊ត់៖**

*(មិនបើកក្បាលមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

លោកបើកក្បាលមីក្រូ លោកដូចជាចូលសវនាការជាច្រើនលើកច្រើនសាដែរហើយ ម៉េចក៏ដូច្នេះ!

**លោក វ៉េង ហ៊ត់៖**

អរគុណលោកប្រធាន ហើយនិងក្រុមប្រឹក្សាជំនុំជម្រះ ខ្ញុំនឹងរំលងសំណួរទាំងអស់នេះ។ ខ្ញុំចូលទៅដល់ឆ្នាំ១៩៧៥ តែម្តង។

[១០:១១:៤៣]

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** នៅថ្ងៃទី១៧ មេសា ឆ្នាំ៧៥ តើពេលនោះលោកនៅទីណាដែរលោក?

**លោក អឿន តាន៖**

**ឆ៖** បាទ ឆ្នាំ១៩៧៥ ខ្ញុំនៅកន្លែងភូមិត្រពាំងទឹម ខេត្តកំពង់ចាម។

**ស៖** តើលោកដឹងពីការជម្លៀសរបស់ប្រជាជនចេញពីទីក្រុងភ្នំពេញទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេ ព្រោះអីខ្ញុំនៅខេត្តកំពង់ចាមឯនោះ។

**លោក វ៉េង ហ៊ត់៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន។ ហើយអរគុណលោកប្រធាន និងក្រុមប្រឹក្សាចៅក្រមដែលបានជួយតម្រង់ទិសដល់រូបខ្ញុំ។ អរគុណចំពោះការស្ដាប់ និងការណែនាំរបស់លោកមេធាវី ម៉ៃខល កាណាវាស និងមេធាវីទាំងអស់។ អរគុណលោក អឿន តាន ខ្ញុំអស់សំណួរហើយ ហើយសូមលោកជួយផ្ដល់ចម្លើយជាច្រើនទៀតទៅនឹងសហការីរបស់ខ្ញុំបាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បន្តការតាំងសំណួរចំពោះសាក្សី។

[១០:១៣:៤៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ សូមគោរពមេធាវីភាគីទាំងអស់ សូមសួស្ដីលោក អឿន តាន សូមអរគុណលោក ដែលមកទីនេះផ្ដល់ចម្លើយដល់តុលាការ។ ឈ្មោះខ្ញុំគឺ ថារីក អាប់ឌុលហាក់ ខ្ញុំជាសមាជិកមួយនៃការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំនឹងសួរសំណួរលោកមួយចំនួន បន្ថែមទៅលើសំណួរដែលសហសេវិករបស់ខ្ញុំបានសួររួចមកហើយ។

ខ្ញុំគ្រាន់តែចង់ចំណាយពេលមួយចំនួនខ្លីតែប៉ុណ្ណោះ នៅក្នុង-- នៅមុនឆ្នាំ១៩៧៥ ដើម្បីធ្វើការបញ្ជាក់បំភ្លឺទៅលើអង្គហេតុដែលលោកបានឆ្លើយរួចមកហើយ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកបានចូលបដិវត្តន៍នៅរតនគិរី ហើយលោកក៏បានឆ្លើយថា-- ឆ្លើយអំពីតួនាទីរបស់លោក តើធ្វើអ្វីក្រោយពីចូលបដិវត្តន៍។ តើលោកនៅរតនគិរីហ្នឹងរយៈពេលប៉ុន្មានដែរ ហើយមានទៅ-- ផ្លាស់ប្ដូរទៅកន្លែងផ្សេងទៀតដែរឬទេ?

[១០:១៤:៥៧]

**ឆ៖** បាទ ខ្ញុំរត់ទៅរតនគិរី ឆ្នាំ១៩៦៨ ដល់ ឆ្នាំ១៩៧០ ខ្ញុំចុះមកកំពង់ចាម។

**ស៖** សូមអរគុណច្រើន។ នៅពេលដែលលោកទៅកំពង់ចាម លោកបានឆ្លើយប្រាប់យើងខ្ញុំថា ខ្ញុំគិតថាលោករស់នៅភូមិមួយឈ្មោះថា ត្រពាំងទឹម តើលោកជម្រាបអង្គជំនុំជម្រះដែរឬទេ ត្រពាំងទឹម នេះស្ថិតនៅក្នុងស្រុកណាដែរ?

**ឆ៖** បាទ ភូមិត្រពាំងទឹម គឺស្ថិតនៅក្នុងខេត្តកំពង់ចាម ស្រុក ខ្ញុំអត់ស្គាល់ទេ។

**ស៖** សូមអរគុណច្រើន។ លោកបានឆ្លើយថា លោកជាអ្នកយាម អៀង សារី, នួន ជា, ខៀវ សំផន និងអ្នកផ្សេងទៀតដែលលោកមិនស្គាល់ទេ តើលោកមានឃើញចូល-- ប៉ុល ពត ចូលរួមក្នុងកិច្ចប្រជុំដែរឬទេ នៅពេលដែលលោកធ្វើការយាមកាមនោះ?

**ឆ៖** បាទ ឃើញ ប៉ុល ពត អ្នកដឹកនាំធ្វើការប្រជុំ។

[១០:១៦:៤០]

**ស៖** សូមអរគុណ។ តើកិច្ចប្រជុំហ្នឹង ប្រជុំញឹកញយប៉ុនណាដែរលោក?

**ឆ៖** ប្រជុំពេលខ្លះ មួយថ្ងៃពេញទៅ។

**ស៖** តើប៉ុន្មានដងដែរ ប្រជុំហ្នឹង តាមអ្វីដែលលោកចាំនោះ? ប្រជុំរាល់សប្តាហ៍ រាល់ខែ ឬក៏ច្រើនដងក្នុងមួយខែ តើប៉ុន្មានដងដែរលោក?

**ឆ៖** បាទ ការប្រជុំហ្នឹងក្នុងមួយខែបីទៅបួនដង ក្នុងមួយខែៗ។

**ស៖** សូមអរគុណ។ នៅក្នុងអំឡុងឆ្នាំនោះ តើលោកចាំដែរឬទេ ឬក៏លោកធ្លាប់រស់នៅក្នុងភូមិតាំងដា ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែរទេ។

**ស៖** សូមអរគុណ។ លោកបានប្រាប់យើងខ្ញុំថា លោកបានឃើញកិច្ចប្រជុំទាំងអស់នោះ។ តើលោកអាចជម្រាបបន្ថែមដែរឬទេ តាមអ្វីដែលលោកចាំនោះ។ តើ នួន ជា, អៀង សារី, ខៀវ សំផន នៅតែបន្តប្រជុំនៅកន្លែងនោះដដែល ឬក៏គាត់ទៅប្រជុំនៅកន្លែងផ្សេង?

**ឆ៖** បាទ គាត់ប្រជុំនៅកន្លែងដដែលទេ តាមខ្ញុំចាំ។

**ស៖** តើពួកគាត់ទាំងអស់ហ្នឹងរស់នៅឯណាដែរ?

[១០:១៩:១១]

**ឆ៖** ពួកគាត់រស់នៅតែក្នុង-- សូមទោសលោក ខ្ញុំសូមបញ្ជាក់ ចាប់ពីឆ្នាំណា?

**សៈ** សូមអរគុណ។ លោកនិយាយថា ពីទសវត្សរ៍ឆ្នាំ៧០ លោកនៅក្នុងខេត្តកំពង់ចាម ដែលគេប្រជុំនៅក្នុងខេត្តនោះ។ តើលោកអាចជម្រាបយើងខ្ញុំដែរឬទេ បុគ្គលទាំងអស់ដែលខ្ញុំបានបញ្ជាក់ខាងដើមនុ៎ង គាត់រស់នៅឯណាដែរ?

**ផៈ** បាទ ពេលនោះ គាត់ជួបជុំគ្នានៅខេត្តកំពង់ចាម ភូមិត្រពាំងទឹម គាត់បានជួបជុំគ្នាភូមិត្រពាំងទឹម។

[១០:២០:០០]

**សៈ** យើងបានរៀបរាប់-- យើងបានពិភាក្សាទៅលើរយៈពេលដែលកន្លងយូរមកហើយ។ ខ្ញុំសូមលើកឡើងទីតាំងមួយទៀត ហើយតើលោកចាំទេ តើលោកធ្លាប់យាមនៅកន្លែងនោះដែរឬទេ? គឺនៅកន្លែងឈ្មោះមាស នៅក្នុងព្រៃកក់ ខេត្តកំពង់ចាម តើលោកចាំថាធ្លាប់យាមនៅកន្លែងនោះដែរឬទេ?

**ផៈ** បាទ ខ្ញុំអត់ធ្លាប់ទេ។

**សៈ** សូមអរគុណ។ នៅពេលដែលលោកចាកចេញពីរតនគិរីទៅតំបន់កំពង់ចាម តើលោកបានធ្វើដំណើររួមជាមួយនរណាគេដែរ?

[១០:២១:១៧]

**ផៈ** បាទ ពេលនែ៎ចេញពីរតនគិរីមក មកកាន់កំពង់ធំ-- កំពង់ចាម ដំណើរជាមួយនែ៎ ប៉ុល ពត, ប៉ង់ តែប៉ុណ្ណោះ។

**សៈ** តើលោកចាំដែរឬទេ ប៉ង់ នោះកាន់នាទីអ្វីដែរនៅពេលនោះ?

**ផៈ** ពេលនោះ ប៉ង់ ក្តាប់រួម ដឹកនាំចុះមកកំពង់ចាម។

**សៈ** សូមអរគុណ។ តើពេលដំបូងនៅក្នុងពេលណាដែរ ដែលលោកបានឃើញ នួន ជា, ខៀវ សំផន និង អៀង សារី? ឃើញគាត់ដំបូង ពួកគាត់ដំបូងនៅពេលណាដែរ?

**ផៈ** បាទ ខ្ញុំចុះមកឆ្នាំ១៩៧០ ពាក់កណ្តាលឆ្នាំ៧០ ខ្ញុំបានឃើញ នួន ជា, ខៀវ សំផន។

**សៈ** ចុះ អៀង សារី តើលោកបានជួបគាត់នៅកំពង់ចាម ឬក៏ជួបមុនទៅដល់កំពង់ចាម?

**ផៈ** បាទ អៀង សារី ខ្ញុំជួបនៅរតនគិរីឯណោះ។

[១០:២៣:០៤]

**សៈ** តើលោកចាំទេនៅពេលនោះគាត់ធ្វើអីដែរ? មាននាទីអ្វីដែរ?

**ផៈ** ខ្ញុំអត់ដែលដឹងទេ។

**សៈ** តើលោកដឹងដែរឬទេ នៅពេលណាដែរដែលគាត់បានធ្វើដំណើរទៅកំពង់ចាម ដែលលោកថានៅពេលទៅដល់កំពង់ចាមនោះ លោកក៏បានឃើញគាត់ហ្នឹងចូលរួមប្រជុំជាមួយនឹងមេដឹកនាំផ្សេងទៀតដែរ?

**ឆៈ** នែ៎ ពេលនោះ អៀង សារី ចុះមកកំពង់ចាម បានជួបជុំ មាន អៀង សារី, មាន នួន ជា, មាន ខៀវ សំផន, ប៉ុល ពត បានជួបជុំនៅកំពង់ចាម។

**សៈ** ដូច្នេះលោកធ្វើដំណើរជាមួយនឹង ប៉ុល ពត និង ប៉ង់ មកពីរតនគិរី។ តើ អៀង សារី មកជាមួយក្រុមលោកដែរ ឬក៏គាត់ធ្វើដំណើរដោយឡែកពីក្រុមលោក?

**ឆៈ** បាទ គាត់នៅក្រោយ។

[១០:២៤:១៥]

**សៈ** សូមអរគុណ។ តាមអ្វីដែលលោកចាំ តើ អៀង សារី ស្នាក់នៅកំពង់ចាមរហូតទៅដល់ឆ្នាំ៧៥ ដែរឬទេ?

**ឆៈ** ដល់ពេលនែ៎រំដោះភ្នំពេញ បានឃើញ អៀង សារី ចូលមក។

**សៈ** ខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះ។ នេះមានន័យថា ក្រោយមកដែលលោកបានឃើញ អៀង សារី នាពេលក្រោយមក គឺនៅពេលដែលរំដោះភ្នំពេញ។ តើអ៊ីចឹងដែរឬទេ?

**ឆៈ** បាទៗ គឺអ៊ីចឹង។

[១០:២៥:០៨]

**សៈ** ដូច្នេះ គាត់ហ្នឹងចាកចេញពីកំពង់ចាម តាមអ្វីដែលខ្ញុំយល់ពីចម្លើយលោក គឺគាត់ចេញពីកំពង់ចាមនៅក្នុងឆ្នាំណាមួយនាពេលនោះ។ តើលោកចាំទេ លោក អៀង សារី ហ្នឹងចេញពីកំពង់ចាមមកនោះនៅក្នុងឆ្នាំណាដែរ?

**ឆៈ** បាទ ខ្ញុំអត់ដែលចាំទេ។

**សៈ** ខ្ញុំសូមសួរបញ្ជាក់មួយសំណួរទៀតត្រង់ចំណុចនេះ។ លោក តាន លោកថា អៀង សារី ចាកចេញពីកំពង់ចាម ហើយបន្ទាប់មកលោកឃើញគាត់ក្រោយថ្ងៃបែកភ្នំពេញ។ លោកបានឆ្លើយខាងដើមថា លោកឃើញពួកគាត់ទាំងអស់គ្នាប្រជុំគ្នានៅកំពង់ចាម។ នេះមានន័យថា ថាតើនៅពេលដែលគាត់ចាកចេញពីកំពង់ចាមនោះ គាត់មានធ្វើដំណើរទៅជួបប្រជុំគ្នានៅកំពង់ចាមដែរទេ? ឬក៏យ៉ាងម៉េចលោក?

**ផ៖** បាទ គាត់ទៅនៅ ក្រោយមកជួបជុំគ្នានៅភ្នំពេញ។

[១០:២៦:៣២]

**ស៖** ខ្ញុំចង់បញ្ជាប់ត្រង់ចំណុចនេះ ក៏ប៉ុន្តែវាហាក់ដូចជាមិនច្បាស់ត្រង់ចំណុចនេះ ខ្ញុំសូមបញ្ជាក់បំភ្លឺ។ លោកបានប្រាប់យើងខ្ញុំថា លោកឃើញ ប៉ុល ពត, នួន ជា, ខៀវ សំផន និង អៀង សារី ប្រជុំគ្នានៅក្នុងតំបន់ខេត្តកំពង់ចាម។ ហើយលោកបាននិយាយថា អៀង សារី ចេញពីកំពង់ចាម ហើយក្រោយមកលោកជួបគាត់នៅក្នុងទីក្រុងភ្នំពេញ។ តាមអ្វីដែលលោកចាំ ដូច្នេះ លោកបានជួបតែ អៀង សារី នៅដើមទសវត្សរ៍ឆ្នាំ៧០ ពេលដែលគាត់ជួបប្រជុំគ្នានៅពេលនោះទេ តើក្រោយមកលោកបានជួបគាត់ដែរឬទេ?

**ផ៖** ក្រោយមកខ្ញុំអត់ដែលជួបទេ ក្រោយមក។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរបញ្ជាក់បំភ្លឺទៀត លោកប្រាប់សហព្រះរាជអាជ្ញាមុនថា លោកគឺជានីរសារ ហើយក្រោយមក លោកជាអ្នកយាម។ តើលោកចាំដែរទេ លោកក្លាយជាអ្នកយាមនោះនៅក្នុងឆ្នាំណាដែរ?

**ផ៖** បាទ ខ្ញុំក្លាយជាអ្នកយាមកងការពារ គឺចាប់ពីឆ្នាំ មុនឆ្នាំ៧០ រហូតដល់៧៥, ៧៦, ៧៧ ក្រុមខ្ញុំវាមានគ្នា៣០នាក់ បែងចែកគ្នាដាំបន្លែផង យាមផង តែប៉ុណ្ណឹង។

[១០:២៨:៥០]

**ស៖** តើអ្នកណាគេដែរ ដែលចាត់តាំងលោកឲ្យធ្វើជាកងការពារ?

**ផ៖** បាទ គឺឈ្មោះ ប៉ង់។

**ស៖** តើប្រសិនបើខ្ញុំយល់មិនខុសទេ តាមចម្លើយរបស់លោកនោះគឺថា លោកការពារ ប៉ុល ពត និងមេដឹកនាំដទៃទៀត។ តើនេះជាការងារទូទៅរបស់លោក ដែលរូបលោកធ្វើការការពារអ្នកដឹកនាំនោះមែនដែរឬទេ?

**ផ៖** បាទ ពេលនោះគឺថា ខ្ញុំតែមួយឡែកទេ តែដល់ពេលគេជួបជុំការប្រជុំអីចឹងទៅ ខ្ញុំចាត់ចែងការពារជុំវិញកន្លែងធ្វើការហ្នឹង។

**ស៖** នៅពេលណាដែលលោកឈប់ធ្វើជាកងការពារ? លោកបាននិយាយថា លោកធ្វើជាកងការពាររហូតដល់ឆ្នាំ៧៥, ៧៦ ឬ៧៧ តើក្រោយពីឆ្នាំនោះ លោកធ្វើជាកងការពារដែរឬទេ? នៅពេលណាដែលលោកឈប់ធ្វើជាកងការពារនោះ?

**ឆ៖** ដល់ពេលដែលវៀតណាមចូលក្នុងស្រុក។

[១០:៣០:៣៧]

**ស៖** លោកធ្វើការឲ្យ ប៉ុល ពត ហើយនិងមេដឹកនាំផ្សេងៗទៀតប្រហែលជា៥ឆ្នាំបាទ ជាអ្នកយាមហ្នឹង?

**លោក ម៉ែខល កាណាវាស៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំមិនដឹងថា នេះជាការនិយាយខុស ឬក៏ជាការនាំមុខទេ គឺថាគាត់ធ្វើការ គាត់បានធ្វើអ្វី? ហើយបើសហព្រះរាជអាជ្ញាលើកបែបនេះ វាហាក់ដូចជាការនាំមុខដូច្នោះ។ ហើយខ្ញុំមិនចង់រំខានដំណើរការច្រើនពេកទេ។ សូមអរគុណបាទ។

[១០:៣១:១៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំចង់ដឹងអំពីចំណុចមួយ ហើយខ្ញុំនឹងបំភ្លឺជាមួយសាក្សី។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក តាន តើលោកយាមអ្នកណាខ្លះ? លោកយាមឲ្យតែ ប៉ុល ពត ឬក៏មានអ្នកផ្សេងដែរ?

**លោក អឿន តាន៖**

**ឆ៖** បាទ ពេលនោះគឺខ្ញុំយាមតែ ប៉ុល ពត ទេ។ ព្រោះអ្នក នួន ជា, អៀង សារី, ខៀវ សំផន គេនៅផ្ទះផ្សេង កន្លែងផ្សេង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការ ផ្តល់កន្លែងសម្រាកសមរម្យនៅបន្ទប់រង់ចាំសម្រាប់សាក្សី

ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១០:៣២ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:១៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ មុននឹងប្រកាសផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី អង្គជំនុំជម្រះកត់សម្គាល់ឃើញមានវត្តមាននៃមេធាវីប្រឹក្សាសាក្សី។

ហើយដើម្បីជាប្រតិចារឹក អង្គជំនុំជម្រះសូមសួរទៅ មេធាវី ប្រឹក្សាសាក្សីថា តើលោកឈ្មោះអ្វីដែរ? ហើយលោកអាចប្រាប់បានទេ ថាតើលោកពីការិយាល័យណា? ហើយនិងលោកមានអត្តលេខនៅក្នុងគណៈមេធាវីកម្ពុជាហ្នឹងប៉ុន្មានដែរ?

**លោក សេង រិទ្ធី៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំបាទឈ្មោះ សេង រិទ្ធី ដែលជាមេធាវីនៃសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ អត្តលេខ ៤៧០។ សូមអរគុណ។

[១០:៥៣:១៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដោយបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សូមជម្រាបសួរលោក តាន ជាថ្មីម្តងទៀត។ មុនពេលដែលយើងសម្រាកនោះ លោកបានប្រាប់តុលាការថា លោកបានយាម ប៉ុល ពត ប៉ុន្តែចំពោះ ខៀវ សំផន, នួន ជា ពួកគាត់រស់នៅក្នុងផ្ទះនៅកន្លែងផ្សេង។ តើលោកដឹងទេថាតើផ្ទះរបស់ពួកគាត់នៅកន្លែងណា? នៅឆ្ងាយពីផ្ទះ ប៉ុល ពត ប៉ុនណាដែរ?

**លោក អឿន តាន៖**

**ឆ៖** បាទ ផ្ទះ ខៀវ-- លោក ខៀវ សំផន និងផ្ទះ នួន ជា នៅឆ្ងាយប្រហែលជាបី-បួនរយម៉ែត្រ។

[១០:៥៤:៤៣]

**ស៖** សូមអរគុណ។ លោកបានប្រាប់ខ្ញុំ និងតុលាការថា លោកមិនដឹងថាពួកគាត់មានតំណែងអ្វីទេនៅពេលនោះ។ តើលោកដឹងថា ពួកគាត់ទទួលខុសត្រូវអ្វីទេ ក្រៅពីបានឃើញគាត់ ឬក៏ជួបគាត់នៅពេលដែលគាត់មកប្រជុំជាមួយ ប៉ុល ពត នោះ?

**ឆ៖** បាទ ខ្ញុំអត់ដែលដឹងទេ នួន ជា, ខៀវ សំផន មិនដឹងជាតួនាទីអីទេ ខ្ញុំអត់ដឹង ពីព្រោះគេមិនដែលប្រាប់យើងផង។

**ស៖** សូមអរគុណ។ តាមដែលខ្ញុំយល់លោកនោះ បើមិនខុសទេ លោកនិយាយថា លោកនៅកំពង់ចាម នៅក្នុងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥។ តើ ប៉ុល ពត បានរស់នៅមូលដ្ឋាននេះពេញពេល ដែលលោកនៅទីនោះទេ? តើលោកនៅចាំទេ គាត់ចេញពីមូលដ្ឋានហ្នឹង នៅពេលណា?

**ឆ៖** បាទ គាត់ចេញពីមូលដ្ឋាននៅកំពង់ចាម គាត់មកនៅភ្នំពេញ ឆ្នាំ៧៥។

[១០:៥៦:៣៣]

**ស៖** តើលោកនៅចាំ បាទ នៅចាំខែទេ នៅក្នុងខែ ដូចជា ខែមករា, មីនា, មេសា គឺថាមុនៗពេល ឬក៏នៅពេលដែលភ្នំពេញដួលរលំ?

**ឆ៖** បាទ ខ្ញុំអត់ចាំថ្ងៃខែទេ លោក។

**ស៖** នៅពេលដែលគាត់ចាកចេញពីកន្លែងនោះទៅ តើ ខៀវ សំផន, នួន ជា ក៏បានចាកចេញពីមូលដ្ឋាននោះ ឬក៏ពួកគាត់នៅកន្លែងនោះដែរ?

**ឆ៖** បាទ ពេលរំដោះភ្នំពេញ គឺ នួន ជា, ខៀវ សំផន និង ប៉ុល ពត ចូលមកមុន។ ចាកចេញពីកំពង់ចាមមក។

**ស៖** នៅពេលដែលលោកនិយាយថា ពួកគាត់មកភ្នំពេញមុន តើលោកចង់និយាយថា ពួកគាត់មកភ្នំពេញមុន ប៉ុល ពត មកឬ?

**ឆ៖** មិនមែនទេ គាត់ទៅព្រមគ្នា១បីនាក់ហ្នឹង។

[១០:៥៧:៥៨]

**ស៖** សូមអរគុណដែលលោកបានបំភ្លឺចំណុចនេះ។ តើពេលដែលពួកគាត់ចាកចេញទៅ តើលោកនៅកន្លែងណាដែរកាលណោះ?

**ឆ៖** បាទ គាត់ចាកចេញមកភ្នំពេញមក ខ្ញុំនៅកំពង់ចាម។ ចាំអីវ៉ែអីវ៉ាន់ ជាខោជាអាវ។

**ស៖** ចាតើហេតុអ្វីបានជាលោកត្រូវរៀបចំខោអាវ តើខោអាវរបស់អ្នកណា?

**ឆ៖** បាទ ពេលនោះ ខ្ញុំរៀបចំខោអាវ ប៉ុល ពត, នួន ជា រៀបចំដើម្បីមកភ្នំពេញ។ ក្រោយមក ប៉ង់ គេហៅមក បានខ្ញុំចុះមក។ ចុះមកក្រោយប៉ុ ល ពត ប្រហែលកន្លះខែ។

[១០:៥៩:១៥]

**ស៖** សូមអរគុណ។ នៅពេលដែលពួកគាត់ចេញពីកំពង់ចាម ប៉ុល ពត, នួន ជា, ខៀវ សំផន តើ ប៉ង់ បានចាកចេញទៅជាមួយពួកគាត់ ឬក៏ ប៉ង់ នៅក្រោយ?

**ឆ៖** បាទ គឺ ប៉ង់ ចាកចេញជាមួយគាត់ បីនាក់ហ្នឹង បួននាក់ទាំង ប៉ង់។

**ស៖** សូមអរគុណ។ លោកបានឆ្លើយនឹងសហព្រះរាជអាជ្ញាជាតិថា នៅឆ្នាំ-- នៅខែមេសា ថ្ងៃទី១៧ ឆ្នាំ១៩៧៥ នោះ គឺថាលោកនៅកំពង់ចាមនៅឡើយ។ តើលោកបានដឹងអំពីជ័យជម្នះរបស់ខ្មែរក្រហមនោះ ដឹងដោយរបៀបណា?

**ឆ៖** ពេលនេះដឹងតាមការប្រកាស ថាជ័យជម្នះ១៧ មករា (ស៊ីក) ឆ្នាំ១៩៧៥ បានឮគេប្រាប់ ឮគេផ្សព្វផ្សាយជាបន្តបន្ទាប់មក។

**ស៖** តើនរណាគេអានសេចក្តីប្រកាសនោះ តើមាននរណាគេជាអ្នកចេញសេចក្តីប្រកាសនោះជាក់លាក់ទេ? តើនរណាគេជាអ្នកចេញនោះ?

**ឆ៖** បាទហ្នឹងគេប្រាប់ត១តាមមាត់ អត់មាននរណាប្រកាសទេ គេប្រាប់ ត១តាមមាត់។

**ស៖** តើលោកឮសេចក្តីប្រកាសនោះដោយផ្ទាល់តែម្តង ជាក់ស្តែងតាមវិទ្យុ ឬក៏ឮតាមរបៀបណា?

**ឆ៖** តាមរបៀបមាត់ ត១គ្នា ឮថាជ័យជម្នះភ្នំពេញ ១៧ មករា (ស៊ីក) ឮតែប៉ុណ្ណឹងទេ។

**ស៖** តើពេលដំបូងដែលលោកបានដឹងថាគេជម្លៀសភ្នំពេញនោះ ពេលដំបូងដែលលោកដឹងៗនៅពេលណាដែរ?

**ឆ៖** ខ្ញុំដឹងពេលចុះមកភ្នំពេញ ចូលភ្នំពេញមក គឺស្ងាត់ អត់ឃើញប្រជាជន។

**ស៖** តើលោកបានឮអ្វីពាក់ព័ន្ធនឹងការជម្លៀសទីក្រុងភ្នំពេញដែរឬទេ ឬក៏លោកឮការជម្លៀសក្រុងភ្នំពេញហ្នឹងមុនពេលដែល មុនពេលដែលគេជម្លៀសទៅទៀត?

**ឆ៖** ពេលនោះ ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅកំពង់ចាមឯណោះ។ មិនដឹងគេជម្លៀសពេលណាៗខ្ញុំអត់ដឹងទេ។ ដល់ពេលចុះមកភ្នំពេញ វាស្ងាត់ក្នុងភ្នំពេញនោះ អត់ឃើញមនុស្ស។

**ស៖** សូមអរគុណ។ នៅពេលដែលលោកធ្វើដំណើរមកទីក្រុងភ្នំពេញនេះ តើលោកមកតែម្នាក់ឯងទេ ឬក៏លោកធ្វើដំណើររួមជាមួយអ្នកផ្សេង?

**ឆ៖** បាទ ពេលនោះខ្ញុំរួមជាមួយអ្នកផ្សេងៗ មកជាមួយគ្នា។

[១១:០៣:៣០]

**ស៖** តើក្រុមដែលធ្វើដំណើរមករួមគ្នានោះ មានមនុស្សចំនួនប៉ុន្មានដែរ ហើយមានតែអ្នកយាមកងការពារប៉ុណ្ណោះ ឬក៏ធ្វើដំណើររួមជាក្រុមច្រើនជាមួយអ្នកផ្សេង?

**ឆ៖** បាទ ពេលនោះខ្ញុំដំណើរគ្នា ក្រុមខ្ញុំ១០នាក់ ដឹកអីវ៉ាន់មកពីកំពង់ចាមមកភ្នំពេញ។

**ស៖** តើអីវ៉ាន់ៗនេះ គឺជាអីវ៉ាន់របស់ នួន ជា និង ប៉ុល ពត ដែលលោកនិយាយថា លោកជាអ្នករៀបចំយកមក ឬក៏ជាអីវ៉ាន់របស់នរណាគេដែរ?

**ឆ៖** អីវ៉ាន់មាន អីវ៉ាន់ ប៉ុល ពត, អីវ៉ាន់ នួន ជា។

**ស៖** នៅពេលដែលលោកមកដល់ភ្នំពេញ តើលោកទៅណាទៀត?

**ឆ៖** ខ្ញុំមកដល់ភ្នំពេញហើយ ខ្ញុំអត់ទៅណាទេ គឺខ្ញុំនៅភ្នំពេញ នៅផ្ទះ ក-១ របស់ ប៉ុល ពត។

[១១:០៥:០៤]

**ស៖** តើលោកអាចប្រាប់តុលាការដែរឬទេ ក-១ នេះមានទីតាំងនៅឯណាដែរ ហើយ ក-១ នេះជាកន្លែងអ្វីដែរ?

**ឆ៖** បាទ ខ្ញុំសូមអធិប្បាយខ្លះដល់បញ្ហាហ្នឹង។ ទីតាំង ក-១ នៅជាប់ទន្លេបាសាក់ តាមមាត់ទន្លេបាសាក់ ជាទីតាំងធ្វើការរបស់ ប៉ុល ពត។

**ស៖** តើទីតាំងនេះ គឺជាទីតាំងដែលលោកធ្វើការចាប់ពីឆ្នាំ៧៥ ដល់៧៩ រហូតមែនដែរឬទេ?

**ឆ៖** បាទ ទីតាំងនេះ គឺចាប់ពីឆ្នាំ៧៥ រហូតដល់ ៧៩ ទីតាំងកន្លែង ប៉ុល ពត ធ្វើការ។

**ស៖** ចុះ ប៉ង់ តើ ប៉ង់ ធ្វើការនៅកន្លែងនោះដែរ ឬក៏គាត់ធ្វើការនៅកន្លែងផ្សេង?

**ឆ៖** បាទ ប៉ង់ ធ្វើការជាមួយ ប៉ុល ពត។ ប៉ុល ពត, នួន ជា និង ខៀវ សំផន នៅទីតាំង ក-១។

[១១:០៦:៥៨]

**ស៖** នៅពេលដែលលោកនិយាយថា ធ្វើការជាមួយពួកគេ តើលោកដឹងទេ? តើ ប៉ង់ នោះទទួលខុសត្រូវអ្វីដែរ? ធ្វើការងារអ្វីដែរជាមួយពួកគេនោះ?

**ឆ៖** បាទ ប៉ង់ គឺអ្នកដឹកនាំរួមខាង-- ដឹកនាំខាងក្រុមនីរសារផង ដឹកនាំខាងន័ះ ខាងដាំដុះផង។ ប៉ុណ្ណឹងទេ។

**ស៖** នៅក្នុងឆ្នាំនោះ នៅពេលដែលលោកមកដល់ ក-១ តើលោកមាននាទីអ្វី? ទទួលខុសត្រូវអ្វីដែរ?

**ឆ៖** បាទ ពេលនោះ ខ្ញុំដល់ភ្នំពេញមាន ប៉ង់ គាត់ចាត់តាំងខ្ញុំធ្វើប្រធានក្រុម កងការពារ ក-១។

**ស៖** ក្រុមដែលលោកដឹកនាំ តើក្រុមហ្នឹងមានមនុស្សប៉ុន្មាននាក់ដែរសមាជិកនោះ ហើយទទួលខុសត្រូវអ្វីដែរ?

**ឆ៖** មួយក្រុមខ្ញុំមាន១០នាក់ ជាតួនាទីគឺថា ការរៀបចំផ្ទះ បោសច្រាសផ្ទះ លើកបាយឱ្យ ប៉ុល ពត ហើយន័ះ ដាំបន្លែតាមមាត់ទន្លេហ្នឹង។ អាហ្នឹងគឺជាភារកិច្ចរបស់ខ្ញុំ អ្វីដែល ប៉ង់ ចាត់តាំងគឺមានៗ អីចឹង។ ចាត់តាំងឱ្យការបោសច្រាសផ្ទះសម្បែង ការបោកគួកខោអាវរបស់ ប៉ុល ពត ផង ហើយនិងរបស់ន័ះ អីៗផ្សេងទៀត ពេលគេមកធ្វើការ។

[១១:០៩:២០]

**ស៖** តើលោកមានតួនាទីពាក់ព័ន្ធទៅនឹងការការពារដែរឬទេ ចំពោះហេតុការណ៍ដែលលោករៀបរាប់នោះ?

**ឆ៖** បាទ ខ្ញុំទាក់ទិនត្រង់ថា ការពារ ការពារទីតាំងរបស់ ប៉ុល ពត ធ្វើការ។ ចាត់ចែងកម្លាំងដាំបន្លែ ដាំបង្ការអីចឹងទៅ លាងចាន លាងឆ្នាំង លាងចាន លើកបាយតែប៉ុណ្ណឹងទេ។

**សៈ** តើលោកធ្វើការនៅកន្លែងណាដែលជាក់ស្ដែងតែម្ដង នៅក្នុងបរិវេណក-១ ឬក៏យ៉ាងម៉េច? ហើយរស់នៅៗកន្លែងណាដែរក្នុងបរិវេណក-១ ឬក៏នៅក្រៅហ្នឹង?

**ឆៈ** បាទ ខ្ញុំនៅបរិវេណ ក-១។ ឯនៅក្រៅ ក-១ គឺមានអ្នកផ្សេងទៀតដឹកនាំដោយឈ្មោះ កែន ហៅ លីន។

**សៈ** អ៊ីចឹងបានន័យថា តាមអ្វីដែលលោករៀបរាប់ហ្នឹង គឺមានក្រុមការពារមួយទៀតដែលជាក្រុមទីពីរនៅក្រៅបរិវេណ ក-១ តើអ៊ីចឹងដែរឬទេ?

**ឆៈ** បាទ អ៊ីចឹងហើយ។

**សៈ** លោកជាអ្នកដឹកនាំក្រុមកងការពារចំនួន១០នាក់ តើនរណាគេជាមេផ្ទាល់គ្រប់គ្រងពីលើលោក?

**ឆៈ** មេដឹកនាំផ្ទាល់ពីលើខ្ញុំទៀតមាន ប៉ង់ អ្នកដឹកនាំពីលើខ្ញុំ។

[១១:១១:៥២]

**សៈ** នៅក្នុងអំឡុងឆ្នាំ៧៥ ដល់ ៧៩ តើលោកធ្លាប់ការពារ ឬក៏ធ្វើជាសន្តិសុខការពារអង្គប្រជុំដូចដែលលោកធ្លាប់ការពារនៅក្នុងកិច្ច-- អង្គប្រជុំមុនឆ្នាំ៧៥ ដែរឬទេ?

**ឆៈ** បាទ ពេលនោះ ខ្ញុំធ្លាប់ការពារកន្លែងធ្វើការជាប្រចាំថ្ងៃ។

**សៈ** តើកន្លែងធ្វើការប្រចាំថ្ងៃរបស់លោកនោះ គឺនៅក្នុង ក-១ ឬក៏នៅក្រៅបរិវេណទ្វារចូល? នៅកន្លែងទ្វារចូល ក-១ ឬក៏នៅក្រៅបរិវេណ ក-១ កន្លែងលោកធ្វើការ?

**ឆៈ** បាទ គឺក្នុងបរិវេណ ក-១។

**សៈ** ខ្ញុំចង់ត្រឡប់ទៅក្រោយបន្តិច ដើម្បីសួរលោក។ តើគេធ្លាប់ចាត់តាំងលោក ឬក៏លោកធ្លាប់ការពារការប្រជុំដែលគេជួបគ្នា-- ជួបប្រជុំគ្នាក្នុងមន្ទីរក-១ ដែរឬទេ?

**ឆៈ** បាទ ខ្ញុំអត់ដែលប្រជុំជាមួយអ្នកដឹកនាំធំៗទេ។ ខ្ញុំធ្លាប់តែការប្រជុំជាមួយ ប៉ង់ ហើយជាមួយក្រុមខ្ញុំអីហ្នឹង ជាប់នឹង ប៉ង់ ហ្នឹង។ ប៉ង់ អ្នកដឹកនាំប្រជុំ។

**សៈ** សូមអរគុណ។ យើងខ្ញុំនឹងសួរសំណួរនេះឡើងវិញ ពាក់ព័ន្ធទៅនឹងការប្រជុំនេះ។ លោកបានរៀបរាប់ប្រាប់យើងខ្ញុំថា ប៉ុល ពត នៅក្នុងក-១។ តើលោកដឹង ខៀវ សំផន, នួន ជា និង អៀង សារី រស់នៅឯណាដែរនៅពេលនោះ?

[១១:១៤:១២]

**ឆ៖** បាទ ខៀវ សំផន, នួន ជា គាត់រស់នៅផ្ទះផ្សេង ហៅផ្ទះក-៣។ រស់នៅផ្ទះផ្សេងទីតាំង ក-៣។ ឯ អៀង សារី គឺនៅៗ ប-១ ។

**ស៖** តើលោកធ្លាប់ឃើញ ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី ជួបប្រជុំគ្នានៅក្នុងកន្លែងដូចដែលលោកបានរៀបរាប់ដែរឬទេ? គឺធ្លាប់ជួបនៅ ក-១, ក-៣ ឬក៏ ប-១ ដែរឬទេ?

**ឆ៖** បាទ ពេលនោះគឺប្រជុំមាន នួន ជា, អៀង សារី, ខៀវ សំផន ហើយអ្នកផ្សេងៗតែមិនចាំឈ្មោះទេ គេប្រជុំនៅ ក-១ តែម្តង។

**ស៖** នៅពេលដែលពួកគាត់ទាំងអស់នោះជួបប្រជុំគ្នា តើមានអ្នកផ្សេងមកចូលរួមប្រជុំជាមួយនឹងពួកគាត់ដែរឬទេ? ឬក៏ការប្រជុំហ្នឹង គឺក្នុងចំណោមអ្នកតែទាំងបួននាក់តែប៉ុណ្ណោះ?

[១១:១៦:០៨]

**ឆ៖** មានអ្នកផ្សេង តាមនែ៎ដឹង តាមភូមិភាគ តាមតំបន់ គេមកប្រជុំជាមួយដែរ។

**ស៖** ការប្រជុំដែលមានអ្នកភូមិភាគ អ្នកតំបន់មកចូលរួមប្រជុំជាមួយគ្នានោះ តើការប្រជុំនោះប្រជុំញឹកញយប៉ុនណាដែរ? ប៉ុន្មានអាទិត្យដែរ ហើយប៉ុន្មានដងក្នុងមួយខែដែរ?

**ឆ៖** បាទ ខ្ញុំភ្លាប់មិនសូវបាន--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកមេធាវី!

**លោក អាកឡូវ វែកកែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះចំណុចនេះ ជាភាសាបារាំងគឺបកប្រែថា "បើសាក្សីចាំនោះ គឺមានអ្នកមកពីតំបន់ និងមកពីភូមិភាគ"។ ហើយសហព្រះរាជអាជ្ញាបានរៀបចំសំណួរគាត់ឡើងវិញ ពាក់ព័ន្ធនឹងការកត់សម្គាល់នោះ គឺថាមាន-- ទៅជាមានថាអ្នកតំណាងមកពីតំបន់ និងភូមិភាគទៅវិញ ហើយជាភាសាបារាំង គឺសាក្សីគាត់មិនបាននិយាយបែបនេះទេ។

[១១:១៧:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំនឹងធ្វើការរៀបចំសំណួរឡើងវិញលោកប្រធាន។ ហើយខ្ញុំនឹងព្យាយាមប្រើពាក្យរបស់សាក្សីតែម្តង។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកនិយាយថា មានអ្នកមកពីភូមិភាគ មកពីតំបន់ មកចូលរួមប្រជុំ តើអ្នកដែលមកពីភូមិភាគនិងតំបន់នោះមានតួនាទីអ្វីដែរ ដែលមកចូលរួមប្រជុំហ្នឹង?

**លោក អឿន តាន៖**

**ឆ៖** បាទ ខ្ញុំក្តាប់មិនសូវបានទេ គ្រាន់តែឮថាពីតំបន់ ពីភូមិភាគគេមកប្រជុំ ព្រោះដឹងតាមន៉ែប៉ង់ គេប្រាប់។

**ស៖** ខ្ញុំសូមត្រឡប់ទៅសំណួរខាងដើមរបស់ខ្ញុំមួយវិញ តើអ្នកដែលមកពីភូមិភាគ តំបន់មកប្រជុំនៅ ក-១ នោះ ប្រជុំញឹកញាប់ប៉ុនណាដែរ?

[១១:១៨:៤១]

**ឆ៖** បាទ ការប្រជុំពេលខ្លះ មួយខែប្រជុំម្តង ពេលខ្លះកន្លះខែម្តង តាមការចាំបាច់។ នេះឃើញរបស់ខ្ញុំទេ ជាប្រចាំថ្ងៃគឺអ៊ីចឹង។

**ស៖** ខ្ញុំសូមសួរបំភ្លឺដើម្បីឱ្យយើងខ្ញុំយល់ឱ្យច្បាស់។ ការប្រជុំដែលមានអ្នកភូមិភាគ តំបន់ មកចូលរួមនោះ តើការ-- តើអ្នកដែលមកពីតំបន់ ភូមិភាគ មកពីតំបន់ មកពីភូមិភាគនោះមកចូលរួមប្រជុំជាមួយនឹងលោកប្រធាន-- លោក ខៀវ សំផន, អៀង សារី, នួន ជា ដែរឬទេ?

**លោក ម៉ែខល កាណាវាស៖**

ខ្ញុំសូម--

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ចាំស្តាប់សាក្សី-- អង្គជំនុំជម្រះសម្រេចលើសេចក្តីជំទាស់របស់មេធាវីការពារក្តី។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលយើងស្តាប់រួម ប្រហែលជាធ្វើឱ្យយើងយល់ច្រឡំ វាអាចជាការផ្តល់ចម្លើយឱ្យយើងខុស។ ខ្ញុំៗសូមស្នើថា វិធីសាស្ត្រដែលប្រុងប្រយ័ត្នក្នុងការសួរនោះ គួរតែប្រើប្រាស់។ តើនរណាគេចូលរួម? នរណាមានវត្តមានក្នុងពេលប្រជុំ ហើយញឹកញាប់ប៉ុនណា? កុំឱ្យសាក្សីឆ្លើយ មែន និង ពិតជាដូច្នោះ។ គឺយើងគួរតែឱ្យសួរបញ្ជាក់ថា តើមានប៉ុន្មាននាក់? មាននរណាខ្លះវត្តមាន? ប្រសិនបើមិនដូច្នោះទេ គឺការសួរសំណួរហ្នឹង ហើយនិងចម្លើយឆ្លើយមកយើងហ្នឹង ធ្វើឱ្យ

យើងយល់ច្រឡំ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមានបំណងសួរសំណួរបន្ថែមទៀត។ ហេតុផលដែលខ្ញុំសួរតាមពាក្យដែលខ្ញុំសួរនេះ គឺដោយសារតែខ្ញុំបានឮសាក្សីនិយាយថា គាត់ឃើញប៉ុល ពត, ខៀវ សំផន, អៀង សារី, នួន ជា ជួបប្រជុំគ្នានៅ ក-១ ហើយខ្ញុំយល់ថា គាត់ក៏បានឆ្លើយថា មានអ្នកមកពីភូមិភាគ និងមកពីតំបន់មកចូលរួមប្រជុំដែរ។ ដូច្នេះ ខ្ញុំគ្រាន់តែសួរបញ្ជាក់ថាតើ មានចូលរួមប្រជុំជាមួយនឹងអ្នកទាំងអស់នោះដែរឬទេ? ដូច្នេះហើយយើងខ្ញុំទុកឱ្យលោកប្រធានជាអ្នកសម្រេចទៅលើចំណុចនេះ។ សូមអរគុណ។

[១១:២១:២០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីការពារក្តីគ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវការស្តាប់នូវចម្លើយតបរបស់សាក្សី ទៅនឹងសំណួរដែលសួរចុងក្រោយដោយតំណាងសហព្រះរាជអាជ្ញាអម្បាញ់មិញនេះ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកតាន តើលោកចង់ឲ្យខ្ញុំសួរសំណួរឡើងវិញដែរឬទេលោក?

**លោក អឿន តាន៖**

**ឆ៖** អត់ទេបាទ។

**ប្រធានអង្គជំនុំ៖**

លោកឆ្លើយនឹងសំណួរចុងក្រោយរបស់លោកតំណាងសហព្រះរាជអាជ្ញា ដែលបានសួរលោក បើសិនជាលោកមិនចាំបាច់ឲ្យគេសួរទេ។ តើលោកនៅចាំទេ ចាំសំណួរដែលគាត់-- តំណាងសហព្រះរាជអាជ្ញាសួរចុងក្រោយអម្បាញ់មិញដែរឬទេ?

[១១:២២:១៧]

**លោក អឿន តាន៖**

បាទ ចាំ។

**ប្រធានអង្គជំនុំ៖**

ចាំ ឆ្លើយតបនឹងសំណួរចុងក្រោយអម្បាញ់មិញនេះ!

**លោក អឿន តាន៖**

**ឆ៖** បាទ សូមលោកបញ្ជាក់ម្តងទៀត។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក អឿន តាន លោកបាននិយាយថា មានអ្នកមកពីភូមិភាគ មកពីតំបន់ចូលរួមប្រជុំមួយខែម្តង ពេលខ្លះកន្លះខែម្តង។ ខ្ញុំសូមសួរលោកថា តើការប្រជុំនេះគឺប្រជុំជាមួយនឹង ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន អ៊ីចឹងមែនដែរឬទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ថា មកពីតំបន់ មកពីភូមិភាគ មកប្រជុំនៅកន្លែង ប៉ុល ពត មាន ខៀវ សំផន, អៀង សារី, នួន ជា បាទ។

**ស៖** សូមអរគុណ។ តើ ប៉ង់ មានចូលរួមប្រជុំជាមួយគេដែរឬទេ តាមលោកចាំនោះ?

**ឆ៖** បាទ អំមិញខ្ញុំសូមទោស មាន ប៉ង់ មានមុខចូលរួមប្រជុំដែរបាទ។

[១១:២៤:០៨]

**ស៖** តើលោកដឹងដែរឬទេ នរណាគេដែរជាអ្នករៀបចំការប្រជុំទាំងអស់នេះ?

**ឆ៖** បាទ ការរៀបចំប្រជុំទាំងអស់នេះ មាន ប៉ុល ពត តួនាទីប្រជុំ។

**ស៖** តើ ប៉ុល ពត ហ្នឹង គាត់ទទួលនាទីប្រជុំហ្នឹង គាត់រៀបចំយ៉ាងម៉េចដែរ? គឺគាត់មានចេញសេចក្តីណែនាំអញ្ជើញគេឲ្យមកចូលរួមប្រជុំដែរឬទេ?

**ឆ៖** បាទ ពេលគាត់ប្រជុំមក គឺគាត់ហៅតាមដូចថា សរសេរសំបុត្រ លាយលក្ខណ៍ជាអក្សរហៅតំបន់ ភូមិភាគ មកការប្រជុំហ្នឹង។

**ស៖** តើលោកដឹងដែរឬទេ នរណាគេដែរ ដែលជាអ្នកសរសេរលិខិតនុ៎ង? ហើយនរណាគេដែលជាអ្នកទទួលបន្ទុកបញ្ជូនលិខិតនុ៎ងចេញហ្នឹង?

**ឆ៖** បាទ អ្នកសរសេរសំបុត្រអញ្ជើញ តាមភូមិភាគតំបន់គឺ ប៉ុល ពត ហើយឲ្យតាមរយៈខ្ញុំៗជូនទៅផ្នែកផ្សេងទៀត គេជូនទៅទៀត ជូនតទៅទៀត។

[១១:២៥:៥៥]

**ស៖** តើលោកទទួលសំបុត្រនេះពី ប៉ុល ពត មែនដែរឬទេ? តើលោកទទួលដោយផ្ទាល់ ឬក៏មានអ្នកផ្សេងយកមកឲ្យលោក?

**ឆ៖** បាទ គឺមាន ប៉ង់ ឲ្យខ្ញុំ ជូនទៅ ក-៧។ នីរសាររនៅ ក-៧ តទៅទៀត។

**ស៖** ខ្ញុំសូមសួរបញ្ជាក់។ ដូច្នេះបានន័យថា លោកជាអ្នកយកលិខិតពីមន្ទីរ ក-១ យកទៅឲ្យមន្ទីរ ក-៧ តើមែនដែរឬទេ?

**ឆ៖** បាទ មែនហើយ។

**ស៖** តើលោកមានបានជួយរៀបចំការប្រជុំទាំងអស់នោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំគ្រាន់តែជួយរៀបចំ ការបោសសម្អាតកន្លែងធ្វើការតែប៉ុណ្ណឹងទេ កន្លែងប្រជុំ បោសសម្អាតកន្លែងប្រជុំតែប៉ុណ្ណឹងទេ។

**ស៖** តើនរណាគេដែលជាអ្នកចាត់តាំងលោក ឲ្យធ្វើការបោសសម្អាតហ្នឹង? លោកទទួលការណែនាំពីនរណាគេដែរ?

**ឆ៖** បាទគឺ ទទួលការណែនាំពីឈ្មោះ ប៉ង់ ទទួលខុសត្រូវរួម។

**ស៖** តើលោកមានធ្លាប់និយាយអំពីការប្រជុំនេះ ជាមួយ ប៉ុល ពត ដែរឬទេ? ហើយ ប៉ុល ពត ធ្លាប់និយាយប្រាប់លោកអំពីការប្រជុំនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំដែលឮពីរយៈ ប៉ង់ ប្រាប់ថា គេមកប្រជុំថ្ងៃនេះៗអីទៅ ដឹងតាមរយៈ ប៉ង់ ប្រាប់ខ្ញុំ។

**ស៖** តើមានមនុស្សប្រហែលជាប៉ុន្មាននាក់ដែរ ចូលរួមប្រជុំនុំង?

[១១:២៨:៤៧]

**ឆ៖** បាទពេលខ្លះ ខ្ញុំឃើញ១០នាក់ ទៅ១៧នាក់។ ខ្ញុំឃើញអ៊ីចឹង ជាប្រចាំការប្រជុំប៉ុណ្ណឹង។ ប្រាំពីរនាក់ ដប់នាក់ ភាគច្រើនគឺ១០នាក់, ប្រាំដណ្ដប់នាក់។

**ស៖** តាមអ្វីដែលលោកចាំ តើការប្រជុំនោះប្រជុំម្ដងៗនោះយូរប៉ុនណាដែរ?

**ឆ៖** បាទពេលខ្លះប្រជុំមានមួយថ្ងៃ ពេលខ្លះមានពីរថ្ងៃ តែប៉ុណ្ណឹងទេបាទ។

**ស៖** នៅពេលដែលការប្រជុំនោះ បន្តប្រជុំដូចដែលលោកបានបញ្ជាក់ តើ ប៉ុល ពត, ខៀវ សំផន, នួន ជា, អៀង សារី នោះ គាត់ចូលរួមប្រជុំរហូតតែម្ដងមែនដែរឬទេ រហូតដល់ចប់តែម្ដងមែនដែរឬទេ?

**ឆ៖** បាទ គឺប្រជុំរហូតដល់ចប់។

**ស៖** ឥឡូវនេះ យើងត្រឡប់ទៅក្រោយវិញបន្តិច គឺថានៅពេលមួយ តើលោកនៅចាំដែរឬទេ? នៅពេលដែលថា ពេលប្រជុំហ្នឹងចាប់ផ្ដើមពេលណា? ហើយចប់នៅពេលណា ក្នុងថ្ងៃនីមួយៗ ដូចថា

ព្រឹកចាប់ផ្តើមម៉ោងប៉ុន្មាន? ថ្ងៃសម្រាកប៉ុន្មាន ល្ងាចចាប់ផ្តើមម៉ោងប៉ុន្មាន? ចប់ម៉ោងប៉ុន្មានជាដើម?

**ឆ៖** បាទ តាមការដឹង គឺប្រជុំចាប់ពីម៉ោងប្រាំពីរព្រឹក រហូតដល់ម៉ោងដប់មួយថ្ងៃត្រង់ សម្រាកហូបបាយ។ ដល់ម៉ោងពីរ ទល់ម៉ោងប្រាំល្ងាចឈប់ បាទ។

[១១:៣១:៣៣]

**ស៖** នៅពេលដែលហើយយើងសម្រាកហូបបាយថ្ងៃត្រង់ហ្នឹង តើលោកយាម ហើយការពារសន្តិសុខ នៅពេលដែលការប្រជុំនោះបន្តទៅនោះ ដែរឬទេ?

**ឆ៖** បាទ ពេលគេសម្រាកហូបបាយ ខ្ញុំនៅការពារកន្លែង ជុំវិញកន្លែងហ្នឹង។

**ស៖** តើលោកបានដឹងអ្វីខ្លះ អំពីគោលបំណងនៃការប្រជុំហ្នឹងដែរឬទេ? ថាតើមូលហេតុអីបានជាពួកគាត់មកប្រជុំ?

**ឆ៖** បាទ ខ្ញុំអត់ដែលដឹងទេ ព្រោះនៅផ្នែកការពារ ថាអ្នកដឹកនាំជាន់ខ្ពស់អីចឹង គេមិនដែលប្រាប់យើងទេ។ ការងារដឹកនាំ គឺដឹកនាំ។ ការងារសំខាន់ខាងការពារ គឺដឹងថាការពារចម្ងាយតែ២០ម៉ែត្រ ទៅ ១០ម៉ែត្រ ១៥ម៉ែត្រតែប៉ុណ្ណឹង។ គេមិនដែលប្រាប់យើងទេ។

**ស៖** តើលោកធ្លាប់បានពិភាក្សា ថាតើការប្រជុំជាមួយ ប៉ង់ ហ្នឹង-- អំ ពិភាក្សាជាមួយ ប៉ង់ ទេពីការរឿងប្រជុំហ្នឹង។ តើប៉ង់ ប្រាប់អីខ្លះទេ?

[១១:៣៣:២២]

**ឆ៖** បាទ គឺអត់មានទេ។ ប៉ង់ ក៏គាត់ភាគច្រើន គាត់ណែនាំពីបញ្ហាការពារទេ។ ពីរឿងប្រជុំធំៗ អីចឹង គឺ ប៉ង់ មិនដែលប្រាប់ទេ។ ប្រាប់តែរឿង ហៅថាថ្ងៃនេះគេប្រជុំ ត្រូវរៀបចំអីខ្លះ? មានទឹកក្តៅ ទឹកត្រជាក់ រៀបចំផ្ទះសម្បែង គឺ ប៉ង់ តាមរយៈ ប៉ង់ គាត់ប្រាប់ខ្ញុំអីចឹង។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ លោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តនៅពេលនេះ គឺបង្ហាញជូននូវសាក្សីចម្លើយរបស់គាត់ដែលៗ គាត់បានឆ្លើយទៅសហចៅក្រមស៊ើបអង្កេត ហើយគ្រាន់តែសេចក្តីលម្អិតពីរបីចំណុច ដើម្បីឲ្យសាក្សីបញ្ជាក់ ហើយដើម្បីឲ្យខ្ញុំប្រើសំណួរច្រើនបាទ។ ខ្ញុំសូមអនុញ្ញាតបន្តបែបនោះ លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយលោកបង្ហាញឯកសារ អត្តសញ្ញាណដែលលោកមានបំណងដាក់

និងលើកមកយកមកសួរដេញដោលចំពោះសាក្សីរូបនេះទៅ យើងនឹងសម្រេច។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ឯកសារនោះ គឺD107/2។ តុលាការទទួលបានស្គាល់ ហើយដាក់លេខថា E3/33 ចុះថ្ងៃទី១៩ តុលា ឆ្នាំ២០០៨។ បាទ គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សី គឺសាក្សី អៀន តាន នេះឯង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក អាកទួរ វែកគែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់សួរពាក់ព័ន្ធទៅនឹងផលប្រយោជន៍នៃនីតិវិធី ដែលបង្ហាញដោយសហព្រះរាជអាជ្ញានេះ។ កាលពីប៉ុន្មានថ្ងៃមុននោះ យើងឃើញថាសហព្រះរាជអាជ្ញាបានប្រើប្រាស់សក្ខីកម្មដែលថាសាក្សីគាត់មិនចងចាំអំពីសេចក្តីលម្អិតដែលគាត់បានផ្តល់ជូន។ ដូច្នេះ ឥឡូវនេះព្រះរាជអាជ្ញា គាត់បានកំណត់នូវចំណុចច្បាស់ៗ ចំណុចលម្អិតជាក់លាក់ដែលសាក្សីគាត់មិនចាំនោះទេ។ ដូច្នេះ ខ្ញុំគិតថាការជំនុំជម្រះហ្នឹងមិនអាចធ្វើទៅអ៊ីចឹងបានទេ យើងមិនអាចគ្រាន់តែត្រឹមថាអានកំណត់ហេតុពីមុនៗរបស់សាក្សី ហើយយកមកឲ្យគាត់ឆ្លើយនោះទេ។ យើងគ្រាន់តែថា អានឡើងវិញ ហើយសួរថា អ៊ីចឹងមែនទេ ឬក៏មិនអ៊ីចឹងនោះ? យើងអាចធ្វើបាន ដោយមិនបាច់មានសាក្សីទេ។ ដូច្នេះខ្ញុំមិនយល់អំពីវិធីសាស្ត្រដែលសហព្រះរាជអាជ្ញាកំពុងតែធ្វើនេះទេ។ ខ្ញុំគ្រាន់តែចង់សុំឲ្យគាត់បំភ្លឺពីវិធីសាស្ត្ររបស់គាត់នេះ។

[១១:៣៦:៤៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន។ យើងគ្រាន់តែសួរបញ្ជាក់ទៅសាក្សីអំពីចម្លើយរបស់គាត់ ហើយដោយហេតុថាគាត់បានឆ្លើយបួនឆ្នាំកន្លងទៅហើយនោះ គឺថាវាអាចមានភាពខុសគ្នានៅក្នុងគំនិតនៃការចងចាំរបស់គាត់។ ដូច្នេះហើយ បានខ្ញុំចង់បានឲ្យលោកសាក្សី គាត់មើលចម្លើយរបស់គាត់ ហើយគាត់បញ្ជាក់ថាតើត្រឹមត្រូវដោយស្មោះត្រង់ដែរឬទេ? ហើយខ្ញុំគឺថា វាមានការលំបាកនៅពេលដែលប្រើចម្លើយទាំងមូល។ ដូច្នេះ គឺខ្ញុំចុចតែចំណុចដែលខ្ញុំចង់លើកមក ដើម្បីឲ្យគាត់ឆ្លើយតែប៉ុណ្ណោះបាទ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីការពារក្តីគ្មានប្រសិទ្ធភាព។

អង្គជំនុំជម្រះអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាអនុវត្តនូវវិធីសាស្ត្រក្នុងការតាំងសំណួរដូច្នេះ។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអនុញ្ញាត ហើយខ្ញុំសូមជូនឯកសារលើក្រដាសទៅសាក្សី ហើយសូមអនុញ្ញាតបញ្ចាំងនៅលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកទៅជូនសាក្សីពិនិត្យ ហើយនិងឲ្យមន្ត្រីដែលពាក់ព័ន្ធបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រនិងទូរទស្សន៍ផងដែរ។

[១១:៣៨:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក តាន ដូចដែលខ្ញុំបញ្ជាក់នេះ គឺថាសម្ភាសនោះ គឺកើតឡើងយូរហើយ ហើយលោកអាចបញ្ជាក់ថា តើការចងចាំរបស់លោកត្រឹមត្រូវទៅតាមចម្លើយហ្នឹងដែរឬទេ នៅទំព័រខ្មែរ 00231800 ហើយនិងបារាំង 00235331 ហើយនៅក្នុងភាសាអង់គ្លេស 00235127។

សូមអនុញ្ញាតបង្ហាញទំព័រនោះនៅក្នុងជាភាសាខ្មែរ ហើយខ្ញុំនឹងចាប់ផ្តើមបន្តសួរគាត់ពីចំណុចនោះទៅ។ ខ្ញុំគិតថា អង្គភាពខាងសោតទស្សន៍ក៏បានបង្ហាញរួចហើយ បាទ សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក តាន ខ្ញុំនឹងអានជូនលោកស្តាប់នូវសំណួរមួយ និងចម្លើយមួយ ដើម្បីឲ្យដឹងថា តើលោកបានឆ្លើយដែរឬទេ បើសិនជាលោកបានឆ្លើយ តើត្រូវ ឬមិនត្រូវ។

សូមលោក-- “សំណួរ៖ តើមុខងាររបស់ ក-១ នោះ គឺអ្វី? ឆ្លើយ៖ វាជាកន្លែងដែល ប៉ុល ពត

និងធ្វើការជាប្រចាំ និងជាកន្លែងប្រជុំដែលគាត់ប្រជុំជាមួយគណៈស្រុក គណៈតំបន់ និងគណៈភូមិភាគ។ ការប្រជុំមានក្នុងមួយខែម្តង ដោយមានអ្នកចូលរួមដូចជា ប៉ុល ពត ជាអ្នកដឹកនាំការប្រជុំ ហើយគាត់ជាអ្នកកោះប្រជុំផ្ទាល់។ អ្នកដែលចូលរួមប្រជុំមាន អៀង សារី, នួន ជា, ខៀវ សំផន តែ អៀង ធីរិទ្ធ ចូលរួមការប្រជុំមិនទៀងទាត់ទេ គឺចូលរួមម្តងម្កាលនៅពេលដែលការប្រជុំនោះ មានការពាក់ព័ន្ធនឹងរឿងសង្គមកិច្ច"។ ខ្ញុំសូមផ្អាកត្រឹមនេះ។ លោកបានរៀបរាប់នៅក្នុងការ នៅក្នុងចម្លើយនេះ គឺថា អ្នកដែលចូលរួមប្រជុំហ្នឹង គឺថា មានគណៈស្រុក គណៈតំបន់ ហើយនិងគណៈភូមិភាគ។ តើនេះជាចម្លើយត្រឹមត្រូវរបស់លោកដែរឬទេកាលនោះ ហើយនិងពេលនេះ នោះ?

[១១:៤១:១២]

**លោក អឿន តាន៖**

**ឆ៖** បាទ គឺពេលនោះ គេសម្ភាសមកគឺថាខ្ញុំចងចាំអីទាំង គឺខ្ញុំឆ្លើយប្រាប់ទាំងអស់។ អ្វីដែលខ្ញុំមិនចាំ ខ្ញុំមិននិយាយទេ ដូចបានបញ្ជាក់អំមិញហើយថា ការចម្លើយរបស់ខ្ញុំនេះត្រឹមត្រូវអស់ហើយ។ សម្រេចយកជាឯកសារតែម្តង។ នេះគឺមតិខ្ញុំ គឺថាគេសម្ភាសយ៉ាងម៉េច ខ្ញុំនិយាយយ៉ាងហ្នឹង អ្វីដែលពិតខ្ញុំនិយាយពិត។ អ្វីដែលមិនពិត ខ្ញុំអត់និយាយទេ។ សូមបញ្ជាក់ប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកច្រើន។ ខ្ញុំនឹងបន្តបាទ អានផ្នែកមួយទៀតនៅក្នុងចម្លើយនោះ ដើម្បីបញ្ជាក់ថាលោកនៅចាំ ឬក៏មិនចាំ។ បើសិនជាមិនចាំលោកប្រាប់ ផ្នែកនោះបន្តទៅទៀតថា៖ "ក្រៅពីអ្នកទាំងនោះ គណៈតំបន់ គណៈភូមិភាគ គណៈស្រុកក៏ចូលរួមផងដែរ តែខ្ញុំមិនស្គាល់ឈ្មោះទេ។ រាល់ការប្រជុំតែងតែមាន ប៉ង់ ចូលរួមដែរ ដោយគាត់ជាអ្នកទទួលខុសត្រូវរួម ព្រោះគាត់ជាអ្នកក្តាប់រួមនៅមន្ទីរ ៨៧០។ ខ្ញុំដឹងថា មានគណៈតំបន់ចូលរួមប្រជុំ ដោយសារ អ៊ំ ប៉ុល ពត ជាអ្នកបញ្ជាឲ្យខ្ញុំរៀបចំកន្លែងប្រជុំ ដោយគាត់ប្រាប់-- អឺ! ដោយមានគណៈតំបន់នោះចូលរួមផង"។

តើ ប៉ុល ពត ជាអ្នកប្រាប់ថា មានគណៈតំបន់ភូមិភាគហ្នឹងមកចូលរួមក្នុងអង្គប្រជុំដែរឬទេ?

[១១:៤៣:០០]

**ឆ៖** បាទ ប៉ុល ពត ប្រាប់ខ្ញុំថា មានតំបន់ ភូមិភាគ មកចូលរួមប្រជុំ។ គាត់ប្រាប់ខ្ញុំផ្ទាល់អីចឹង។

**ស៖** សូមអរគុណ។ លោកបាននិយាយថា គេបានផ្ញើសំបុត្រទៅតាមរយៈ ក-៧ ដើម្បីហៅអ្នកដែលមកពីតំបន់ ភូមិភាគមកប្រជុំ មកពី-- បាទ តើលោកដឹងដែរឬទេថា នួន ជា, អៀង សារី, ខៀវ

សំផន បានទទួលសំបុត្រ គឺក៏គេផ្ញើសំបុត្រទៅអញ្ជើញគាត់មកប្រជុំដែរឬទេ?

**ឆ៖** ពេលនេះ មានការប្រជុំគេសរសេរសំបុត្រអញ្ជើញមកប្រជុំ មាន នួន ជា, ខៀវ សំផន, អៀង សារី បីនាក់ហ្នឹង។ ហើយរួមជាមួយខាងតំបន់ គណៈតំបន់ គណៈស្រុក ប្រជុំបាទ។

[១១:៤៤:២៩]

**ស៖** ខ្ញុំចង់យល់ឲ្យច្បាស់ លោកនិយាយថា ការប្រជុំហ្នឹងធ្វើឡើងមួយខែម្តង ឬក៏កន្លះខែម្តង។ តាមអ្វីដែលលោកចាំនោះ តើ អៀង សារី, នួន ជា, ខៀវ សំផន ចូលរួមប្រជុំហ្នឹងទៀងទាត់ទេបាទ?

**ឆ៖** បាទ គឺពេលប្រជុំម្តងៗ គឺមានលោក ខៀវ សំផន, លោក អៀង សារី, នួន ជា ហើយអ្នកផ្សេងៗទៀត គឺការប្រជុំ គឺមានទៀងទាត់។ ឧទាហរណ៍ថា កន្លះខែម្តង ឬមួយខែពីរដង។ តែឃើញវាល់ដងអ៊ីចឹងបាទ។

**ស៖** មានចំណុចតូចមួយដែលខ្ញុំចង់សួរទាក់ទងទៅនឹងរយៈពេលនៃការប្រជុំ។ ហើយលោកនិយាយថា ជួនកាលគេប្រជុំមួយថ្ងៃ ជួនកាលគឺពីរបីថ្ងៃ។ បាទ អ៊ីចឹង ខ្ញុំចង់ឲ្យលោកបញ្ជាក់ឲ្យច្បាស់ថា តើការប្រជុំហ្នឹងវែងជាងហ្នឹងដែរឬទេបាទ?

**ឆ៖** បាទ ពេលនោះ តាមខ្ញុំធ្លាប់ការរស់នៅ បើថាមានការងារច្រើន បើថាមានការតិច គេប្រជុំតែមួយថ្ងៃទេ បើមានការងារច្រើនៗអ៊ីចឹងទៅ គេប្រជុំពីរថ្ងៃ ទៅបីថ្ងៃ។ ពេលខ្លះក៏មានទៀងទាត់អ៊ីចឹងបាទ។

[១១:៤៦:៣៥]

**ស៖** អ្នកដែលចូលរួមប្រជុំនោះ គឺមកពីតំបន់ ស្រុក ឬក៏ភូមិភាគ។ តើលោកកត់សម្គាល់ថាអ្នកហ្នឹងមកហ្នឹង គឺជាមនុស្សដដែលៗ ឬក៏ជាមនុស្សផ្លាស់ប្តូរអ្នកថ្មីមក អ្នកចាស់ផ្លាស់ដូចម្តេច តាមការសម្គាល់នោះ?

**ឆ៖** បាទ តាមការសម្គាល់របស់ខ្ញុំ គឺថាការមកប្រជុំម្តងៗតែមនុស្សដដែលៗទេ អត់មានអីផ្សេងមកទៀតទាំងអស់ អត់ទេ គឺមកតែអ្នកដដែលៗអ៊ីចឹងបាទ។

**ស៖** សូមអរគុណ។ នៅពេលនោះ តើលោកដឹងដែរឬទេថាតើ នួន ជា មានតួនាទីជាអ្វី?

**ឆ៖** បាទ ដូចខ្ញុំបានបញ្ជាក់ដើមហើយថា ខ្ញុំមិនដែលដឹងទេថា នួន ជា គាត់ជាតួនាទីអី ខ្ញុំមិនដែលដឹងទេ។ ខ្ញុំប្រាប់ត្រង់ ហើយច្បាស់អ៊ីចឹងតែម្តង។

[១១:៤៨:០០]

**ស៖** សូមអរគុណ។ តើលោកដឹងថា លោក ខៀវ សំផន ឬក៏ អៀង សារី គាត់មានតួនាទី ឬក៏ តំណែងជាអ្វីទេ នៅពេលនោះ?

**ឆ៖** បាទ អៀង សារី, ខៀវ សំផន ប៉ុន្តែខ្ញុំដឹងចំណុចលោក អៀង សារី គាត់ពីឆ្នាំ៧៥ ដល់ ៧៩ គាត់នៅខាងក្រសួងការបរទេស។ ឯចំណែក ឯ ខៀវ សំផន ខ្ញុំអត់ដឹងតួនាទីខាងអីទេ។

**ស៖** តើលោកដឹងអ្វីខ្លះ អំពី៧ថ្នាក់ ឬក៏កម្រិតដែលពួកគាត់នៅក្នុងបក្ស ដែលហៅថា "បក្សកុម្មុយនីស្តកម្ពុជា" ដែលលោកបានដឹងថាការប្រជុំទាំងអស់ហ្នឹង គឺជាការប្រជុំថ្នាក់ខ្ពស់ បាទ?

[១១:៤៩:១៧]

**ឆ៖** បាទ ខ្ញុំគឺមិនដែលដឹងទេ មិនដឹងជាខ្ពស់ប៉ុនណា ឬក៏នែយ៉ាងម៉េចៗទេគឺថា ព្រោះខ្ញុំដូចបានរៀបរាប់ជាបន្តបន្ទាប់ហើយថា ខ្ញុំមិនសូវយល់ទេការដឹកនាំ មិនដឹងគេដឹកនាំរឿងអី? មិនដឹងគេធ្វើអី? ការងាររបស់ដឹកនាំ ខ្ញុំមិនសូវដឹងទេបាទ។

**ស៖** លោកនិយាយថា លោកមិនបានដឹងថាអ្វីដែលពួកគាត់ធ្វើអ្វីនយោបាយអីទេ ប៉ុន្តែតាមអ្វីដែលលោកបានដឹងគឺ តើ នួន ជា, ខៀវ សំផន, អៀង សារី ពួកគាត់នៅក្នុងថ្នាក់ដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យនោះមែនទេ?

**ឆ៖** បាទ មែនហើយ។

**ស៖** ចុះ ប៉ង់ វិញ ថាតើគាត់ជាសមាជិកនៅក្នុងថ្នាក់ដឹកនាំហ្នឹងដែរឬទេ?

**ឆ៖** បាទ សូមទោស អត់បានបញ្ជាក់អំមិញ គឺថា ប៉ង់ នៅក្នុងផ្នែកនែ ដឹកនាំដែរ ពីព្រោះគាត់អ្នកដឹកនាំដែលហៅថា រួមក្នុងអង្គភាព។

**ស៖** សូមអរគុណ។ ពីខាងដើមនោះលោកបានបញ្ជាក់ថា មន្ទីរ៨៧០ តើលោកដឹងទេថាតើមន្ទីរ ៨៧០ នេះជាមន្ទីរអ្វី?

**ឆ៖** បាទ មន្ទីរ៨៧០ គឺ ប៉ង់ ដឹកនាំ ក្នុងទទួលបន្ទុក៨៧០ ប៉ុន្តែតួនាទីអីក៏ខ្ញុំអត់ដឹងដែរ បាទ។

[១១:៥១:៤៨]

**ស៖** ឥឡូវនេះលោកបានរៀបរាប់យ៉ាងពិស្តារឲ្យយើងខ្ញុំដឹង អំពីអ្វីដែលលោកបានដឹង អំពីការប្រជុំជាមួយពួកមនុស្សដែលមកពីថ្នាក់តំបន់ ហើយនិងភូមិភាគ។ ថាតើមានការប្រជុំអ្វីផ្សេងទៀតទេនៅក-១ ឬក៏ក-៣ ដែលកន្លែងដែលថ្នាក់ដឹកនាំគេប្រជុំនោះ? បាទ ក្រៅពីនៅក-១ តើមានការប្រជុំនៅក-៣ នោះដែរឬទេ?

**ឆ៖** បាទ អត់មានទេ ក-៣ គឺមានតែកន្លែង ក-១ តែមួយគត់។ ក-៣ គឺកន្លែងស្នាក់នៅរបស់ នៃ នួន ជា របស់ ខៀវ សំផន ទេ។ ទីតាំងធ្វើការប្រជុំគឺនៅ ក-១ បាទ។

**សៈ** នៅពេលដែលកន្លែងធ្វើការងារថានៅ ក-១ ហ្នឹង គឺថាជាកន្លែងធ្វើការងាររបស់តែ ប៉ុល ពត ឬក៏ធ្វើការងាររបស់មេដឹកនាំទាំងអស់ នៅក-១?

**ឆ៖** បាទ នៅកន្លែង ក-១ គឺដឹកនាំទាំងអស់។ ដោយឡែកតែ ក-៣ ហើយអ្នកផ្សេងៗពេលដែលកោះហៅប្រជុំទៅ គឺថាមក ក-១ ទាំងអស់។ អត់មានប្រជុំកន្លែងផ្សេងៗទៀតទេបាទ។

[១១:៥៣:៣៨]

**សៈ** តើញឹកញាប់ប៉ុនណាដែរ ដែល នួន ជា, ខៀវ សំផន ហើយនិង អៀង សារី ដែលមកធ្វើការនៅ ក-១ នោះ?

**ឆ៖** តាមការចាប់អារម្មណ៍របស់ខ្ញុំ គឺពេលការប្រជុំម្តងៗ ទាំងអស់នេះគឺថាមកញឹកញាប់ជាប្រជុំថ្ងៃដែរ ឲ្យតែកោះហៅគឺថាមកជាបន្តបន្ទាប់។ ញឹកញាប់តាមការកំណត់ និងតាមការឃើញរបស់ខ្ញុំ។ មិនដែលខានទេ បាទ។

**សៈ** តាមដែលលោកដឹង តើពួកគាត់ធ្វើការជាមួយគ្នាជាមួយ ប៉ុល ពត ឬក៏គេអាចមានកន្លែងធ្វើការខុសៗគ្នានៅ ក-១ រវាងមេដឹកនាំទាំងនេះ?

**ឆ៖** បាទ អត់មានទេ មានតែមួយកន្លែងហ្នឹង បាទ។

**សៈ** ខ្ញុំសួរបន្តពីចំណុចនេះទៅទៀត។ ហើយសូមលោកប្រាប់ខ្ញុំ បើសិនជាមិនត្រឹមត្រូវទេ។ អ្វីដែលលោកបានរៀបរាប់នោះ ថាតើត្រឹមត្រូវទេបើយើងនិយាយថា ប៉ុល ពត, នួន ជា, ខៀវ សំផន, អៀង សារី គឺធ្វើការជាមួយគ្នា?

**ឆ៖** បាទ គឺត្រឹមត្រូវតាមការនិយាយរបស់ខ្ញុំពីខាងដើម គឺជាភាសាខ្មែរ គឺអ៊ីចឹងមែន បាទ។

**សៈ** លោកបានរៀបរាប់ខាងដើមថា មេដឹកនាំ តើលោកស្គាល់ថាក្រុមពួកគាត់ហ្នឹងគឺថា តើក្រុមពួកគាត់ហ្នឹងមានការទទួលខុសត្រូវអ្វី? មុខងារក្រុមហ្នឹងគាត់ធ្វើអ្វី? ហើយពួកគាត់បានធ្វើ តើលោកបានដឹងទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលដឹងទេ។ ដូចបានបញ្ជាក់ខាងដើមថា អ្វីការងារដែលខ្ញុំដឹង ខ្ញុំឆ្លើយឲ្យអស់តែម្តង អ្វីដែលខ្ញុំមិនច្បាស់ មិនច្បាស់គឺអត់ឆ្លើយទេ អាហ្នឹង។ ព្រោះការងារដឹកនាំ គេមិនដែលប្រាប់យើងផង ព្រោះភារកិច្ចដឹកនាំ ដែលយើងខាងក្រោមៗ ដូចជាថា យើងជាកងការពារ។ ដូច្នេះគេមិនដែល

ប្រាប់ថា ខ្ញុំធ្វើនេះ ខ្ញុំធ្វើនោះ ខ្ញុំដឹកនាំយ៉ាងនេះ ខ្ញុំដឹកនាំយ៉ាងនោះ គេអត់ប្រាប់យើងទេ ព្រោះដឹកនាំគេគិតការងារដឹកនាំ ហើយផ្នែកយើងអាតូចតាច ខាងក្រោមៗគេមិនដែលប្រាប់យើងទេបាទ។

[១១:៥៦:៤៦]

**ស៖** សូមអរគុណ។ នៅពេលដែលលោកឆ្លើយសំណួរទៅនឹងសហព្រះរាជអាជ្ញាជាតិ លោកបាននិយាយថា លោកបានធ្វើដំណើរជាមួយ ប៉ុល ពត នៅក្នុងដំណើរមួយចំនួនមុនឆ្នាំ១៩៧៥ តើលោកធ្លាប់ធ្វើដំណើរជាមួយគាត់នៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ បញ្ហានេះ ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៩ ក៏ខ្ញុំបានធ្លាប់ គឺថា គាត់ហៅធ្វើដំណើរជាមួយគាត់។ គាត់ថាពីភ្នំពេញទៅបាត់ដំបង។ ពេលខ្លះពីភ្នំពេញទៅកំពង់ឆ្នាំង ពេលខ្លះពីភ្នំពេញមកសៀមរាប គាត់តែងតែហៅទៅជូនគាត់ដំណើរ ទៅមើលកន្លែងហៅថា ជីកប្រឡាយ ទៅមើលកន្លែងស្ទូងស្រូវ ដើម្បីដោះស្រាយជីវភាព។ ខ្ញុំធ្លាប់ជូនគាត់អ៊ីចឹង គាត់ហៅខ្ញុំទៅអ៊ីចឹង បាទ។

**ស៖** តើ ប៉ុល ពត បានធ្វើអ្វីនៅក្នុងពេលដែលធ្វើដំណើរទៅ ដែលថាក្រៅពីទៅមើលការលើកទំនប់ជីកប្រឡាយនោះ បាទ ដែលលោកអមដំណើរគាត់ទៅ តើឃើញគាត់ធ្វើអ្វីខ្លះក្រៅពីនោះ?

**ឆ៖** បាទ ពេលនោះក៏គាត់បានជួបកន្លែងធ្វើការ ឧទាហរណ៍ថាកន្លែងជីកទំនប់ ជីកប្រឡាយគាត់ជួបតាមគណៈតំបន់ ប៉ុន្តែខ្ញុំអត់ដឹងការនិយាយអីទេ ខ្ញុំនៅឆ្ងាយៗពីកន្លែងគាត់និយាយគ្នាជាមួយគណៈតំបន់។ អត់ច្បាស់ទេ ព្រោះខ្ញុំហៅថា ការពារគឺនៅឆ្ងាយ ១០ម៉ែត្រ ប្រាំដណ្តប់ម៉ែត្រ។ ហើយកិច្ចការអីគាត់និយាយក្នុងគណៈតំបន់ ដូចឧទាហរណ៍ថា ណែនាំអីធ្វើអី គឺថាខ្ញុំអត់ដឹងទេបាទ។

[១១:៥៩:២៧]

**ស៖** ដើម្បីបញ្ជាក់ឲ្យច្បាស់ ដើម្បីឲ្យខ្ញុំយល់ច្បាស់លោកនោះថា ៗគាត់បានជួបជាមួយគណៈតំបន់នៅពេលនោះ ហើយលោកមិនបាននៅក្បែរ ហើយមិនបានឮថាគាត់ប្រជុំរឿងអីទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ គឺច្បាស់អ៊ីចឹងតែម្តង បាទ។

**ស៖** តើលោកនៅចាំឬទេ ថាតើកំពង់ឆ្នាំងហ្នឹងនៅកន្លែងណា ដែលលោកការពារលោក ប៉ុល ពត ទៅទស្សនកិច្ចនោះ?

**ឆ៖** បាទ គឺយូរឆ្នាំហើយ អត់ចាំ មិនដឹងកន្លែងណាៗទេបាទ។ អត់ចាំទេបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។ លោកប្រធាន ឥឡូវនេះ ខ្ញុំចង់ចូលដល់ប្រធានបទថ្មី ប៉ុន្តែខ្ញុំអាចធ្វើដូច្នោះបាន ខ្ញុំនឹងប្រើពេលវែងបាទ។

[១២:០០:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅកន្លែងការិយាល័យ ក្នុងបន្ទប់បម្រុងទុកសម្រាប់សាក្សី ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនេះវិញ នៅរសៀលនេះនៅម៉ោងកំណត់អម្បាញ់មិញនេះ គឺមួយសាមសិបនាទីរសៀល។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ កូនក្តីរបស់ខ្ញុំសូមអនុញ្ញាត តាមដាននីតិវិធី ដែលនៅសល់ក្នុងថ្ងៃនេះពីបន្ទប់តាមដានខាងក្រោម។ សូមអរគុណលោកប្រធាន។

[១២:០១:២៦]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សូមអង្គុយចុះ!

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ស្នើសុំ ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលសវនាការពេញមួយរសៀលនេះ ដោយគាត់លះសិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះសម្រេច យល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការ។

[១២:០២:០៤]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាម នូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ សម្រាបជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលនេះ ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការនេះ ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ហើយដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៣ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ចារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

សួស្តីលោក អឿន តាន សូមអរគុណដែលលោកមកសាថ្មី។ មុនពេលយើងឈប់សម្រាក

ខ្ញុំមានបំណងសួរលោកលើហេតុការណ៍ថ្មីមួយ ក៏ប៉ុន្តែក្នុងពេលសម្រាក ខ្ញុំមើលកំណត់ត្រារបស់ខ្ញុំ ខ្ញុំពិនិត្យឃើញថា ខ្ញុំត្រូវសួរបញ្ជាក់ទៅលើចំណុចពីរបី ដែលសូមឲ្យលោកធ្វើការបញ្ជាក់ទៅលើចំណុចទាំងនេះ។

លោកបានជម្រាបយើងខ្ញុំ ហើយក៏បានរៀបរាប់លម្អិតផងដែរ ដែលថាមានការប្រជុំចូលរួមពីអ្នកមកពីតំបន់ ភូមិភាគ និងស្រុក។ ហើយលោកក៏បានប្រាប់យើងខ្ញុំផងដែរ ថា នួន ជា, ប៉ុល ពត, អៀង សារី និង ខៀវ សំផន ធ្វើការរួមនៅ ក-១។

[១៣:៣៣:៣៥]

**សៈ** ខ្ញុំសូមសួរលោក ដើម្បីឲ្យប្រតិចារឹកការកត់ត្រារបស់យើងពេញលេញ។ ក្រៅពីការប្រជុំជាមួយនឹងអ្នកមកពីស្រុក តំបន់ និងភូមិភាគ ថាតើមានការប្រជុំនៅ ក-១ ផ្សេងទៀតដែរឬទេ ដែលការប្រជុំនោះ ប្រជុំជាមួយនឹងអ្នកផ្សេង ក្រៅពីអ្នកមកពីភូមិភាគ ស្រុក និងតំបន់។ តើមានដែរឬទេ ការប្រជុំផ្សេងទៀត?

**លោក អឿន តាន ៖**

**ឆៈ** បាទ ការប្រជុំផ្សេងទៀត អត់ដែលមានទេ មានតែមួយកន្លែង។

**សៈ** តើលោកចាំដែរឬទេ ថាលោកបាននិយាយប្រាប់ចៅក្រមស៊ើបអង្កេត ដែលថានៅពេលនោះ មានការប្រជុំពិសេសនៅ ក-១។ តើលោកចាំថា បានឆ្លើយប្រាប់ចៅក្រមអង្កេតលើចំណុចហ្នឹងដែរឬទេ?

**ឆៈ** បាទ ខ្ញុំដូចអត់ចាំ ភ្លេច។ យូរហើយ ដូច្នេះភ្លេច។

[១៣:៣៥:០០]

**សៈ** សូមអរគុណលោក។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន យើងខ្ញុំសូមអនុញ្ញាត។ យើងខ្ញុំស្នើសុំឲ្យសាក្សីមើលផ្នែកនៃកំណត់ត្រាសម្ភាសរបស់គាត់។ ឯកសារដែលខ្ញុំចង់បង្ហាញ គឺ E3/33។ សាក្សី ក៏មានឯកសារហ្នឹងមួយច្បាប់ផងដែរ។ ដូច្នេះយើងខ្ញុំសូមអនុញ្ញាតពីលោកប្រធានបញ្ចាំងនៅលើអេក្រង់។ ERN ដែលពាក់ព័ន្ធមានលេខ ERN ជាភាសាអង់គ្លេសគឺ 00235130, បារាំងគឺ 00235333 ដល់ 34, ខ្មែរគឺ 00231803 ទៅដល់ 804។ យើងខ្ញុំសូមអនុញ្ញាតពីលោកប្រធាន ដើម្បីបញ្ចាំងឯកសារនេះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១៣:៣៦:១០]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមឲ្យខាងសោតទស្សន៍ធ្វើការជួយបង្ហាញនៅលើអេក្រង់ផង។ ខ្ញុំសូមចាប់ផ្ដើមអាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

លោក អឿន តាន គឺខ្ញុំសូមអាន ហើយលោកមើលឯកសារនៅលើក្រដាសរបស់លោក ហើយលោកស្ដាប់ការបកប្រែទៅ។ សំណួរ ខ្ញុំសូមដកស្រង់សម្ដី៖ "សំណួរ៖ តើការប្រជុំដែលមានគ្នាក្រោម ១០នាក់នោះ មានញឹកញាប់ តើលោកៗធ្លាប់ដឹងថាមានការប្រជុំពិសេសណាមួយ ដោយឡែក ដែលគ្មានការចូលរួមពីមេដឹកនាំតំបន់ ភូមិភាគ ឬដែរឬទេ? តើធ្លាប់មានការប្រជុំដែលមានសមាជិកតិចជាង ២០នាក់ដែរឬទេ? ឆ្លើយ៖ ខ្ញុំធ្លាប់ឃើញ ពេលខ្លះការប្រជុំមានសមាជិកចូលរួមប្រហែល១០ ឬតិចជាង ១០នាក់។ ខ្ញុំចាំថាមាន អៀង សារី, នួន ជា, ខៀវ សំផន, និង ប៉ុល ពត ចូលរួមក្នុងការប្រជុំពិសេសនេះ។ ឯអ្នកចូលរួមផ្សេងទៀត មិនមានមកពីគណៈតំបន់ គណៈភូមិភាគទេ គឺសុទ្ធតែអ្នកធ្វើការនៅក្នុងក្រុងភ្នំពេញ តែខ្ញុំមិនស្គាល់ឈ្មោះ និងឋានៈគេទេ។ ការប្រជុំពិសេស កើតឡើងក្នុងករណីចាំបាច់។ ដូចជាការដោះស្រាយស្បៀង ការលើកទំនប់ជាដើម"។

[១៣:៣៧:៣២]

**ស៖** លោក អឿន តាន តើលោកនឹកឃើញថា លោកធ្លាប់បានឆ្លើយដូច្នេះដែរឬទេ? ហើយអ្វីដែលខ្ញុំបានអានអម្បាញ់មិញនេះ គឺវាឆ្លុះបញ្ចាំងនូវអ្វីដែលលោកបានឆ្លើយនាពេលនោះត្រឹមត្រូវដែរឬទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកចាំដែរឬទេ ហេតុអ្វីបានជានៅពេលនោះ លោកឆ្លើយ ហើយប្រាប់គេថា ការប្រជុំនោះ ជាការប្រជុំពិសេស?

**ឆ៖** ពេលនោះ ខ្ញុំបានឃើញ គេមកបួនដប់នាក់ មកប្រជុំ ប៉ុន្តែការប៉ាន់ស្មានថាគេប្រជុំពិសេស តែពិសេសយ៉ាងម៉េចៗ ខ្ញុំក្តាប់មិនបានដែរទេ បាទ។

**សៈ** នៅពេលដែលលោកឆ្លើយនៅក្នុងចំណុចដែលខ្ញុំទើបតែអានអម្បាញ់មិញនេះ លោកបាននិយាយថា ការប្រជុំពិសេសកើតឡើងតែក្នុងករណីចាំបាច់ ដូចជាការដោះស្រាយស្បៀង ការលើកទំនប់ជាដើម។ តើលោកដឹងចំណុចហ្នឹងតាមរបៀបណា? អ្នកណាប្រាប់លោកដែរ?

**ផៈ** បាទ ខ្ញុំពេលនោះក៏ឃើញថា ការប្រាប់ គឺតាមរយៈ ប៉ង់ ប្រាប់ថាថ្ងៃនេះគេប្រជុំពិសេសដើម្បីការកោះហៅនៃការប្រជុំ ដូចបានជម្រាបខាងដើមមាន ប៉ុល ពត, អៀង សារី, ខៀវ សំផន, នួន ជា ហើយក្រៅពីនោះ ខ្ញុំមិនចាំឈ្មោះ ដឹងអ្នកណាៗខ្លះទេ ខ្ញុំមិនចាំឈ្មោះបាទ។

[១៣:៤០:៥៤]

**សៈ** សូមអរគុណ។ នៅពេលនេះ ខ្ញុំសូមសួរទៅលើចំណុចមួយទៀត លោក អឿន តាន។ លោកបានឆ្លើយខាងដើមថា “លោកបានយកសំបុត្រពី ប៉ុល ពត និង ប៉ង់ ពី ក-១ បញ្ជូនទៅ ក-៧។ បន្ទាប់មកសំបុត្រនោះនឹងបញ្ជូនពី ក-៧ ទៅកន្លែងផ្សេងទៀត”។ តើលោកធ្លាប់យកសំបុត្រពី ក-៧ បញ្ជូនត្រឡប់មក ក-១ ដែរឬទេនៅក្នុងពេលនោះ?

**ផៈ** បាទ ពេលនោះ គឺពី ក-៧ មកជូនមក ក-១។ ខ្ញុំក្នុង ក-១ ខ្ញុំជូនឲ្យ ប៉ុល ពត បាទ។

**សៈ** សូមអរគុណ។ ខ្ញុំនឹងសួរអំពីបញ្ហាសំបុត្រនេះបន្តិចទៀត ក៏ប៉ុន្តែនៅពេលនេះ ខ្ញុំសូមសួរតើនៅ ក-១ មានប្រើប្រាស់សារទូរលេខដែរឬទេ?

**ផៈ** បាទ ក្នុង ក-១ គេមានការប្រើទូរលេខ ហើយថាទូរលេខនេះ ទូរលេខទៅណាមកណា ខ្ញុំក្តាប់មិនបានទេ ប៉ុន្តែឃើញមានទូរលេខនៅក្នុងនោះដែរបាទ។

[១៣:៤១:៤៤]

**សៈ** តើលោកអាចប្រាប់តុលាការបានដែរឬទេ ថាតើមន្ទីរដែលគេទទួល និងបញ្ជូនទូរលេខនោះនៅកន្លែងណា មន្ទីរទូរលេខនោះ?

**ផៈ** បាទ ពេលនោះគឺមានសំបុត្រពី ប៉ុល ពត បញ្ជូនតាមន៉ៃ ទូរលេខ។ ទូរលេខហ្នឹង គឺមានន៉ៃផង់ ហើយនិង យស់ អ្នកគ្រប់គ្រងបាទ ដើម្បីបញ្ជូនសារទៅក្រៅ។

**សៈ** តើ ប៉ង់ ហ្នឹងគឺជា ប៉ង់ ដែលលោកប្រាប់ខាងដើមនោះមែនដែរឬទេ? ឬក៏ ប៉ង់ ហ្នឹងខុសពី ប៉ង់ មុន?

**ផៈ** ផង់ នៅកន្លែងទូរលេខឈ្មោះ ផង់។

**សៈ** ដូច្នេះបានន័យថាជាបុគ្គលខុសគ្នា ខុសពី ប៉ង់។ ក្រោយនេះ គឺ ផង់។

**ឆ៖** វាខុសគ្នា ការគ្រប់គ្រងខាងទូរលេខមាន ផង់ ហើយ ប៉ង់ ទទួលខុសត្រូវរួមបាទ។

**ស៖** សូមអរគុណ។ លោកបានយកសំបុត្រពី ក-១ ទៅ ក-៧ តើលោកមានការទទួលខុសត្រូវយកទូរលេខទៅឲ្យគេដែរឬទេ ពីមន្ទីរដែល ផង់ ធ្វើការ? តើលោកមានតួនាទីយកទូរលេខពីមន្ទីររបស់ ផង់ ទៅឲ្យគេដែរឬទេ?

**ឆ៖** បាទ គឺពី ផង់ មានក្មេងៗ ផង់ ហ្នឹងបញ្ជូនមកខ្ញុំនៅ ក-១។ ដល់ទៅ ក-១ ខ្ញុំទទួលពីក្មេងៗ ផង់ នៅកន្លែង ផង់ ហ្នឹង ខ្ញុំបញ្ជូនឲ្យ ប៉ុល ពត បាទ។

[១៣:៤៤:២៨]

**ស៖** ដូច្នេះ ខ្ញុំនឹងព្យាយាមសង្ខេបនូវចម្លើយរបស់លោក តាមដែលអាចធ្វើទៅបាន។ ផង់ ធ្វើការនៅមន្ទីរទូរលេខ គឺគាត់មានទទួលបានទូរលេខ ហើយក្មេងៗនៅមន្ទីររបស់គាត់នោះយកទូរលេខនោះមកឲ្យលោក ហើយលោកជាអ្នកយកទូរលេខទាំងអស់នោះបញ្ជូនទៅ ប៉ុល ពត។ តើត្រឹមត្រូវដែរឬទេ អ្វីដែលខ្ញុំសង្ខេបនេះ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកចាំដែរឬទេ? តើលោកទទួលទូរលេខបញ្ជូនទៅឲ្យលោក ប៉ុល ពត នោះញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ ចួនណាមួយថ្ងៃ ពីរទៅបីដង ក្នុងមួយថ្ងៃៗបាទ។

**ស៖** នៅពេលដែលលោកបញ្ជូនទូរលេខនេះទៅ ប៉ុល ពត តើលោក ប៉ុល ពត នោះមានចាត់តាំងលោកឲ្យធ្វើការងារផ្សេងទៀតដែរឬទេ?

**ឆ៖** បាទ ពេលខ្ញុំយកសំបុត្រទៅ ប៉ុល ពត ក៏កិច្ចការងារខ្ញុំគឺថា រត់ខាងការងារបាយទឹក រត់ការងារខាងដាំបន្លែ មួយចំនួនទៀតនៅយាម។ អាហ្នឹងអីចឹង បាទ។

[១៣:៤៦:៤៨]

**ស៖** តើ ប៉ុល ពត ធ្លាប់ចាត់តាំងឲ្យលោកយកទូរលេខបញ្ជូនទៅកន្លែងផ្សេងដែរឬទេ ក្រោយពីគាត់បានមើលទូរលេខហើយនោះ គាត់មានឲ្យលោកយកទូរលេខទៅបញ្ជូន ទៅឲ្យអ្នកផ្សេងដែរឬទេ?

**ឆ៖** បាទ ធ្លាប់ជូនទៅនែ នួន ជា ធ្លាប់ជូនទៅ នួន ជា នៅ ក-៣ បាទ។

**ស៖** តើលោកធ្លាប់បញ្ជូនទូរលេខនេះទៅអ្នកផ្សេងក្រៅពី នួន ជា ដែរឬទេ?

**ឆ៖** បាទ អត់ដែលទេបាទ។

**ស៖** លោកបានលើកឡើងថា ពេលខ្លះទៅ ពី-- ក្នុងមួយថ្ងៃពីរបីដងលោកទទួលទូរលេខ ហើយបញ្ជូនទៅ ប៉ុល ពត ថាតើទូរលេខទាំងអស់ដែលលោកទទួលបាននោះ បញ្ជូនទៅ នួន ជា ទាំងអស់ ឬក៏មានខ្លះទេ ដែលមានទូរលេខតែមួយចំនួនទេ បញ្ជូនទៅ នួន ជា?

**ឆ៖** បាទ ពេលនោះ គឺ ប៉ុល ពត បានមើលហើយចប់។ ចប់ហើយបានឲ្យបញ្ជូនទៅខាង នួន ជា ទៀតបាទ។

[១៣:៤៨:៤៥]

**ស៖** អ៊ីចឹងបានន័យថា ទូរលេខទាំងអស់បានបញ្ជូនទៅ ប៉ុល ពត ក្រោយមក គឺទូរលេខទាំងអស់នោះ គឺបញ្ជូនមក នួន ជា ទៀត។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** តើលោកដឹងដែរឬទេថា មានមេដឹកនាំផ្សេងទៀតបានទទួលទូរលេខនោះ?

**ឆ៖** បាទ មេដឹកនាំផ្សេងៗ ខ្ញុំក្តាប់មិនបានទេបាទ។

**ស៖** សូមអរគុណ។ លោកបាននិយាយថា លោកយកទូរលេខពី ប៉ុល ពត ទៅឲ្យ នួន ជា តើលោកធ្លាប់យកលិខិតឆ្លើយតបពី នួន ជា ទៅឲ្យ ប៉ុល ពត វិញដែរឬទេ?

**ឆ៖** បាទ អត់ដែលទេបាទ។

[១៣:៥០:២២]

**ស៖** តើលោកយកលិខិតទាំងអស់នោះទៅឲ្យ នួន ជា នៅកន្លែងណាដែរ?

**ឆ៖** បាទ ខ្ញុំយកទៅឲ្យកន្លែង ក-៣ កន្លែងគាត់រស់នៅបាទ។

**ស៖** ខ្ញុំសួរអំពីទូរលេខដែលបញ្ជូនចេញម្តង។ តើលោកដឹងដែរឬទេ មានទូរលេខបញ្ជូនពី ប៉ុល ពត ចេញពី ក-១ ទៅ។ ដូច្នេះតើបញ្ជូនដោយរបៀបណាដែរ?

**ឆ៖** បាទ ក្នុងនោះក៏មានស្រោមសំបុត្រ គេដាក់ទៅសរសេរការខ្នង អក្សរខ្មៅ។ ជូនឲ្យអ្នកណាៗអត់ដឹងទេបាទ។ គ្រាន់តែខ្ញុំជូនពី ក-១ ទៅក-៧ បាទ។

[១៣:៥១:៥០]

**ស៖** ខ្ញុំសូមអធ្យាស្រ័យប្រហែលជាសំណួរខ្ញុំធ្វើឲ្យលោកច្រឡំ។ ខ្ញុំចង់សួរលោកអំពីទូរលេខប្រសិនបើមាន ទូរលេខដែលបញ្ជូនពី ប៉ុល ពត។ តើមានធ្លាប់ទូរលេខបញ្ជូនពី ក-១ ទៅមន្ទីររបស់ ផង់ដែរឬទេ?

**ឆ៖** បាទ ពេលនោះមានពី ប៉ុល ពត យកទៅមន្ទីរ ផង់ បាទ មាន។

**ស៖** តើលោកអាចនិយាយបញ្ជាក់បានដែរឬទេ បញ្ជូនទៅមន្ទីរ ផង់ ហ្នឹង ញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ ពេលខ្លះពីរដងទៅបីដងក្នុងមួយថ្ងៃ។ ជូនសំបុត្រនុំង ម្ដងពីរដងក្នុងមួយថ្ងៃបាទ។

**ស៖** សូមអរគុណ។ លោកបាននិយាយថា ទូរលេខដែលបញ្ជូនចូលមក ប៉ុល ពត ក្រោយមកលោកយកទៅឲ្យ នួន ជា។ អ៊ីចឹង តើលោកអាចបញ្ជាក់ដែរឬទេ លិខិតដែលបញ្ជូនទៅក-៧ បន្ទាប់មកបញ្ជូនទៅក-១។ លិខិតបញ្ជូនពីក-៧ ទៅក-១ លិខិតទាំងអស់នេះមានបញ្ជូនទៅ នួន ជា ឬទៅអ្នកណាផ្សេងដែរឬទេ?

**ឆ៖** បាទ អត់មានទេពេលនោះបាទ។

[១៣:៥៤:៣៩]

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរត្រឡប់លើចំណុចមួយចំនួនតូច ដែលលោកបានឆ្លើយនៅក្នុងថ្ងៃនេះកាលពីព្រឹកមិញ ពីខាងដើម ដើម្បីឲ្យខ្ញុំដឹងព័ត៌មានឲ្យបានច្រើនពីលោក។ លោកបាននិយាយថា នៅក្រោយពីលោកចូលបដិវត្តន៍លោកប្រគល់ជីវប្រវត្តិ ប្រវត្តិរូបរបស់លោកឲ្យគេ។ តើមានតែប្រវត្តិរូបតែម្ដងទេ ដែលលោកប្រគល់ទៅឲ្យគេ ឬក៏មានប្រវត្តិរូបដែលលោករៀបចំច្រើនដងប្រគល់ឲ្យគេ?

**ឆ៖** មានប្រវត្តិរូបតែម្ដងហ្នឹងឲ្យគេ បាទ។

**ស៖** សូមអរគុណ។ លោកក៏បានឆ្លើយប្រាប់ថា លោកធ្លាប់ឃើញទង់បដិវត្ត និងទង់យុវជនបដិវត្ត។ តើលោកអាចជម្រាបប្រាប់តុលាការដែរឬទេ លោកធ្លាប់ឃើញទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីយុវជន យុវនារីនេះនៅពេលណាដែរ?

[១៣:៥៦:១៥]

**ឆ៖** បាទ ខ្ញុំឃើញហៅ ទង់បដិវត្ត និងទស្សនាវដ្ដីក្នុងឆ្នាំ១៩៧៥, ៧៦ ខ្ញុំឃើញ។ ប៉ុន្តែន័យយ៉ាងម៉េចៗ ខ្ញុំក្ដាប់មិនបានដែរបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរសំណួរនេះនាពេលនេះ លោកបាននិយាយថា ក្រោយពីលោកចូលបដិវត្តន៍ គឺនៅពេលនោះគឺលោកចូលជាសមាជិកបក្សតែម្ដង ឬក៏នៅពេលនេះលោកចូលរួមជាមួយនឹងយុវកក តើលោក-- ក្រោយពីលោកចូលបដិវត្តន៍ហ្នឹង លោកចូលជាមួយនឹងក្រុមមួយណាដែរ?

**ឆ៖** បាទ ពេលនោះខ្ញុំចូលបដិវត្តន៍ ចូលក្រុម ប៉ង់ តែម្តង។

**ស៖** សូមអរគុណ។ តើគេមានប្រាប់ថា លោកជាសមាជិករបស់បក្សណាមួយដែរឬទេ? ឧទាហរណ៍ថា គេប្រាប់ថាលោកជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា គេមានប្រាប់ទេ?

**ឆ៖** ពេលនោះគេ-- មានគេប្រាប់ថា ខ្លួនខ្ញុំចូលសម្ព័ន្ធយុវកក ជាសមាជិករបស់នែ៎ ក្នុងសម្ព័ន្ធយុវកកហ្នឹង បាទ។

[១៣:៥៨:២៤]

**ស៖** សូមអរគុណច្រើន។ សំណួរមួយទៀត ដែលខ្ញុំចង់សួរលោកផងដែរ គឺពាក់ព័ន្ធនឹងរយៈពេលមុនឆ្នាំ-- មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥។ លោកបាននិយាយថា ប៉ុល ពត, នួន ជា និង ខៀវ សំផន បានទៅភ្នំពេញជាមួយគ្នា។ តើលោកដឹងថា ពួកគាត់ទាំងបីនេះទៅភ្នំពេញជាមួយគ្នានេះតាមនរណាដែរ? ដោយរបៀបណាដែរ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយថា ព្រោះពេលនោះខ្ញុំមិនដឹង មិនដឹងតាមរបៀបណាទេ តាមឡាន ឬមួយតាមអីខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំនៅក្រោយបាទ។

**ស៖** សូមអរគុណ។ លោកថា លោកទៅតាមក្រោយនៅកំពង់ចាមនោះ ក៏ប៉ុន្តែលោកដឹងពួកគាត់ទាំងបីនេះទៅភ្នំពេញ។ ក៏ប៉ុន្តែលោកដឹងថា ពួកគាត់ទាំងនេះទៅភ្នំពេញហ្នឹងដោយរបៀបណា? គឺអ្នកនរណាប្រាប់លោក?

**ឆ៖** ពេលនោះ គឺ ប៉ង់។ ប៉ង់ ប្រាប់ខ្ញុំថា ប៉ុល ពត, នួន ជា, ខៀវ សំផន ថាទៅភ្នំពេញ ក៏ក្នុងនោះមាន ប៉ង់ ទៅដែរបាទ។ មាន ប៉ង់ ប្រាប់ខ្ញុំអ៊ីចឹងបាទ។

[១៤:០០:០៧]

**ស៖** សូមអរគុណ។ គឺយើងនិយាយអំពី ប៉ង់ ខ្ញុំជឿថា ប៉ង់ ទទួលខុសត្រូវរួមលើមន្ទីរ៨៧០។ តើលោកធ្លាប់ឮឈ្មោះបុរសម្នាក់ហៅ សឿ វ៉ាស៊ី-- បុរសម្នាក់ឈ្មោះ សឿ វ៉ាស៊ី ហៅឌឿន ដែរឬទេ? តើលោកធ្លាប់ទេ ធ្លាប់ស្គាល់បុគ្គលហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេបាទ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងត្រឡប់មកនិយាយពី ប៉ង់ វិញ។ ខ្ញុំគិតថា លោកបានប្រាប់យើងពីព្រឹកនេះថា បានចូលរួមនៅក្នុងកិច្ចប្រជុំជាមួយនឹង ប៉ង់។ តើលោកអាចប្រាប់បានដែរឬទេ ថាតើកិច្ចប្រជុំជាមួយ ប៉ង់ ហ្នឹងធ្វើឡើងញឹកញាប់ប៉ុនណាដែរ?

**ឆ៖** បាទ ពេលនោះក៏ ប៉ង់ បានហៅប្រជុំណែនាំអីទៅ ក៏ ខ្ញុំក៏ប្រជុំតាមក្រុមតាមគេទៅ ព្រោះក្រុមខ្ញុំមានគ្នា១០នាក់។ ប៉ង់ ថាឥឡូវយើងប្រជុំក្នុងក្រុម ដាស់តឿនពីបញ្ហាការយាមកាម ដាស់តឿនពីបញ្ហាការដាំបន្លែ ឧបត្ថម្ភខ្លួន។ អាហ្នឹងគឺជាមតិរបស់ ប៉ង់ ណែនាំអីចឹងបាទ។

**ស៖** តើលោកអាចប្រាប់បានដែរឬទេ ថាតើអ្នកណាខ្លះដែលចូលរួមនៅក្នុងកិច្ចប្រជុំជាមួយ ប៉ង់ នោះ ក្រៅពីលោក តើមានអ្នកណាខ្លះ?

[១៤:០២:២០]

**ឆ៖** ពេលនោះគឺមានក្រុមខ្ញុំ ហើយនិងក្រុមប្រជុំ-- ក្រុមការពារខាងក្រៅ ដើម្បីចូលរួមប្រជុំជាមួយ ប៉ង់ ផ្ទាល់តែម្តងបាទ។

**ស៖** ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ទៅលើបញ្ហានេះ។ ថាតើមាន១តែប្រធានផ្នែក ឬមួយក៏មានទាំងបុគ្គលិកទាំងអស់ ដែលធ្វើការនៅក្នុង និងនៅជុំវិញ ក-១? តើមានតែប្រធានទេដែលចូលរួម ឬក៏មានសមាជិកផ្សេងទៀតដែរ?

**ឆ៖** បាទ ក្នុងនោះមានប្រធានផង មានសមាជិកផង ដើម្បីចូលរួមក្នុងការជុំជាមួយ ប៉ង់ ផ្ទាល់។

**ស៖** បន្ទាប់ពីប្រជុំដែលលោកបានទទួលការណែនាំនោះ ថាតើលោកមានតួនាទីក្នុងការផ្សព្វ-ផ្សាយនូវការណែនាំហ្នឹងទៅដល់អ្នកក្រោមបង្គាប់ ឬមួយក៏អ្នកក្រោមបង្គាប់លោកហ្នឹងគេបានចូលរួមប្រជុំជាមួយដែរ?

**ឆ៖** បាទ ពេលនោះគឺក្រោមបង្គាប់របស់ខ្ញុំ គឺថាចូលរួមប្រជុំទាំងអស់គ្នាបាទ។

[១៤:០៤:០៨]

**ស៖** តើមានប្រធានបទអ្វីខ្លះ ដែលពិភាក្សានៅក្នុងកិច្ចប្រជុំហ្នឹង ក្រៅពីការពិភាក្សាអំពីការណែនាំពីការងារប្រចាំថ្ងៃ? តើមានបញ្ហាផ្សេងៗ តើមានបញ្ហាផ្សេងៗទៀតលើកយកមកពិភាក្សាដែរឬទេនៅក្នុងកិច្ចប្រជុំនោះ?

**ឆ៖** បាទ ក្នុងពេលនោះអត់មានទេ ក្រៅពីការប្រជុំ មាន-- ការមានមតិពី ប៉ង់ ហើយក្រៅពីនេះអត់មានទៀតទេបាទ។ មានតែ ប៉ង់ អ្នកណែនាំការប្រជុំបាទ។

**ស៖** ក្នុងនាមជាប្រធានកងការពារ ដែលមានអ្នកក្រោមបង្គាប់ជាងដប់នាក់ ថាតើលោកមានធ្លាប់ទទួលការណែនាំពីការប្រជុំ ឬក៏ពីកន្លែងណាផ្សេងទៀតទេ ទាក់ទងនឹងការចាត់ចែង ឬក៏ការដឹកនាំកងការពារនោះ?

**ឆ៖** បាទ ពេលនោះគឺមានតែម្នាក់គត់គឺ ប៉ង់ ក្រៅពីហ្នឹងអត់មានទេ មានតែ ប៉ង់ ផ្ទាល់តែម្តង បាទ ណែនាំបាទ។

**ស៖** តើលោកចង់និយាយថា ប៉ង់ គឺជាអ្នកផ្តល់យោបល់ ឬក៏ជាអ្នកផ្តល់ការណែនាំ ពាក់ព័ន្ធទៅនឹងការការពារ ឬក៏សន្តិសុខហ្នឹង។ តើលោកចង់មានន័យបែបនេះមែនទេ?

**ឆ៖** បាទលោក ខ្ញុំមិនច្បាស់ទេ សូមបញ្ជាក់ម្តងទៀតបាទ។

[១៤:០៥:៥៨]

**ស៖** ខ្ញុំចង់ដឹងថា ថាតើលោកទទួលបានការណែនាំ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសន្តិសុខ នៅ ក-១ ដោយសារតែលោកជាអ្នកគ្រប់គ្រង ទៅលើកងការពារផ្ទៃខាងក្នុងនៅក-១។ អ្វីដែលខ្ញុំចង់សួរគឺថា តើ ប៉ង់ គឺជាអ្នកផ្តល់ការណែនាំ ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសន្តិសុខ តើមែនទេ?

**ឆ៖** បាទ គឺពិតប្រាកដអ៊ីចឹងដែរបាទ។

**ស៖** តាមដែលលោកចាំ ថាតើធ្លាប់មានបុគ្គលិកណាមួយធ្វើឲ្យខូចខាត ឬក៏ធ្វើឲ្យប៉ះពាល់ដល់បញ្ហាសុវត្ថិភាព ឬក៏បញ្ហាសន្តិសុខនៅ ក-១ ដែរឬទេ?

**ឆ៖** បាទ កន្លែងខ្ញុំអត់មានទេបាទ។

**ស៖** តើលោកអាចប្រាប់បានដែរឬទេ ប្រសិនបើលោកចាំ តើមានអ្វីកើតឡើងចំពោះ ប៉ង់?

**ឆ៖** បាទ ពេលនោះក៏ខ្ញុំក្រោយមកគឺថា ខ្ញុំនៅកន្លែងក-១ នៅឆ្នាំណាខ្ញុំអត់ចាំ តែយូរៗទៅបាត់ ប៉ង់ ខ្ញុំផ្ទាល់ចេះតែឆ្ងល់ថា ប៉ង់ ទៅអ៊ីចេះ? ចេះតែមើលផ្លូវជាប់ ពីរថ្ងៃទៅបីថ្ងៃ បួនថ្ងៃទៅបួនថ្ងៃ អត់ឃើញ ក៏ឆ្ងល់តែម្នាក់ឯងទេ អត់ប្រាប់គេទេបាទ។

[១៤:០៨:២២]

**ស៖** តើលោកមានអារម្មណ៍យ៉ាងម៉េចដែរ បន្ទាប់ពី ប៉ង់ បាត់ខ្លួនទៅ?

**ឆ៖** ខ្ញុំមានអារម្មណ៍តូចមួយដែរ ក្នុងនាមខ្ញុំនៅក្នុងក-១ ខ្ញុំមានអារម្មណ៍ត្រង់ថា មិនដឹងជាយ៉ាងម៉េចទេ បាត់អ្នកដឹកនាំក្នុងគណៈ៨៧០ ចេះៗតែសង្ស័យខ្លួនឯងខ្លាច បាទខ្លាច។ ខ្លាចត្រង់ថា បាត់បីទៅបួនថ្ងៃស្ងាត់ឈឹងអត់ឃើញ អត់ឮដំណឹង ដល់អ៊ីចឹងខ្លួនចេះតែភ័យខ្លាចដែរ ចេះតែទ្រាំធ្វើការធ្វើងារឲ្យល្អនឹងគេនឹងឯងតទៅទៀត បាទ។

**ស៖** ថាតើមានហេតុផលអ្វីដែលលោកភ័យខ្លាច តើលោកភ័យខ្លាចហេតុ-- តើហេតុអ្វីបានលោកភ័យខ្លាច នៅពេលដែលមានការបាត់ខ្លួន ប៉ង់ នោះ?

**ឆ៖** ពេលនោះខ្ញុំខ្លាចត្រង់ថា បើ ប៉ង់ បាត់មុខជាខ្ញុំបាត់ដែរ ខ្ញុំខ្លាចអ៊ីចឹងបាទ។ ដល់អ៊ីចឹង ខំធ្វើការងារក្នុងក-១ហ្នឹង។ ខំធ្វើការត្រង់ថា ធ្វើនេះធ្វើនោះបោកខោអាវ អ្នកដឹកនាំ ធ្វើដាំបន្លែដាំបង្ការ ធម្មតាដូចគេដូចឯងអ៊ីចឹងទៅ អាហ្នឹងបាទ។

[១៤:១០:២៥]

**សៈ** តើលោកមានដែលពិភាក្សាអំពីអារម្មណ៍ភ័យខ្លាច ឬក៏អំពីអារម្មណ៍របស់លោកហ្នឹងជាមួយអ្នកដទៃ ឬក៏ជាមួយនឹងអ្នកធ្វើការជាមួយលោកដែរឬទេ?

**ឆ៖** បាទ ពេលនោះ ក៏អត់ប៊ានិយាយទេ គឺនៅស្ងាត់ម្នាក់ឯង មិនឲ្យគេដឹង មិនឲ្យគេឮ ព្រោះខ្លាចដែរ បាទ។

**សៈ** ខ្ញុំចង់បញ្ជាក់ទៅលើអង្គហេតុមួយលោកសាក្សី។ ប៉ុន្តែមុនខ្ញុំបញ្ជាក់ ខ្ញុំសូមសួរសំណួរមួយសិនទៅលោក។ ក្រោយពីការបាត់ខ្លួន ប៉ង់ នោះ តើមានអ្នកផ្សេងទៀត នៅក-១ ឬក៏នៅអង្គភាពនានានៅជុំវិញ ក-១ ហ្នឹង តើមានអ្នកណាបាត់ខ្លួនទៀតដែរឬទេ ក្រៅពី ប៉ង់?

**ឆ៖** បាទ ក្រៅពី ប៉ង់ បាត់ខ្លួន ក្នុងអង្គភាពក-១ ក្តី ឬក៏អង្គភាពផ្សេងៗក្តី ក៏មិនដែលឃើញ មិនដែលមានទេ បាទ។

[១៤:១១:៥២]

**សៈ** នៅពេលដែលសហការីខ្ញុំសួរលោកនៅពេលព្រឹកនេះ លោកនិយាយថា មុនឆ្នាំ១៩៧៥ ប្រសិនបើមានអ្នកណាម្នាក់ធ្វើអ្វីដែលខុស ដូចជាបំផ្លាញព្រឡសម្បត្តិ ឬក៏ធ្វើឲ្យខូចខាតសត្វពាហនៈ ពួកនឹងត្រូវបញ្ជូនទៅឲ្យរៀនសូត្រ។ តើបញ្ហានេះ មានកើតឡើងទេនៅក្រោយឆ្នាំ១៩៧៥?

**ឆ៖** បាទ នៅពេលនោះ គឺតួអង្គនៅកន្លែងខ្ញុំនៅ ទោះបីនៃ មានការខុសត្រូវ ធំក្តី តូចក្តី ខ្លួនខ្ញុំផ្ទាល់ គឺខំអប់រំណែនាំ ធ្វើម៉េចឲ្យល្អ កុំប៉ះពាល់រឿងទ្រព្យសម្បត្តិ កុំប៉ះពាល់ជាមាន់ទា។ បើថាប៉ះពាល់អ៊ីចឹង ត្រូវសងប្រជាជនវិញ។ ដូច្នេះ គឺថាការមតិរបស់ខ្ញុំ គឺមានការអប់រំខាងក្រោមៗ ដើម្បីឲ្យគេយល់ថែមទៀតបាទ។

[១៤:១៣:៣១]

**សៈ** នៅពេលដែលលោកកាន់តួនាទី គឺតួនាទីជាមេសន្តិសុខ១០នាក់នោះ ១០រូបនោះ ថាតើលោកអាចបញ្ជាក់ច្បាស់ដែរឬទេ ថាតើលោកទទួលតួនាទីហ្នឹង នៅថ្ងៃខែណា? ប្រសិនបើលោកចាំសូមលោកអាច-- សូមលោកជម្រាបបានទេ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេលោកបាទ ព្រោះយូរឆ្នាំ យូរខែហើយ បាទ។ បើខ្ញុំចាំ ខ្ញុំអាចបញ្ជាក់ជូនអត់អីទេ បាទ ប៉ុន្តែយូរហើយ ដូចថាខ្ញុំមិនចាំ។

**ស៖** សូមអរគុណលោក។ ថាតើមានអ្នកណាម្នាក់ជាមេកងការពារ១០នាក់ហ្នឹង មុនពេលដែលលោកទទួលតួនាទីនោះដែរទេ តើមានអ្នកផ្សេងកាន់តួនាទីហ្នឹង មុនលោកចូលទេ?

[១៤:១៤:៤៧]

**ឆ៖** មុនចូល-- បាទ លោក ខ្ញុំបញ្ហានេះ ក្តាប់មិនច្បាស់ទេបាទ។ សូមបញ្ជាក់ម្តងទៀតបាទ។

**ស៖** លោកបានប្រាប់យើងថា លោកអត់ចាំនៅពេលវេលា ឬក៏ថ្ងៃខែដែលលោកបានតែងតាំងជាប្រធានក្រុមកងការពារចំនួន១០នាក់នោះ។ ខ្ញុំគ្រាន់តែចង់ដឹងថា មុនពេលដែលគេតែងតាំងលោកទៅកាន់តួនាទីហ្នឹង ថាតើមានបុគ្គលណាដែលកាន់តួនាទីនេះ មុនពេលដែលលោកចូលកាន់តួនាទីនេះទេ?

**ឆ៖** បាទ មុនអត់មានទេ មានតែខ្ញុំបាទ។ កាន់ក្រុមកងការពារជាមួយគ្នាហ្នឹង។

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន ខ្ញុំចង់បញ្ជាក់ថា ខ្ញុំមាននូវចម្លើយរបស់សាក្សីរូបផ្សេង ដែលពណ៌នាអំពីស្ថានភាពនៅ ក-១។ ហើយបានបញ្ជាក់អំពីលោក អឿន តាន ផងដែរ។ ហើយតាមការអនុវត្តកាលពីម្សិលមិញនោះ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមបង្ហាញនូវចម្លើយរបស់សាក្សីនោះ គឺដែលលោកយើងបានធ្វើការកោសលុបរួចទៅហើយចម្លើយនោះ គឺសាក្សី TCW-620។ ហើយសាក្សីហ្នឹងត្រូវបានចុះបញ្ជីនៅក្នុងសាក្សីដែលត្រូវកោះហៅ។ ខ្ញុំចង់ឲ្យមានការយុត្តិធម៌ចំពោះសាក្សីនេះ ហើយខ្ញុំចង់បង្ហាញនូវចម្លើយសាក្សីរូបនោះ ដើម្បីឲ្យសាក្សី អឿន តាន គាត់អាចពិនិត្យមើលនៅថ្ងៃនេះ។

[១៤:១៧:១៧]

ចម្លើយសារភាពនេះគឺ D91/9 ហើយឯកសារមួយនេះមានលេខ E3/104។ ហើយខ្ញុំ ដូចខ្ញុំជម្រាបរួចទៅហើយ គឺខ្ញុំបានធ្វើការកោសលុបរួចទៅហើយទៅលើឯកសារនេះ។ ហើយខ្ញុំគិតថា ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំនឹងបន្តទៅមុខ។

[១៤:១៨:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២១:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យមេធាវីប្រើប្រាស់ឯកសារនេះក្នុងការសួរ តាំងសំណួរដេញដោលចំពោះសាក្សី ប៉ុន្តែសុំឲ្យតំណាងសហព្រះរាជអាជ្ញាប្រគល់នូវឯកសារជាក្រដាសដែលមានឈ្មោះសាក្សីនៅ ដែលផ្តល់សក្ខីកម្មនៅក្នុងឯកសារ E3/104 នេះជូនទៅមេធាវីប្រឹក្សាសាក្សី ដើម្បីឲ្យគាត់អានដោយខ្សឹបប្រាប់ជូនទៅលោកសាក្សី ដើម្បីឲ្យគាត់យល់អំពីមនុស្សណាដែលផ្តល់សក្ខីកម្មដូច្នេះ។ ហើយសាក្សី គឺមិនត្រូវប្រើប្រាស់នូវឈ្មោះសាក្សី ដែលមេធាវីប្រាប់លោកទេ គ្រាន់ឲ្យដឹងខ្លឹមសារ និងមនុស្សបុគ្គលដែលនិយាយដូច្នេះតែប៉ុណ្ណោះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំអាចផ្តល់ការជួយដល់មេធាវីប្រឹក្សា ដើម្បីឲ្យមើលទៅលើទំព័រណាដែលពាក់ព័ន្ធ។ លោកមេធាវីប្រឹក្សា ផ្នែកដែលយើងៗ ចង់ដឹងស្រង់ គឺនៅខ្មែរ ERN ដែលមានលេខ 00204053 ហើយខ្ញុំគិតថាខាងមន្ត្រីតុលាការអាចជួយដល់លោកមេធាវីក្នុងការកំណត់នូវទំព័រមួយនេះ។

ហើយលោកមេធាវីប្រឹក្សា អាចធ្វើការពិនិត្យ ហើយយើងនឹងបន្តនៅពេលបន្តិចទៀត។

[១៤:២៣:៤១]

**ប្រធានអង្គជំនុំ៖**

មានៗឈ្មោះដែលអ្នកផ្តល់សក្ខីកម្មទេមេធាវី ឯកសារនុ៎ង?

**លោក សេង រិទ្ធី៖**

សូមគោរពលោកប្រធាន ដូចអត់ឃើញមានឈ្មោះទេ ព្រោះថាឯកសារហ្នឹងបានបិទឈ្មោះអ្នកផ្តល់សក្ខីកម្មទាំងអស់បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះឲ្យតំណាងសហព្រះរាជអាជ្ញា ផ្តល់ឯកសារដែលមានឈ្មោះអ្នកផ្តល់សក្ខីកម្ម ទៅឲ្យលោកមេធាវី។ មេធាវីហ្នឹងខ្សឹបប្រាប់ទៅសាក្សី ដើម្បីឲ្យសាក្សីយល់ថាចម្លើយហ្នឹង គឺមនុស្សហ្នឹងដែលគាត់ធ្លាប់ដឹងពីមុនមក ប៉ុន្តែពេលគាត់ឆ្លើយហ្នឹង គឺសាក្សីមិនត្រូវឆ្លើយបញ្ចេញឈ្មោះសាក្សីពាក់ព័ន្ធទៅដល់ឈ្មោះសាក្សីដែលរក្សាការសម្ងាត់នេះទេ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំក៏មានឯកសារមួយទៀតដែល ដែលមិនមានការកោស។ ឥឡូវ

ខ្ញុំសូមប្រគល់ជូន។

[១៤:២៥:០៩]

**ប្រធានអង្គជំនុំ៖**

មេធាវីប្រឹក្សាសាក្សី គ្រាន់តែលោកមើល ហើយអានឈ្មោះៗអ្នកដែលផ្ដល់សក្ខីកម្មនៅក្នុងឯកសារហ្នឹងថា គាត់ឈ្មោះអី? ហើយថាគាត់ធ្លាប់ស្គាល់ពីមុនមកដែរឬទេ? ដើម្បីឲ្យគាត់មានចំណាប់អារម្មណ៍នៅ-- សួរនៅខ្លឹមសារពាក់ព័ន្ធហ្នឹងការផ្ដល់សក្ខីកម្មរបស់សាក្សីរូបនោះ គាត់នឹងអាចយល់បានថា អ្នកណាជាអ្នកនិយាយដូច្នេះ។ តើគាត់ហ្នឹងស្គាល់មនុស្សហ្នឹងទេពីមុនមក ពីព្រោះម្សិលមិញយើងបានធ្វើរបៀបនេះហើយ ប៉ុន្តែសាក្សីមិនបានស្គាល់ទេ ដោយសារមូលហេតុយើងបិទអត្តសញ្ញាណអ្នកផ្ដល់សក្ខីកម្ម។ អ៊ីចឹងហើយបានឲ្យលោកជម្រាបថា ខ្លឹមសារនេះគឺសាក្សីឈ្មោះអី? ឲ្យដឹងតែពីរនាក់ហ្នឹងទៅ ហើយគាត់ចាប់អារម្មណ៍ថា តើមនុស្សហ្នឹងគាត់ស្គាល់ពីមុនដែរឬទេ? ហើយគាត់ជឿទេ ការផ្ដល់សក្ខីកម្មអ៊ីចឹង តើវាមានប្រយោជន៍ក៏ជាការពិត ឬមិនពិតយ៉ាងដូចម្ដេច? តែប៉ុណ្ណឹងទេ។

[១៤:២៦:២៣]

សូមអញ្ជើញ!

**លោក អាកទូរ វែកគែន៖**

បាទ លោកប្រធាន តើយើងអាច-- ខ្ញុំសូមទំព័រ ហើយនិងកថាខណ្ឌ នឹងអានបន្តិចទៀតទេ ជាសំណៅជាភាសាផ្សេងៗលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមបន្ត-- សូមផ្ដល់លេខ ERN ទាំងបីភាសាជូនដល់ភាគី និងអង្គជំនុំជម្រះ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ផ្នែកដែលខ្ញុំចង់អាននេះ គឺភាសាអង់គ្លេសមានលេខ 00204061 ហើយនិងទំព័របន្តបន្ទាប់ ហើយជាភាសាបារាំងគឺមានលេខ 00524374 និងទំព័របន្តបន្ទាប់។ ហើយភាសាខ្មែរដូចខ្ញុំបានបញ្ជាក់ពីខាងដើមរួចមកហើយគឺ 00204053។

[១៤:២៧:៥១]

**ប្រធានអង្គជំនុំ៖**

អញ្ជើញដំណើរការតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោក តាន ខ្ញុំចង់បង្ហាញ ការពិតមិនមែនខ្ញុំចង់ចោទប្រកាន់លោកនោះទេ។ ខ្ញុំមិនមែនលើកមកដើម្បីចោទប្រកាន់លោក គឺខ្ញុំគ្រាន់តែចង់លើកឡើង ព្រោះថាអាចនឹងមានអ្នកដទៃគេនឹងសួរលោកទៅលើបញ្ហានេះ ដូច្នេះខ្ញុំផ្តល់ឱកាសនេះដើម្បីឲ្យលោកធ្វើការឆ្លើយតប។ បុគ្គលរូបនេះដែលគាត់បំពេញការងារនៅក្នុងផ្នែកសន្តិសុខផងដែរ។ គាត់បាននិយាយដូចតទៅនេះ៖ “សំណួរ៖ តើលោកធ្លាប់ឮពីការៗចាប់ខ្លួនមនុស្សដែលបាត់-- ហើយឆ្លើយថា៖ ខ្ញុំបានឮអំពីបញ្ហានេះ ប៉ុន្តែរឿងនេះ ខ្ញុំធ្លាប់ឮដែរតែអ្នកដែលគេចោទនៅជំនាន់នោះច្រើនតែអ្នកដែលមានតួនាទីធំៗដូចជា សែម ដែលជាប្រធាន ក-១ មុន តាន ហៅ ខៀវ។ ហើយតាន ហៅ ខៀវ នេះហើយ ជាមនុស្សប្រកាសថា សែម នេះក្បត់”។ ខ្ញុំសូមបញ្ចប់ត្រឹមនេះ។

[១៤:២៩:២០]

ហើយលោក តាន ដំបូងបំផុតនេះ ដោយមិនៗបញ្ជាក់នៅឈ្មោះមនុស្សដែលនិយាយហ្នឹង តើលោកស្គាល់ទេ តើបុគ្គលនេះគឺជា-- តើលោកស្គាល់អ្នក-- សាក្សីដែលផ្តល់ចម្លើយនេះទេ?

**លោក អឿន តាន៖**

**ឆ៖** បាទ អត់ស្គាល់។

**ស៖** ហើយអ្វីដែលបុគ្គលនេះបាននិយាយ តើជាចម្លើយដែលត្រឹមត្រូវ ដែលថាបុគ្គលម្នាក់ឈ្មោះ សែម ដែលជាប្រធានមុនលោកនោះត្រូវបានគេដកចេញដោយសារតែជននេះក្បត់។ តើវាជាការត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ។

សូមអញ្ជើញមេធាវី!

**លោក អាង ឧត្តម៖**

សូមគោរពៗលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម មុននឹងលើកឯកសារនេះបានស្តាប់ឮលោកចៅក្រមសួរសាក្សី ហើយសួរមេធាវីប្រឹក្សាឲ្យបញ្ជាក់ថា ស្គាល់ឈ្មោះអ្នកផ្តល់សក្ខីកម្មក្នុង

ឯកសារនេះទេ ហើយសាក្សីឆ្លើយថា អត់ស្គាល់ទេ។ ក្នុងករណីនេះ តើយើងត្រូវអនុវត្តបញ្ញត្តិមួយណាឲ្យត្រូវ? តាមខ្ញុំបាទយល់ ថាក្នុងករណីដែលសាក្សីនេះមិនស្គាល់ម្ចាស់សាក្សីក្នុងឯកសារនេះទេ យើងគួរតែអនុវត្តបញ្ញត្តិដែលចែងមុនៗថា គួរដកឯកសារនេះ ទោះយ៉ាងណាគួរដកឯកសារនេះចេញពីសាក្សី។ ហើយសហព្រះរាជអាជ្ញានៅមានសិទ្ធិសួរសំណួរផ្សេង ដែលមិនចំសំណួរដែលមានលក្ខណៈបែបនេះ គឺសំណួរដទៃផ្សេងវិញ។ តើយើងគួរអនុវត្តបញ្ញត្តិដូចមានចែងពីមុនឬអត់? សូមអរគុណ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣២:១២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ សេចក្តីជំទាស់របស់លោកមេធាវីជាតិការពារក្តីលោក អៀង សារី មិនត្រឹមត្រូវទេ បរិបទនេះវាដោយឡែកពីបរិបទដែលយើង អង្គជំនុំជម្រះបានសម្រេចពេលមុនៗ ហើយឯកសារដែលឲ្យអង្គជំនុំជម្រះជូនទៅនោះ គឺជូនទៅក្រុមមេធាវីប្រឹក្សាសាក្សីប៉ុណ្ណោះ ដោយសារសាក្សីបានបង្ហាញហើយថា គាត់មានកម្រិតណាស់ក្នុងការចេះអានភាសាខ្មែរនេះ។

សូមអញ្ជើញបន្តសំណួរ!

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។

[១៤:៣២:៥៨]

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** លោក អឿន តាន ដូចដែលខ្ញុំបានជម្រាប អ្វីដែលខ្ញុំចង់សួរលោកនោះគឺថា តើចម្លើយនោះត្រឹមត្រូវដែរឬទេ? ខ្ញុំគ្រាន់តែចង់ដឹងថាមានបុគ្គលម្នាក់ឈ្មោះ សែម ដែលធ្លាប់ជាប្រធាន ក-១ ហើយត្រូវបានគេដកចេញដោយគេចោទគាត់ថាជាជនក្បត់?

**លោក អឿន តាន៖**

**ឆ៖** បាទ ពេលនោះគឺត្រឹមត្រូវដូចលោកបានបញ្ជាក់អំមិញហើយបាទ។

**ស៖** តើលោកចាំដែរឬទេ បុគ្គលហ្នឹងឈ្មោះពេញឈ្មោះអីដែរ? មិនមែនសាក្សីទេ គឺ សែម នេះមានឈ្មោះពេញឈ្មោះអ្វីដែរ?

**ឆ៖** អត់ស្គាល់ផង។ បាទ អត់ស្គាល់បាទ។

[១៤:៣៤:១៨]

**លោក អាប់ឌុលឡាក់ ថាវីក៖**

លោកប្រធាន ដើម្បីជាកំណត់ត្រាមានបុគ្គលម្នាក់ទំនងជាស៊ីសង្វាក់នឹងបុគ្គលរូបនេះ ឈ្មោះនោះឃើញមាននៅក្នុងបញ្ជីអ្នកទោសស-២១ ដែលហៅថា “កែប ស ហៅ សែម” ត្រង់លេខ៣៣៩១ នៅក្នុងបញ្ជីអ្នកទោសដែលបានកែប្រែ ឯកសារនោះគឺលេខ២ D288/6.68។

ខ្ញុំសូមអរគុណលោក អឿន តាន ដែលលលោកឆ្លើយដោយស្មោះត្រង់។ ខ្ញុំគ្រាន់តែចង់សួរសំណួរមួយសំណួរទៀត ដែលវាពាក់ព័ន្ធទៅនឹងចម្លើយដែលខ្ញុំយកមកសួរលោកនេះ។ លោកបាននិយាយប្រាប់យើងខ្ញុំថា លោកអប់រំអ្នកដែលប្រព្រឹត្តខុស នៅក្នុងឯកសារនេះមានចំណុចមួយដែលខ្ញុំសូមអានជូនលោក។ មុនពេលដែលខ្ញុំអាន នោះគឺខ្ញុំសូមសួរលោក ថាតើលោកធ្លាប់មានដកអ្នកណាចេញពីអង្គភាពរបស់លោក ហើយចាត់តាំងទៅកន្លែងដែរឬទេ បើសិនអ្នកទាំងអស់នោះធ្វើខុស?

**ឆ៖** បាទ បញ្ហាហ្នឹងដូចបានបញ្ជាក់ខ្លះមកហើយថា បើសិនមានការខុសឆ្គង ឬមួយក៏ប៉ះពាល់អីមួយ ដូចថាខ្លួនខ្ញុំ គឺថាយកមកអប់រំ អត់ដកទៅណាមកណាទេ គឺថាយកមកអប់រំ ណែនាំឲ្យយល់ក្នុងការរស់នៅប្រចាំថ្ងៃ បាទ។

[១៤:៣៦:២៤]

**ស៖** យើងបានពិភាក្សាលើករណី សែម។ តើឲ្យលោកចាំដែរឬទេ ក្រៅពី សែម មានអ្នកផ្សេងដែលបាត់ខ្លួន ឬត្រូវបានគេដកចេញពីមន្ទីរក-១ និងទីតាំងជុំវិញ ក-១ ដែរឬទេ?

**ឆ៖** បាទ អត់ដែលមានទេបាទ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

យើងសល់ពេលតែបន្តិចតែប៉ុណ្ណោះមុនពេលឈប់សម្រាក។ ដូច្នេះ ខ្ញុំសូមសួរសំណួរមួយចុងក្រោយ ត្រង់អត្ថបទនេះដែលលោកកំពុងពិនិត្យ ដើម្បីឲ្យប្រតិចារឹកយើងពេញលេញលោកប្រធាន។ ប្រសិនបើខ្ញុំសូមចូលទៅដល់ឯកសារលេខ E3/104 វិញ គឺERN ជាភាសាបារាំង គឺ 00524374, ខ្មែរ គឺ 00204053, អង់គ្លេសគឺ 00204061។ ដូច្នេះ លោកប្រធាន ខ្ញុំសូមអនុញ្ញាត ហើយធ្វើ-- ឲ្យខ្ញុំបានបង្ហាញអត្ថបទនេះជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកប្រធាន-- លោក អឿន តាន គឺខ្ញុំសូមអានដូចតទៅ៖ "តើមានមនុស្សបាត់ពីអង្គភាពរបស់លោកដែរឬទេ? ហើយតើលោកមានការភ័យខ្លាចដែរឬទេ? ក្នុងអង្គភាពខ្ញុំមានការដកមនុស្សជាច្រើនដែរ គឺ តាន និង សុត អ្នកសម្រេចដក ប្រសិនបើធ្វើខុស ហើយគេប្រាប់ថាឲ្យទៅធ្វើការនៅកន្លែងផ្សេង ដូចជានៅតាមរោងចក្រ ក្រសួង ឯមនុស្សមួយចំនួនដែលគេបានដកនោះ ខ្ញុំបានជួបញឹកញាប់ដែរ ហើយចំពោះខ្ញុំមិនមានការភ័យខ្លាចការចាប់ខ្លួនទេ"។

លោក តាន ដូចដែលលោកបានឃើញហើយ គេមិនបានចោទលោកថា ធ្វើខុសនោះទេ ក៏ប៉ុន្តែខ្ញុំចង់សួរបញ្ជាក់ឲ្យបានច្បាស់ សាក្សីនេះបាន-- ហាក់ដូចជាបានឆ្លើយថា លោកជាអ្នកចាត់តាំងបុគ្គលិកទៅធ្វើការនៅតាមរោងចក្រ ឬក្រសួង តាមអ្វីដែលខ្ញុំអាននៅក្នុងចម្លើយនេះ។ តើត្រឹមត្រូវដែរឬទេ?

[១៤:៣៩:០៩]

**លោក អឿន តាន៖**

**ឆ៖** បាទ ពេលនោះខ្ញុំក្តាប់មិនបានទេ គឺព្រោះន៎ែ ដូចបញ្ជាក់ខាងដើមថាខ្លួនខ្ញុំផ្ទាល់ ខ្ញុំមិនដែលចាត់ចែងទៅតាមរោងចក្រ ឬទៅតាមកន្លែងផ្សេងៗទេ។ ព្រោះការងារគឺថា ខ្ញុំផ្នែកការពារនោះទេ ការចាត់ចែងស្រេចតែខាងលើ ដូចជា ប៉ង់ អាហ្វឹង ដូចជា ប៉ង់ អ៊ីចឹង។ ដូច្នេះនៅក្រោមការដឹកនាំរបស់ ប៉ង់ ខ្ញុំៗផ្ទាល់ស្ថិតក្រោមការដឹកនាំផ្ទាល់របស់ ប៉ង់។ ប៉ុន្តែខ្ញុំមិនប៊ានចាត់ចែងទៅណាមកណាទេ ស្រេចតែ ប៉ង់ ទេអ្នកដឹកនាំរួម អ្នកចាត់ចែងទៅណេះទៅណោះ ដកហូតអ្នកនេះអ្នកនោះ បាទ។

**ស៖** ខ្ញុំនូវមានសំណួរមួយចំនួនតូចទៀត នៅពេលដែលយើងជិតឈប់សម្រាកនេះ។ លោក តាន លោកបាននិយាយប្រាប់យើងខ្ញុំថា លោកបាននាំលិខិតនិងទូរលេខ ជូនទៅ ប៉ុល ពត និងយកពី ប៉ុល ពត។ តើនៅ ក-១ មានកន្លែងណាមួយដែលគេរក្សាទុកឯកសារទាំងឡាយ ដែលប្រើប្រាស់ដោយ ប៉ុល ពត ដែរឬទេ?

[១៤:៤០:២៧]

**ឆ៖** បាទ ពេលនោះគឺការប្រើប្រាស់ ដូចជា សារ នេះគឺថា ប៉ុល ពត ទុកផ្ទាល់ខ្លួនឯង។ អត់មានទុកកន្លែងណាផ្សេងទេ គឺថាទុកនៅ ក-១ ខ្លួនឯងផ្ទាល់តែម្តងបាទ។

**ស៖** តើដឹងមានអ្វីកើតឡើងចំពោះឯកសារទាំងនោះ នៅថ្ងៃទី០៦ ក៏ឬថ្ងៃទី០៧ ខែមករា ឆ្នាំ៧៩ បានន័យថានៅចុងរបបកម្ពុជាប្រជាធិបតេយ្យ។ ឯកសារទាំងនោះនោះនៅរក្សាទុកសល់នៅក-១ ដដែល

ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំក្តាប់មិនបានទេ។ តាមការស្មានគឺថាទុកនៅ ក-១ អត់មានយកទៅណាមកណាទេបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណច្រើនលោក អឿន តាន ចំពោះចម្លើយដែលលោកបានឆ្លើយលម្អិត។ សូមអរគុណលោកប្រធាន យើងខ្ញុំអស់សំណួរហើយ។

[១៤:៤១:៤០]

**ប្រធានអង្គជំនុំ៖**

អរគុណ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះនៅបន្ទប់រង់ចាំ សម្រាប់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឲ្យអញ្ជើញពួកគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០១:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល ថ្វាយបង្គំព្រះសង្ឃ ហើយនិងសាធារណជនទាំងអស់។

លោកប្រធាន មេធាវីនាំមុខបានស្នើសុំថា អ្នកដែលនឹងធ្វើអន្តរាគមន៍គឺលោកមេធាវី គីម ម៉េងឃី ហើយនិងខ្ញុំបាទ ពេជ អង្គ ដែលនឹងលើកសំណួរជូន សួរចំពោះលោកសាក្សីរូបនេះ ហើយជាចាប់ផ្តើម គឺលោក ម៉េងឃី នឹងត្រូវឡើងមុន។ សូមលោកប្រធានអនុញ្ញាត សូមអរគុណ។

[១៥:០២:៥៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល ហើយសូមជម្រាបសួរលោកអ៊ំសាក្សី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** ខ្ញុំបានស្តាប់សក្ខីកម្មរបស់លោកអ៊ំច្រើនមកហើយតាំងពីដំបូង នៃការចូលបដិវត្តន៍របស់លោកអ៊ំ រហូតទៅដល់ការបំពេញការងារជាកងការពារនៅមន្ទីរក-១។ ក៏ប៉ុន្តែ ខ្ញុំសូមវិលត្រឡប់ទៅចំណុចចាប់ដំបូងបន្តិច ដោយសារខ្ញុំមិនឃើញការបញ្ជាក់របស់លោកអ៊ំ ដែលលោកអ៊ំបានមានប្រសាសន៍ថា ការចូលធ្វើបដិវត្តន៍ហ្នឹងគឺធ្វើឡើងដោយស្ម័គ្រចិត្ត។ តើលោកអ៊ំអាចបញ្ជាក់បានទេ មូលហេតុអ្វីបានធ្វើឲ្យលោកអ៊ំចង់ចូលបដិវត្តន៍ ហើយក៏ដូចជាជនជាតិផ្សេងទៀត នៅក្នុងតំបន់នោះចង់ចូលបដិវត្តន៍?

[១៥:០៤:០៤]

**លោក អឿន តាន៖**

**ឆ៖** បាទ ពេលនោះខ្ញុំសូមឆ្លើយ ព្រោះខ្ញុំជាជនជាតិភាគតិច ប៉ុន្តែមិនដែលចេះអីទេ ម៉្លោះហើយឮគេថាធ្វើបដិវត្តន៍ៗ តែខ្លួនខ្ញុំចង់ចូល ចូលឲ្យវាមានចំណេះដឹង ដូចជា អក្សរ លេខអីហ្នឹង ព្រោះអីបញ្ហានេះក៏ជនជាតិ វាមិនចេះអីទាំងអស់ ល្ងង់ខ្លៅមិនចេះអីទាំងអស់ ធ្វើការងារធ្វើនឹងចប ធ្វើកម្លាំងពលកម្ម

ដោយនឹងចប។ ដូច្នេះ ខ្លួនខ្ញុំផ្ទាល់ឮថា បដិវត្តន៍ៗ។ ដូច្នេះខ្លួនខ្ញុំ គឺថាចង់ៗឃើញបដិវត្តន៍វាយ៉ាងម៉េច។ មួយគឺថា ចង់រៀន រៀនសូត្រចេះអក្សរៗ ព្រោះអត់ចេះសោះនៅពេលមុន។ បច្ចុប្បន្នក៏អ៊ីចឹងដែរ ជនជាតិភាគតិចនៅខាងរតនគិរីគឺ អ្នកខ្លះគេប្រឹងរៀនទៅគេចេះ។ អ្នកខ្លះមិនប្រឹងទេ គេខំទៅធ្វើចម្ការ អត់ចេះទេ។ នេះខ្ញុំសូមបញ្ជាក់ថា ខ្លួនខ្ញុំថាចង់ចូលបដិវត្តន៍ គឺចង់រៀន ចង់ចេះអក្សរ ចង់ចេះភាសាខ្មែរ កុំឲ្យល្ងង់ខ្លៅ អាហ្នឹងប៉ុណ្ណឹងទេ មិនចង់-- ថាចង់ចូលបដិវត្តន៍គឺអ៊ីចឹងបាទ។

[១៥:០៥:៣០]

**ស៖** សូមអរគុណលោកអ៊ំ។ បន្តសំណួរពាក់ព័ន្ធទៅនឹងការចូលបដិវត្តន៍ចង់រៀនហ្នឹង តើលោកអ៊ំបានទទួលវគ្គបណ្តុះបណ្តាលលើចំណុចអ្វីខ្លះ ពាក់ព័ន្ធនឹងបញ្ហាការធ្វើបដិវត្តន៍នោះ? សូមលោកអ៊ំជម្រាប។

**ឆ៖** បាទ ខ្ញុំអត់មានអីបណ្តុះបណ្តាលទេ គឺថាពេលនោះ នៅក្នុងព្រៃ ប៉ុន្តែខ្ញុំគ្មានសៀវភៅរៀនទេ ប៉ុន្តែខ្ញុំបណ្តុះបណ្តាលខ្លួនឯង ហើយមានអ្នកបង្រៀន គេអ្នកចេះៗ គឺថាគេបង្រៀនយើង។ បាទ អ៊ីចឹង គេបណ្តុះបណ្តាលយើងវិញ។ យកធ្យូងសរសេរនឹងបំពង់ឫស្សី ពេលហ្នឹងអត់ៗមានសៀវភៅទេ អត់មានប៊ិកទេ ប៉ុន្តែបណ្តុះបណ្តាលខ្លួនឯង គឺថាខំរៀន។ សរសេរនឹងធ្យូងនឹងបំពង់ឫស្សី ប៉ុនកជើង សរសេរអ៊ីចឹងទៅ រៀនតិចទៅ ដើរផង រត់នីរសារ រៀងផង កាលហ្នឹង។ អាហ្នឹងអ៊ីចឹង នេះសូមមានមតិអ៊ីចឹងបាទ។

[១៥:០៦:៤១]

**ស៖** បាទ សូមអរគុណ។ ចុះនៅពេលនោះ គេមានបង្រៀនលោកអ៊ំអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាដែរឬទេ?

**ឆ៖** ពេលនោះ គឺឆ្នាំ១៩៧៥ គេបង្ហាត់បង្រៀនដែរ គេបង្ហាត់បង្រៀនអំពីបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែឲ្យយល់ថា ន័យថា បក្សកុម្មុយនីស្តកម្ពុជាយ៉ាងម៉េច ខ្លួនខ្ញុំផ្ទាល់ ដូចបានបញ្ជាក់ខាងដើម ថាជនជាតិភាគតិច គាត់អត់យល់ទេ បក្សកុម្មុយនីស្តកម្ពុជានេះយ៉ាងម៉េច អត់យល់។ ដូចនេះ ការធ្វើ ការដឹងតាមតែឮគេនិយាយថា បក្សកុម្មុយនីស្តកម្ពុជា។ គ្រាន់តែឮគេនិយាយអ៊ីចឹងទៅ និយាយតាមគេ។ បាទ សូមអស់។

**ស៖** សូមអរគុណលោកអ៊ំ។ ខ្ញុំបន្តសំណួរមួយទៀត ពាក់ព័ន្ធនឹងតំបន់ដែលលោកអ៊ំរស់នៅ។ លោកអ៊ំបញ្ជាក់ថា លោកអ៊ំធ្វើការងារជានីរសារ និងកងការពារនៅក្នុងខេត្តរតនគិរី។ តើលោកអ៊ំអាច

បញ្ជាក់បានទេ ថាតើអង្គភាពនីរសារហ្នឹង គេហៅឈ្មោះថា អង្គភាពអីដែរ? ហើយតំបន់ហ្នឹង គេហៅតំបន់អីដែរ?

[១៥:០៨:០៧]

**ឆ៖** បាទ ពេលនោះ គឺថានៅរតនគិរី គឺថាខ្លួនខ្ញុំធ្វើជានីរសារ។ នីរសារគឺប្រធានឈ្មោះ ផៃ អ្នកដឹកនាំឲ្យនែ៎-- ហើយខ្ញុំរត់នីរសារ ពីរតនគិរី ទៅខាងរ៉ុនសៃ។ ពីរ៉ុនសៃ ឡើងមករតនគិរី។ ពីរតនគិរីទៅខាងមណ្ឌលគិរី។ នេះជម្រាបឲ្យត្រង់ ដែលមានភារកិច្ចរបស់ខ្ញុំគឺថាជម្រាបឲ្យត្រង់ជូនលោកចុះ បាទ។

**ស៖** លោកអ៊ំអាចបញ្ជាក់បានទេ ថាតើមធ្យោបាយរត់សារពីទីតាំងរបស់លោកអ៊ំទៅរ៉ុនសៃ ហើយនិងទៅមណ្ឌលគិរីហ្នឹង តាមរបៀបណាដែរ?

**ឆ៖** បាទ ពេលនោះ គឺថាការធ្វើដំណើរ គឺដើរ ដើរនឹងជើង ដេកមួយយប់ពីរយប់ពាក់កណ្ដាលផ្លូវអ៊ីចឹងទៅ បានដល់រ៉ុនសៃ។ អ៊ើ្ហ គឺថាវិធីដំណើរគឺថាពីរតនគិរីទៅមណ្ឌលគិរី ក៏អ៊ីចឹងដែរ ឆ្ងាយ។ ដើរជើង ដេកពាក់កណ្ដាលយប់ បានព្រឹកឡើង ឡើងទៀត បានដល់មណ្ឌលគិរី។ ធ្វើដំណើរដោយជើងតែម្ដង អត់មានជិះទេ កង់ក៏គ្មាន ព្រោះអត់មានផ្លូវ បាទ។

**ស៖** តើលោកអ៊ំអាចបញ្ជាក់បានទេ ថាតើសារដែលពីរ៉ុនសៃទៅមណ្ឌលគិរីហ្នឹង ពីអ្នកណាទៅអ្នកណាដែរ? លោកអ៊ំមានដឹងជ្រាបរឿងហ្នឹងទេ?

[១៥:០៩:៥៦]

**ឆ៖** បាទ ពេលនោះ គឺថាខ្ញុំនៅមន្ទីរស្រុក ហៅថាស្រុកអណ្ដូងមាស។ បាទ អ៊ីចឹងគឺថា រត់ពីស្រុកអណ្ដូងមាស ទៅខាងរ៉ុនសៃ ទទួលបញ្ជាដោយអ៊ំៗ កង ដែង គណៈស្រុក ឲ្យខ្ញុំយកសារហ្នឹងទៅខាងរ៉ុនសៃ។ ពីស្រុកអណ្ដូងមាសទៅខាងមណ្ឌលគិរី មាន កង ដែង ហ្នឹងជាគណៈស្រុក ហៅថាស្រុកអណ្ដូងមាស បាទ។

**ស៖** លោកអ៊ំអាចបញ្ជាក់បានទេថាតើទៅអំមិញហ្នឹងចេញពី កង ដែង ហ្នឹងទៅអ្នកណាគេលោកអ៊ំ?

**ឆ៖** បាទ ពេលនោះ គឺថាកាន់តែសំបុត្រទេ អត់ចេះមើលឈ្មោះគេទេ។ សំបុត្រការខ្ទងអត់ចេះមើលទេ មិនដឹងជូនអ្នកណាៗអត់ដឹងទេ។ រត់ពីស្រុកអណ្ដូងមាសទៅខាងរ៉ុនសៃ ឃើញគេសរសេរមិនដឹងឈ្មោះអី ព្រោះអត់ចេះអក្សរ។ អ៊ីចឹងជូនទៅ តាមឋានៈនីរសារគេទៅ គេនេះ នីរសារទីមួយគេតទៅទៀតទៅអាហ្នឹង គឺអ៊ីចឹងបាទ។

**ស៖** សូមអរគុណលោកអ៊ំ។ នៅក្នុងខេត្តរតនគិរី លោកអ៊ំមានស្គាល់មន្ទីរមួយឈ្មោះថាមន្ទីរ ១០០ ដែរឬទេ?

[១៥:១១:៣១]

**ឆ៖** បាទ ពេលនោះខ្ញុំឮៗគេនិយាយថាមន្ទីរ១០០បាទ។

**ស៖** លោកអ៊ំបានឮគេនិយាយអំពីមន្ទីរ១០០ហ្នឹង គេកន្លែងដែលអ្នកណាអ្នកនៅទីហ្នឹង មន្ទីរ ១០០ហ្នឹង?

**ឆ៖** បាទ ពេលនោះគឺថាមន្ទីរ១០០ហ្នឹងមានតា ប៉ុល ពត ហើយហ្នឹង អៀង សារី។ តែប៉ុណ្ណឹងទេ។ កន្លែង១០០ហ្នឹង មន្ទីរ១០០។ ប៉ុន្តែខ្ញុំនៅកន្លែងស្រុក ស្រុកអណ្តូងមាសហ្នឹង ធ្វើជានីរសាររបាទ។

**ស៖** ហើយលោកអ៊ំធ្លាប់ធ្វើជាកងការពារនៅមន្ទីរ១០០ហ្នឹងដែរឬទេ?

**ឆ៖** បាទ ពេលនោះខ្ញុំមិនធ្លាប់ទេ ខ្ញុំនៅការពារកន្លែងនីរសារស្រុក។ មាន ផៃ អ្នកដឹកនាំក្រុមនីរសារហ្នឹងបាទ។

**ស៖** តើនៅក្នុងឆ្នាំណាដែលលោកអ៊ំក្លាយទៅជាកងការពាររបស់ ប៉ុល ពត លោកអ៊ំចាំបានទេ?

**ឆ៖** បាទ ពេលនោះក៏ខ្ញុំចេញពីនីរសារទៅ ខ្ញុំមិនចាំថ្ងៃចាំខែទេ គេដកខ្ញុំមកនៅខាងកន្លែង ប៉ុល ពត នៅបាទ នៅខាងរតនគិរីបាទ។

[១៥:១៤:២៣]

**ស៖** កន្លែងដែល ប៉ុល ពត នៅក្នុងរតនគិរីហ្នឹង លោកអ៊ំចង់សំដៅកន្លែងណាដែរ? ជាមន្ទីរ១០០ ដែលខ្ញុំលើកឡើងអំមិញហ្នឹង ឬក៏ជាកន្លែងផ្សេងទេ?

**ឆ៖** បាទ សំដៅទៅមន្ទីរ១០០ហ្នឹងបាទ។

**ស៖** ក្រៅពីមេដឹកនាំ ប៉ុល ពត, អៀង សារី តើមានមេដឹកនាំណាផ្សេងទៀតចូលទៅធ្វើការ ឬក៏ស្នាក់នៅមន្ទីរ១០០ ហ្នឹង ដែលលោកអ៊ំបានស្គាល់ដែរឬទេ?

**ឆ៖** បាទ ពេលនោះ ខ្ញុំអត់ស្គាល់ទេ មិនដឹងអ្នកណាៗទេ អស់ស្គាល់ទេបាទ។

**ស៖** តើលោកអ៊ំអាចដឹងអំពីចំនួនមេដឹកនាំនៅក្នុងហ្នឹងមានច្រើននាក់ ឬក៏មានតែពីរនាក់ហ្នឹងទេ?

**ឆ៖** បាទ មានតែពីរនាក់ទេពេលនោះ។

[១៥:១៤:២៥]

**ស៖** បាទ សូមអរគុណលោកអ៊ំ។ បន្តសំណួរមួយទៀត។ នៅពេលដែលលោកអ៊ំធ្វើជាកងការពារឲ្យ ប៉ុល ពត តើលោកអ៊ំធ្លាប់ការពារគាត់នៅពេលដែលគាត់ប្រជុំសមាជនៅក្នុងខេត្តរតនគិរី ឬក៏ខេត្តណាផ្សេងៗដែរឬទេ?

**ឆ៖** បាទ អត់ដែលទេបាទ។

[១៥:១៥:00]

**ស៖** លោកអ៊ំបានរៀបរាប់ពីខាងដើមថា លោកអ៊ំបានការពារ ប៉ុល ពត ទៅទីតាំងមួយកន្លែងដែលស្ថិតនៅព្រំប្រទល់កំពង់ធំ និងកំពង់ចាម តើលោកអ៊ំអាចបញ្ជាក់បានទេទីតាំងនុ៎ងគេហៅឈ្មោះថាជាទីតាំងអ្វីដែរ? ហើយលោកអ៊ំការពារហ្នឹងរយៈពេលប៉ុន្មានដែរ?

**ឆ៖** បាទ ពេលនោះក៏-- ទីតាំងនៅកន្លែង ប៉ុល ពត ធ្វើការទីតាំងនៅភូមិត្រពាំងទឹម នៅខេត្តកំពង់ចាម តាមដងស្ទឹងសង្កែ (ស៊ីក) ខ្ញុំចាំប៉ុណ្ណឹងបាទ។

**ស៖** តើលោកអ៊ំដឹងទេ មាន-- នៅទីនោះគឺមានទីតាំងមួយដែលមានមន្ទីរ បន្ទាយមួយគេហៅថា មន្ទីរ ក-១ នៅទីនោះលោកអ៊ំមានជ្រាបបញ្ហាហ្នឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងទេបាទ។

[១៥:១៦:០៩]

**ស៖** ចុះទីតាំងមួយកន្លែងទៀតដែលស្ថិតនៅក្នុងភូមិដងក្ដារ ប៉ែកព្លសាននៃឃុំស្ទឹ លោកអ៊ំដែលធ្លាប់ទៅជាមួយ ប៉ុល ពត នៅទីនោះទេ? ភូមិដងក្ដារ ប៉ែកព្លសាននៃឃុំស្ទឹ។

**ឆ៖** បាទ ភូមិដងក្ដារ ខ្ញុំធ្លាប់ជូនគាត់ដែរ នៅមន្ទីរដងក្ដារណ៎ា ធ្លាប់ជូនគាត់ធ្វើការដែរ។

**ស៖** តើកន្លែងនោះជាទីតាំងអ្វីដែរ ហើយគេសម្រាប់ធ្វើអីខ្លះនៅទីតាំងនោះ?

**ឆ៖** ទីតាំងឃើញ គេប្រជុំ ដូចបានបញ្ជាក់ខាងដើម គេប្រជុំខាងផ្នែករដ្ឋបាល ដូចជាខាងផ្នែកភូមិភាគអីចឹង។ តែគេគ្រាន់ថាផ្នែកហ្នឹងជិត តាមតំបន់ តាមស្រុកអី គេយកមន្ទីរកន្លែងដងក្ដារហ្នឹងជាទីតាំងមួយហៅថាប្រជុំបាទ។

[១៥:១៧:១៧]

**ស៖** សូមលោកអ៊ំបញ្ជាក់ឲ្យបានច្បាស់ពីចំណុចមួយទៅចំណុចមួយ លោកអ៊ំសំដៅទៅលើការប្រជុំរដ្ឋបាលហ្នឹងសំដៅទៅលើការប្រជុំយ៉ាងម៉េច? មានមេដឹកនាំប៉ុន្មាននាក់ដែលចូលរួម ហើយគេប្រជុំនិយាយអំពីអ្វីដែរ បញ្ហាអស់ហ្នឹង?

**ធ៖** បាទ ពេលនោះគឺខ្ញុំអត់ដឹងទេ ព្រោះមិនស្គាល់ឈ្មោះគេអាហ្នឹង។ ស្គាល់តែ ប៉ុល ពត តែប៉ុណ្ណឹង ប៉ុន្តែក្រៅពីហ្នឹងឃើញគេចូលដែរមិនដឹងពីណាខ្លះទេ អត់ស្គាល់។ អាហ្នឹងខ្ញុំបញ្ជាក់ជូនឲ្យច្បាស់អ៊ីចឹង។ អត់ស្គាល់។

**ស៖** តើលោកអ៊ំកំណត់ដូចម្ដេចបានថា នៅប្រជុំនៅទីនោះមានប្រជុំភូមិភាគ ឬក៏ប្រជុំតំបន់នោះ?

**ធ៖** ពេលនោះ គឺកំណត់ថា ព្រោះឃើញមិត្ត ប៉ង់ គេបញ្ជាក់ថា ឥឡូវគេមកខាងមន្ទីរភូមិដងក្ដារហ្នឹង ប្រជុំខាងស្រុក និងតំបន់។ អាហ្នឹងកោះហៅពីស្រុក តំបន់មកប្រជុំកន្លែងមន្ទីរភូមិដងក្ដារហ្នឹងបាទ។ ខ្ញុំឮតែពី ប៉ង់ ទេបាទ។

[១៥:១៨:៤៥]

**ស៖** រាល់ការប្រជុំដែលលោកអ៊ំបានដឹងហ្នឹង តើមានវត្តមានរបស់លោក នួន ជា, លោក ខៀវ សំផន, លោក អៀង សារី នៅទីនោះដែរឬទេ អមជាមួយនឹង ប៉ុល ពត?

**ធ៖** ពេលនោះ គឺអត់មានទេ ខៀវ សំផន អត់មាន អៀង សារី ទេ។ មានតែ ប៉ុល ពត ហើយនិងអ្នកផ្សេងទៀតដែលខ្ញុំមិនចាំឈ្មោះបាទ។ មិនស្គាល់ឈ្មោះបាទ។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ តើលោកអ៊ំធ្លាប់ឮអំពីការហៅឈ្មោះមន្ទីរដែលលោកអ៊ំរៀបរាប់ថា មន្ទីរដងក្ដារហ្នឹងមានឈ្មោះអីផ្សេងក្រៅពីហ្នឹងជាការសម្គាល់ទេ? មានលេខសម្ងាត់អីទេ?

**ធ៖** បាទ អត់ដឹងទេបាទ។ វាយូរហើយអត់ស្គាល់មិនដឹងស៊ីៗខ្លះទេបាទ។

**ស៖** លោកអ៊ំអាចបញ្ជាក់បានទេ នៅមុនពេលការចូលកាន់កាប់ទីក្រុងភ្នំពេញឆ្នាំ១៩៧៥ ហ្នឹងពេលណាដែលលោកអ៊ំមិនបានការពារ ប៉ុល ពត ហើយនិងថ្នាក់ដឹកនាំផ្សេងៗទៀត ពីឆ្នាំណាដល់ឆ្នាំណា?

[១៥:២០:១៩]

**ធ៖** បាទ ខ្ញុំសូមបញ្ជាក់ជូនឲ្យច្បាស់ ហើយឲ្យចំ ដើម្បីអស់លោកយល់ អស់លោកជ្រាប។ ភារកិច្ចរបស់ខ្ញុំគឺថា តាំងពីឆ្នាំ៧០មក តាំងពីឆ្នាំ៧០ រហូតដល់ ៧៥ រស់នៅ ប៉ុល ពត រហូត។ ដល់ឆ្នាំ៧៥ រហូតដល់ ៧៩ បែកៗ នេះសូមបញ្ជាក់ឲ្យច្បាស់អ៊ីចឹងបាទ។

**ស៖** លោកអ៊ំបានមានប្រសាសន៍ថា ៧០ ដល់ ៧៥ លោកអ៊ំតាម ប៉ុល ពត រហូត។ លោកអ៊ំអាចបញ្ជាក់បានទេ មុនថ្ងៃ១៧ មេសា ១៩៧៥ នៅក្នុងអំឡុងខែមករា ខែកុម្ភៈ មីនា មុនហ្នឹងបីបួនខែ ឆ្នាំ

៧៥ លោកអ៊ំនៅការពារ ប៉ុល ពត ដែរឬទេ?

**ឆ៖** បាទ ពេលនោះដូចបញ្ជាក់ហូរហែមកហើយថា ពីឆ្នាំ៧៥ បានបែកភ្នំពេញហ្នឹងទៅក៏ ប៉ុល ពត មកមុន ដូចបញ្ជាក់ខាងដើម ប៉ុល ពត មកមុន ខ្ញុំនៅក្រោយប្រហែលជាកន្លះខែ ព្រោះខ្ញុំរៀបចំអីវ៉ែអីវ៉ាន់កំប៉ិកកំប៉ុករបស់តា ប៉ុល ពត និងមកក្រោយៗ ប៉ុល ពត បាទ។

[១៥:២១:៥៩]

**ស៖** លោកអ៊ំអាចបញ្ជាក់បានទេថា គាត់មកមុនលោកអ៊ំហ្នឹង មានន័យថាគាត់មុនពេលហ្នឹង លោកអ៊ំនៅជាមួយគាត់ដែរ ឬក៏លោក-- មិននៅជាមួយគាត់ទេ? ហើយរៀបចំឥវ៉ាន់ហ្នឹងលោកអ៊ំសំដៅទៅលើថា រៀបចំអីវ៉ាន់ពីណាមកចេញពីណា?

**ឆ៖** បាទ កាលនោះខ្ញុំរៀបចំ ពេលរៀបចំគឺថា កន្លែងហៅថា ភូមិត្រពាំងទឹម ខេត្តកំពង់ចាម បានអ៊ីចឹងខ្ញុំរៀបចំអីវ៉ាន់ គឺថាមានស្អី? មានខោអាវ មុងភួយ របស់គាត់ដែលប្រើប្រាស់ប្រចាំថ្ងៃ។ ហើយគាត់មកមុនអ៊ីចឹងទៅ ខ្ញុំនៅក្រោយគឺថាមុនកន្លះខែ គាត់ទៅមុនកន្លះខែ ខ្ញុំនៅរៀបអីវ៉ែអីវ៉ាន់អ៊ីចឹងទៅ បានហើយ ប៉ង់ បានហៅខ្ញុំចូលភ្នំពេញវិញ។ ខ្ញុំយកអីវ៉ាន់ចូលភ្នំពេញដែរបាទ។

**ស៖** ដូច្នេះមានន័យថាមុននឹងកន្លះខែ ប៉ុល ពត នៅកំពង់ចាមទេឬក៏យ៉ាងម៉េចលោកអ៊ំ?

**ឆ៖** បាទ អត់ទេបែកភ្នំពេញគាត់ចូលៗ មក ចូលពីកំពង់ចាម ចូលភ្នំពេញតែម្តង ឆ្នាំ៧៥ហ្នឹង ដល់អ៊ីចឹងទុកឲ្យខ្ញុំនៅក្រោយ ដើម្បីប្រមូលអីវ៉ាន់ ទុកអីវ៉ាន់ រៀបចំអីវ៉ាន់។ ដល់អ៊ីចឹងប្រហែលជាកន្លះខែមកគឺ ប៉ង់ ហៅខ្ញុំចូលភ្នំពេញវិញបាទ។

[១៥:២៣:៤២]

**ស៖** ខ្ញុំសូមបញ្ជាក់លោកអ៊ំថែមទៀតនៅជុំវិញចំណុចនេះ ចង់សួរលោកអ៊ំថា តើនៅមក្នុងមុនពេលឆ្នាំ៧៥ មុនដែល ប៉ុល ពត ចូលភ្នំពេញហ្នឹងគាត់មានប្រជុំនៅទីតាំងខេត្តកំពង់ឆ្នាំង ឬក៏នៅឧដុង្គដែរឬទេ? ហើយលោកអ៊ំបានអមដំណើរគាត់ទៅជាមួយដែរទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។ សំណួរក្រៅអង្គហេតុឆ្ងាយណាស់ អង្គហេតុហ្នឹងដូចមិនមានការបង្ហាញនៅក្នុងដីកាដំណោះស្រាយទេ។ ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាដូចជាសមល្មមនឹងអាចនឹងទទួលយកបានហើយ។ គួរតែសួរដេញដោលជាប់ពាក់ព័ន្ធនឹងអ្វីដែលសាក្សីបានដឹងដោយផ្ទាល់ពាក់ព័ន្ធជាមួយនឹងយុត្តាធិការពេលវេលានៃអង្គជំនុំជម្រះ អ.វ.ត.ក ១៧ មេសា ៧៥, ៦ មករា ៧៩

ហើយជ្រើសរើសយកតែអង្គហេតុណាដែលពាក់ព័ន្ធទៅនឹងសាក្សីគាត់បានដឹងជាក់ច្បាស់ផ្ទាល់ ដើម្បីឈានទៅរកស្វែងរកការពិត។

[១៥:២៥:១១]

**លោក គីម ម៉េងឃី៖**

សូមៗអរគុណលោកប្រធាន ក៏ប៉ុន្តែនៅក្នុងចំណុចដែលខ្ញុំសួរនេះ ពីព្រោះនៅក្នុងនេះគឺមានតែថែងនៅក្នុង-- មានជាអង្គហេតុមួយដែលមាននៅក្នុងកថាខណ្ឌ៨៩៩ នៃដីកាដំណោះស្រាយ--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនឲ្យសាក្សីឆ្លើយទេ! ព័ត៌មានពាក់ព័ន្ធជាមួយនឹងប្រវត្តិបក្សកុម្មុយនីស្តកម្ពុជាហ្នឹង អង្គជំនុំជម្រះទទួលព័ត៌មានសមល្មម អាចអង្គជំនុំជម្រះមានមូលដ្ឋានពិចារណាហើយ។ សូមបន្តទៅអង្គហេតុដែលពាក់ព័ន្ធទៅនឹងសាក្សី ដែលបានយល់ដឹងដោយផ្ទាល់ ដើម្បីឆ្លុះបញ្ចាំងអំពីអង្គហេតុ អំពីភស្តុតាង អំពីស្ថានភាពនានានៃរឿងក្តី។ អង្គជំនុំជម្រះមិនត្រូវការស្តាប់ចម្លើយតបរបស់មេធាវី-- អ៎ របស់សាក្សីឆ្លើយតបនឹងសំណួរដែលលោកសួរចុងក្រោយអម្បាញ់មិញនេះទេ។ លោកមានសំណួរផ្សេងលោកតាំងសំណួរ បើអស់សំណួរប្រគល់ឲ្យអ្នកដទៃបន្ត។

[១៥:២៦:១៦]

**លោក គីម ម៉េងឃី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្តសំណួរទៅលោកអ៊ំសាក្សី អឿន តាន ជាបន្តទៀត។

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** លោកអ៊ំជ្រាបទេអំពីរឿងជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅពេលដែលលោកអ៊ំនៅកំពង់ចាមនោះ?

**លោក អឿន តាន៖**

**ឆ៖** បាទ ខនេះខ្ញុំបានឆ្លើយហើយ គឺថាពេលរំដោះភ្នំពេញ ខ្ញុំនៅកំពង់ចាមនោះ។ ដល់ ប៉ង់ហៅមកខ្ញុំបានរៀបចំអីវ៉ែអីវ៉ាន់ ដល់អ៊ីចឹងទៅមកហ្នឹង។ រៀបចំអីវ៉ែអីវ៉ាន់ ប៉ង់ គេហៅខ្ញុំចុះមក។ ចុះមកគឺថាចូលភ្នំពេញគឺស្ងាត់ ខ្ញុំអត់ដឹងណាជម្លៀសៗទេ ប៉ុន្តែគ្រាន់តែឃើញស្ងាត់ ស្ងាត់តែម្តង។ នេះខ្ញុំសូមបញ្ចាក់អ៊ីចឹង។

[១៥:២៧:១០]

**ស៖** សូមទោសប្រហែលជាខ្ញុំសួរសំណួររាងពិបាកយល់បន្តិច។ ខ្ញុំសូមបញ្ជាក់សំណួរឡើងវិញ គឺថាតើលោកអ៊ំមានឃើញការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ ប្រជាជនចេញពីភ្នំពេញហ្នឹងទៅដល់កន្លែងដែលលោកអ៊ំនៅ-- ស្នាក់នៅនៅកំពង់ចាមដែរឬទេបាទ?

**ឆ៖** បាទ ត្រង់នេះខ្ញុំសូមបញ្ជាក់ជូនពីការជម្លៀសប្រជាជន។ ដូចបញ្ជាក់ខាងដើមហើយ គឺថាខ្ញុំអត់ដឹងទេ ព្រោះខ្ញុំនៅកំពង់ចាមណោះ។ គេជម្លៀសប្រជាជនតាមខេត្ត តាមភូមិភាគអីផ្សេងៗ ខ្ញុំមិនដែលដឹងទេ។ នែប៉ុន្តែដូចបញ្ជាក់ខាងដើមថា ពេលខ្ញុំចូលភ្នំពេញឃើញតែស្ងាត់តែម្តង អត់មានមនុស្សម្ល៉ោះហើយបានថា អ្នកណាជម្លៀសៗ ខ្ញុំមិនដឹងទេ គ្រាន់ថាខ្ញុំនៅកំពង់ចាមឯណោះ។

**ប្រធានអង្គជំនុំ៖**

អរគុណសាក្សី ហើយសូមសាក្សីស្តាប់សំណួរអ្នកសួរឲ្យបានច្បាស់ ហើយឆ្លើយត្រឹមតែកម្រិតសំណួរដែលសួរបានហើយ។ ប្រសិនបើសួរថា កាលពីលោកនៅខេត្តកំពង់ចាមហ្នឹង លោកបានទទួលដំណឹង ដឹងថាមានប្រជាជនជម្លៀសចេញពីទីក្រុងភ្នំពេញ ទៅដល់ទីកន្លែងដែលលោកធ្វើការដែរអត់? បើលោកថាមិនដឹងទេ ឆ្លើយថាមិនដឹងទៅ ចប់ហើយ។ ព្រោះសំណួរផ្សេងទៀត ពាក់ព័ន្ធនឹងដល់រាជធានីភ្នំពេញហ្នឹង អត់មានសំណួរសួរលោកទេ។ ឆ្លើយតបឲ្យចំនឹងសំណួរដែលសួរបានហើយ។

[១៥:២៨:៥១]

**សួរដោយលោក គីម ម៉េងឃី៖**

**ស៖** នៅ-- ខ្ញុំសូមបន្តសំណួរទៀតលោកអ៊ំ។ គឺថានៅក្នុងពេលដែលលោកអ៊ំធ្វើជាកងការពារចាប់ពីពេលដែលលោកអ៊ំចូលមកមន្ទីរក-១ នៅទីក្រុងភ្នំពេញហ្នឹង តើលោកអ៊ំបានដឹងទេ ថាមានពេលណាមួយដែល ប៉ុល ពត ផ្លាក់ខ្លួនឈឺជាទម្ងន់?

**លោក អឿន តាន៖**

**ឆ៖** បាទ ខ្ញុំមិនដែលដឹងទេបាទ។

**ស៖** តើនៅក្នុងចន្លោះឆ្នាំ-- នៅក្នុងថ្ងៃ២៧ ខែកញ្ញា ឆ្នាំ១៩៧៦ មានគេប្រកាសសេចក្តីប្រកាសរបស់មួយ ដែលបញ្ជាក់ថា ប៉ុល ពត ឈឺជាទម្ងន់ តើលោកអ៊ំជ្រាបពីបញ្ហានេះដែរឬទេ ក្នុងឆ្នាំ៧៦ ហ្នឹង?

**ឆ៖** បាទ អត់ដែលដឹងទេបាទ។

**ស៖** ដូច្នេះ ប៉ុល ពត មិនដែលឈឺជាទម្ងន់ ឬក៏ធ្លាប់ឈឺជាទម្ងន់? លោកអ៊ំសូមបញ្ជាក់ នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យហ្នឹង។

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ជូនថា ការឈឺធ្ងន់ធ្ងររបស់លោក ប៉ុល ពត តាមការដឹងគឺ ខ្ញុំមិនដែលឃើញទេ គ្រាន់តែឈឺបន្តិចបន្តួច លេបថ្នាំទៅបាត់ៗ ហើយការឈឺធ្ងន់ធ្ងរអត់មានទេបាទ។ ខ្ញុំបញ្ជាក់ជូនច្បាស់អ៊ីចឹងបាទ។

[១៥:៣០:៣៨]

**ស៖** ដូច្នេះ មិនមានព្រឹត្តិការណ៍ណាមួយ ដែលលោកអ៊ំបានដឹងថា ប៉ុល ពត ឈឺធ្ងន់រួចលាលែង ផ្ទេរតំណែងរបស់គាត់ទៅលោក នួន ជា ដែរឬទេ? មានព្រឹត្តិការណ៍បែបហ្នឹងដែរឬទេលោកអ៊ំបានជ្រាប?

**ឆ៖** បាទ ខ្ញុំបញ្ជាក់ជូនគឺថា ខ្ញុំអត់ដឹងទេបាទ។

**ស៖** ដូច្នេះ ខ្ញុំបន្តសំណួរមួយទៀត បើលោកអ៊ំមិនបានដឹងអំពី-- នៅក្នុងពេលដែលលោកអ៊ំមិនបានដឹងថា ប៉ុល ពត ធ្លាប់ឈឺទេ ដូចអ្វីដែលលោកអ៊ំបានលើកឡើងហ្នឹង ការប្រជុំគឺមិនដែលមានការអាក់ខានទេ តើពិតជាអ៊ីចឹងមែនទេលោកអ៊ំ?

**ប្រធានអង្គជំនុំ៖**

ចាំៗ ឧបករណ៍ប្រតិបត្តិការសឹមឆ្លើយសាក្សី!

**លោក អឿន តាន៖**

**ឆ៖** សូមលោកបញ្ជាក់មួយសាទៀតបាទ។

**សួរដោយលោក គឹម ម៉េងឃី៖**

**ស៖** ខ្ញុំបញ្ជាក់សំណួរឡើងវិញគឺថា បើ ប៉ុល ពត ដូចអ្វីដែលលោកអ៊ំ បញ្ជាក់ថា គ្មានព្រឹត្តិការណ៍ដែលគាត់ឈឺធ្ងន់ បានន័យថា តើជាការពិតដែរឬទេ ដែលមន្ទីរក-១ ហ្នឹងមានការប្រជុំរហូតដោយគ្មានការអាក់ខានអី ហើយមានវត្តមាន ប៉ុល ពត រហូត?

**លោក អឿន តាន៖**

**ឆ៖** ពេលនោះគឺ តាមក្តាប់បានគឺថា គាត់មិនឈឺអីធ្ងន់ធ្ងរ គាត់នៅធ្វើការបាន គាត់ធ្វើជាការងាររហូត ការប្រជុំការអី គឺគាត់ធ្វើរហូតដែរ។ ព្រោះតាមការរស់នៅរបស់ខ្ញុំគឺថា មិនឃើញឈឺអីធ្ងន់ធ្ងរទេ ឈឺបន្តិចបន្តួច ដូចបញ្ជាក់ខាងដើមថា លេបថ្នាំមួយគ្រាប់ពីរគ្រាប់ទៅបាត់ ហើយគាត់ចេះតែធ្វើការងារតទៀតបាទ។

[១៥:៣២:៥១]

**ស៖** សូមអរគុណលោកអ៊ំ។ ខ្ញុំបន្តសំណួរមួយទៀត ពាក់ព័ន្ធទៅនឹងទូរលេខ លោកអ៊ំបានឆ្លើយច្រើនហើយ អំពីការបញ្ជូន និងការទទួលទូរលេខ។ ប៉ុន្តែលោកអ៊ំអាចបញ្ជាក់បានទេ ថាតើនៅពេលដែលលោកអ៊ំទទួលទូរលេខហ្នឹង លោកអ៊ំដឹងថាតើទូរលេខហ្នឹងប្រភពមកពីខាងណាដែរ? ដែលជូនទៅ ប៉ុល ពត ហ្នឹង?

**ផ៖** បាទ ខ្ញុំអត់ដឹងពីប្រភពណាទេ ព្រោះនៅក្នុងសំបុត្រគេដាក់ក្នុងស្រោម ហើយគេការខ្ទង អ៊ីចឹងទៅ។ ដូច្នេះ គឺថាមកពីប្រភពណា ខ្ញុំមិនដែលដឹងទេបាទ។

**ស៖** ក្រៅអំពីការបញ្ជូនទូរលេខ និងសំបុត្រ តើលោកអ៊ំធ្លាប់ទទួលបានការបញ្ជូនចម្លើយសារភាព ឬក៏ឯកសារអីផ្សេងពីហ្នឹងទេ? ដែលគេបញ្ជូនមកមន្ទីរក-១?

**ផ៖** បាទ កន្លងទៅក៏ដូចបានបញ្ជាក់ខាងដើមថា សំបុត្រគេបញ្ជូនពីណាៗមក គឺថាគឺគេការខ្ទងសរសេរខ្ទង ដូច្នេះ ខ្ញុំចេះតែបញ្ជូនឲ្យ ប៉ុល ពត។ ដូច្នេះពីសាច់ការងារអីផ្សេងៗ ក្នុងនោះខ្ញុំក៏មិនដឹងដែរ។ គ្រាន់តែយកសំបុត្រឲ្យ ប៉ុល ពត តែប៉ុណ្ណោះបាទ។

[១៥:៣៤:២០]

**ស៖** បាទ សូមអរគុណ។ ខ្ញុំបន្តសំណួរមួយទៀត ពាក់ព័ន្ធទៅនឹងការប្រជុំ។ លោកអ៊ំបានរៀបរាប់អំពីថា ប៉ុល ពត បានចូលរួមប្រជុំនៅតាមខេត្ត និងដោយចុះទៅទីតាំងទំនប់មួយចំនួន លោកអ៊ំអាចរំឭកឡើងវិញទេ ថាតើខេត្តណាខ្លះដែលទៅ? ហើយទីតាំងហ្នឹងគេហៅថាទីតាំងអីដែរ?

**ផ៖** បាទ បញ្ហានេះ ដូចបានបញ្ជាក់ខាងដើមហើយមុន គឺថាការប្រជុំតាមខេត្ត តាមតំបន់ បានជម្រាបហើយថា ឧទាហរណ៍ថា ចុះតំបន់សៀមរាប គឺប្រជុំក្នុងគណៈតំបន់សៀមរាបហ្នឹង។ ប៉ុន្តែការណែនាំអីៗ គេពិភាក្សាបញ្ហាអី ខ្ញុំមិនដែលដឹងទេ ពីព្រោះបញ្ហា គឺដូចបានបញ្ជាក់ខាងដើម គឺថាកងការពារនៅឆ្ងាយពីកន្លែងការ។ គ្រាន់តែដឹងថា ដល់ប្រជុំហើយ គាត់ចុះទៅ ណែ៎ គាត់ចុះទៅកន្លែងប្រឡាយ ចុះកន្លែងទំនប់ បានខ្ញុំថាយល់ថា កន្លែងគេដឹកនាំប្រជុំ ណែនាំបញ្ហាទំនប់ ប្រឡាយហ្នឹងឯងតាមមើល។ ឃើញជាក់ស្តែង គឺអ៊ីចឹង គឺប្រជុំហើយ គឺថាចុះទៅកន្លែងប្រឡាយ ទំនប់។ បានខ្លួនយល់ថាដឹកនាំ គេចុះមកមើលប្រឡាយហ្នឹងឯង។ ប្រជុំគឺដោះស្រាយបញ្ហាប្រឡាយនេះឯង។ ខ្លួនក៏ចាប់ផ្តើមយល់បាទ។

[១៥:៣៥:៥៤]

**ស៖** សូមលោកអ៊ំបញ្ជាក់ពីឈ្មោះទីតាំង ដែលលោកអ៊ំថាចុះទៅមើលទំនប់ប្រឡាយហ្នឹង។

ទីតាំងហ្នឹង គេហៅថាអ្វី? ឈ្មោះអី? លោកអ៊ំចាំបានទេ។

[១៥:៣៦:១៣]

**ឆ៖** បាទ ទីតាំងប្រឡាយទំនប់ហ្នឹង ខ្ញុំអត់ចាំទេ វាយូរហើយ មិនដឹងឈ្មោះអីខ្លះ។ គ្រាន់ថាដឹងថាគេធ្វើទំនប់ ធ្វើប្រឡាយ ប៉ុន្តែអាប្រឡាយស្អី ទំនប់ស្អី ខ្ញុំភ្លាប់មិនដែរ ភ្លេចអស់ហើយ យូរហើយ។ បាទ អត់ចាំ។

**លោក គីម ម៉េងឃី៖**

បាទ លោកអ៊ំ ខ្ញុំអស់សំណួរហើយ ហើយខ្ញុំទុកឲ្យលោកសហភាតាខ្ញុំបន្តសំណួរទៅលោកអ៊ំទៀត។ បាទ សូមអរគុណ ចំពោះការឆ្លើយបំភ្លឺរបស់លោកអ៊ំបាទ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ ខ្ញុំមានសំណួរមួយចំនួនដែលនៅក្នុងនោះ បីសំណួរដំបូង គឺបញ្ជាក់អំពីទីតាំងនៅកំពង់ធំ ហើយនិងកំពង់ចាម ដែលហាក់ដូចជាពុំសូវមានភាពច្បាស់លាស់។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកអ៊ំបានមានប្រសាសន៍អំពីដងក្ដារ តើដងក្ដារនេះ គឺជាឃុំដងក្ដារ ឬក៏ជាភូមិដងក្ដារ? តើស្ថិតនៅខាងណានៃស្ទឹង?

**លោក អឿន តាន៖**

**ឆ៖** ដងក្ដារហ្នឹង ស្ថិតខាងលិច។ ខាងលិចដងស្ទឹងៗបាទ។

**ស៖** ភូមិដងក្ដារនេះ ឬក៏ឃុំដងក្ដារនេះ នៅជិតឃុំស្អីដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលស្គាល់ទេបាទ។

**ស៖** ចំណុចមួយទៀត តើអ៊ំមានធ្លាប់ឮឃុំក្រយាដែរឬទេ?

[១៥:៣៨:១៥]

**ឆ៖** បាទ ឮៗ គ្រាន់តែគេថា ឃុំក្រយាៗ ប៉ុន្តែអត់ដែលទៅដល់ គ្រាន់តែឮគេនិយាយថា ឃុំក្រយា។ ក្រយា ដងក្ដារៗណ៎ា។

**ស៖** តើដងក្ដារ ក្រយា ដែលអ៊ំមានប្រសាសន៍អម្បាញ់មិញ គឺដងក្ដារដែលអ៊ំបាននិយាយនោះ ឬក៏យ៉ាងម៉េច?

**ឆ៖** ឃុំក្រយា គឺក្រយា។ ដងក្តារ គឺដងក្តារផ្សេង។ ផ្សេងពីក្រយាហ្នឹង ឆ្ងាយគ្នាបាទ។

**ស៖** ឆ្លងស្ទឹងម្នាក់ម្ខាង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ ឆ្លងស្ទឹង។

**ស៖** បាទ អ៊ីចឹងអាចជាឃុំដងក្តារ។ ចំណុចមួយទៀត ដែលអ៊ំមានប្រសាសន៍ពាក់ព័ន្ធនឹងភូមិត្រពាំងទឹម ដែលអ៊ំមានប្រសាសន៍ថា ស្ថិតនៅក្នុងខេត្តកំពង់ចាម។ តើភូមិត្រពាំងទឹមហ្នឹង នៅខាងលិចស្ទឹង ឬក៏ខាងកើតស្ទឹង?

**ឆ៖** បាទ កន្លែងមន្ទីរនៅត្រពាំងទឹម ភូមិត្រពាំងទឹម នៅខាងលិចស្ទឹង។ កន្លែងខ្ញុំនៅ នៅខាងកើតស្ទឹងបាទ។

[១៥:៣៩:២៩]

**ស៖** ដល់អ៊ីចឹង អ៊ំមានស្គាល់ឃុំបឹងល្វាដែរឬទេ?

**ឆ៖** បាទ អត់ដែលស្គាល់ទេ បាទ។

**ស៖** ស្ទឹងដែលអ៊ំមានប្រសាសន៍ៗ ថាជាស្ទឹងសង្កែ ថាតើអាចជាស្ទឹងអីផ្សេង ដូចជាស្ទឹងតាំងក្រសាំង ឬក៏ស្ទឹងជីនីតដែរឬទេ? ឬក៏ជាស្ទឹងសង្កែតែម្តង?

[១៥:៤០:០៤]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ជូនថា ស្ទឹង មិនស្ទឹងសែនទេ ស្ទឹងសង្កែទេ ស្ទឹងសែន។ តាមដឹងស្ទឹងសែន។

**ស៖** អាចជាស្ទឹងជីនិតដែរឬទេ ឬក៏ស្ទឹងសែន?

**ឆ៖** ស្ទឹងសែន។

**ស៖** បាទ អរគុណអ៊ំ ខ្ញុំចង់សុំសួរអំពីទីកន្លែងមួយទៀត ជាចំណុចចុងក្រោយ។ តើអ៊ំមានធ្លាប់អញ្ជើញទៅទីកន្លែងមួយដែលមានឈ្មោះថា ព្រៃកកក់ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលទេបាទ។

**ស៖** ធ្លាប់ឮដែរឬទេអ៊ំ?

**ឆ៖** អត់។

**ស៖** បាទ អ៊ីចឹងសូមអរគុណអ៊ំ។ ខ្ញុំនឹងចូលទៅដល់សំណួរពាក់ព័ន្ធទៅនឹងដែនយុត្តាធិការនៃ--នៃពេលវេលានៃរបស់តុលាការ។

[១៥:៤១:១៨]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន ខ្ញុំសូមលោកប្រធានអនុញ្ញាតបង្ហាញឯកសារមួយ ដែលជាកំណត់ហេតុនៃការសម្ភាសរបស់លោកសាក្សី អឿន តាន នេះដែលមានលេខ E3/33 លេខ ERN ជាភាសាខ្មែរ 00231809, ERN ជាភាសាអង់គ្លេស 00235134, ERN ជាភាសាបារាំង 00235339។ ដើម្បីសួរបញ្ជាក់គាត់បន្ថែមឲ្យបំភ្លឺលើចំណុចនៅក្នុងកំណត់ហេតុនេះ។ សូមលោកប្រធានអនុញ្ញាត ហើយខ្ញុំមានឯកសារដើម្បីប្រគល់ជូនលោកសាក្សី ប្រសិនបើលោកសាក្សីត្រូវការ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ ហើយសាក្សីអាចអានអក្សរបានទេ?

**លោក អឿន តាន៖**

បាទ អានអត់កើតទេបាទ អត់កើតទេ។

[១៥:៤២:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកយកឯកសារហ្នឹងមកសួរសាក្សីបាន ហើយនិងឲ្យជំនួយការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ និងទូរទស្សន៍ តែមិនចាំបាច់ផ្តល់ឯកសារជាក្រដាសឲ្យទៅសាក្សីទេ ពីព្រោះសាក្សីបានបង្ហាញច្បាស់ហើយ ថាគាត់មិនចេះអានអក្សរទេ ចេះតិចតួច មានកម្រិតទាបណាស់។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** នៅផ្នែកខាងលើនៃទំព័រ ដូចខ្ញុំបានជម្រាបជូនហ្នឹង គឺមន្ត្រីនៃការិយាល័យសហចៅក្រមស៊ើបអង្កេតបានសួរលោកថា “ក្រោយបែកភ្នំពេញ នៅខែមេសា ឆ្នាំ១៩៧៥ តើលោកមានដឹងថា មានការប្រជុំធំដែរឬទេ រវាងមេដឹកនាំខ្មែរក្រហម?” លោកអ៊ំបានមានប្រសាសន៍ថា “ខ្ញុំឃើញមានការប្រជុំច្រើន តែមិនដឹងថាគេប្រជុំអំពីអ្វីខ្លះនោះទេ”។ កន្លែងនេះ ខ្ញុំចង់សុំសួរអ៊ំពាក់ព័ន្ធទៅនឹងបន្ទាប់ពីបែកភ្នំពេញភ្លាមៗឆ្នាំ៧៥ មានដែលអ៊ំមានប្រសាសន៍ថាមានការប្រជុំច្រើននោះ តើអ៊ំចង់និយាយអំពីការប្រជុំ

ហ្នឹងនៅទីកន្លែងណា?

**លោក អឿន តាន៖**

**ឆ៖** បាទ ក្រោយពីបែកភ្នំពេញមក គឺការប្រជុំដូចបានជម្រាបជាបន្តបន្ទាប់ ការប្រជុំញឹកញាប់ ជាពិសេសគឺក្រោយពីបែកភ្នំពេញហើយ ក៏មានការឃើញការប្រជុំ ខ្លួនខ្ញុំផ្ទាល់ក៏ឃើញការប្រជុំ តែគេប្រជុំនិយាយពីរឿងអីៗ ខ្ញុំក្តាប់មិនបានដែលបាទ។

**ស៖** តើការញឹកញាប់ ការប្រជុំញឹកញាប់ ឬក៏ប្រជុំច្រើននោះ ថាតើគេប្រជុំលើ-- រយៈពេលប៉ុន្មានថ្ងៃម្តងទៅពេលដែលថាបន្ទាប់ពីបែកភ្នំពេញ បើអ៊ំមកដល់ភ្នំពេញភ្លាមហ្នឹង?

[១៥:៤៤:៥០]

**ឆ៖** បាទ ការប្រជុំ ហៅថាញឹកញាប់នុ៎ង គឺថាដូចបានបញ្ជាក់ខាងដើមខ្លះមកហើយថា ជួនណាមួយថ្ងៃ ប្រជុំមួយថ្ងៃអ៊ីចឹងទៅ ជួនណាមិនចប់មួយថ្ងៃទៅ ក៏បន្តពីរថ្ងៃទៅបីថ្ងៃទៀតទៅ នេះតាមការជាក់ស្តែងមើលឃើញរបស់ខ្ញុំវាអ៊ីចឹងបាទ។

**ស៖** តើការប្រជុំដែលអ៊ំចង់លើកឡើងនេះ គឺជាប្រជុំក្នុងរយៈពេលដែលអ៊ំទើបតែមកដល់ភ្នំពេញភ្លាម ឬក៏អ៊ំសំដៅទៅលើការប្រជុំដែលមានរយៈពេលបីបួនប្រាំខែក្រោយពីពេលនោះ? ហើយប្រជុំនៅទីណា?

**ឆ៖** ពេលបែកភ្នំពេញហើយក៏ៗ បានបញ្ជាក់ឲ្យដឹងថា ខ្ញុំបានចុះមកភ្នំពេញគឺឃើញការប្រជុំញឹកញាប់ គឺប្រជុំនៅកន្លែង ក-១។ ក-១ ដូចបានបញ្ជាក់ហើយថា ការ-- ជាទីកន្លែងការប្រជុំរបស់តាប៉ុល ពត បាទ។

**ស៖** ខ្ញុំចាប់អារម្មណ៍អំពីរយៈពេលប្រជុំដែលភ្លាមៗបន្ទាប់ពីពេលបែកហ្នឹង ហើយដែលអ៊ំបានដឹងហ្នឹងថា តើអ្នកណាខ្លះដែលមកប្រជុំនៅ ក-១ ជាមួយនឹងលោក ប៉ុល ពត នៅពេលដែលអ៊ំមកដល់ភ្លាមៗនៅ ក-១ ហ្នឹង?

**ឆ៖** បាទ ពេលនោះក៏ខ្ញុំមកដល់ហើយ គឺថាបានឃើញការប្រជុំមាន ប៉ុល ពត, នួន ជា, អៀង សារី ហើយនិង សុន សេន ប៉ុណ្ណឹងនាក់ទេបាទ។

**ស៖** អាចមានអ្នកផ្សេងទៀត ឬក៏អត់ទេ?

**ឆ៖** បាទ អត់មានឃើញទេបាទ។

**ស៖** បាទ សូមអរគុណលោកអ៊ំ។

[១៥:៤៧:១៦]

**លោក ពេជ អង្គ៖**

លោកប្រធានចំពោះឯកសារដដែលដែរ ខ្ញុំសូមអនុញ្ញាតដើម្បីអាននៅក្នុងទំព័រមួយដែលមានលេខ ERN ជាភាសាខ្មែរ 00231807 ជាភាសាខ្មែរ, ជាភាសាអង់គ្លេស 00235132 ដល់ 33, ភាសាបារាំង 00235337 ដល់ 38។ សូមលោកប្រធានអនុញ្ញាតឲ្យខ្ញុំអាន ហើយនិងមន្ត្រីជំនួយការបញ្ចាំងឯកសារនេះក្នុងអេក្រង់។ សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ នៅក្នុងឃ្លាមួយអ៊ំបានមានប្រសាសន៍ថា បន្ទាប់ពីគេសួរថា "ពេលលោកយកលិខិតទៅឲ្យ នួន ជា តើ នួន ជា មានផ្ញើអ្វីទៅឲ្យ ប៉ុល ពត វិញដែរឬទេ?" អ៊ំបានឆ្លើយថា "អត់មានទេ តែមានពេលខ្លះគេយកសំបុត្រពី នួន ជា ទៅឲ្យ ប៉ុល ពត។ ការបញ្ជូនសំបុត្រពី នួនជា ទៅឲ្យ ប៉ុល ពត មានមួយក្នុងរយៈពេលមួយថ្ងៃពីរដង។ ខ្ញុំមិនដែលឃើញសំបុត្រពី ខៀវ សំផន ឬពី អៀង សារី និង អៀង ធីរិទ្ធ ទេ ព្រោះពុំដែល-- ពុំមានជាអ្នកធ្វើការ-- ខ្ញុំពុំមែនជាអ្នកធ្វើការរវាងអ្នកទាំងនោះ និង ប៉ុល ពត ទេ។ ខ្ញុំធ្លាប់ឃើញមានសំបុត្រផ្ញើមកពី សុន សេន។"

បាទ ត្រង់ចំណុចដែលចុងក្រោយ ដែលអ៊ំបានធ្លាប់ឃើញមានសំបុត្រផ្ញើពី សុន សេន តើអ៊ំអាចបញ្ជាក់បានទេថា តើសំបុត្រដែលផ្ញើមកពីខាង សុន សេន ហ្នឹងជាសំបុត្រលក្ខណៈយ៉ាងម៉េច? ជាសំបុត្រតូច ឬក៏ជាសំបុត្រធំ? ក្រាស់ ឬក៏ស្តើង?

[១៥:៤៩:៣០]

**លោក អឿន តាន៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយនឹងសំណួរនេះ សំបុត្រមកពី សុន សេន គឺសំបុត្រតូចមួយគេដាក់ក្នុងស្រោមៗសំបុត្រហ្នឹង ខ្ញុំយកមកៗឲ្យ ប៉ុល ពត។ អាហ្នឹងមិនធំទេ មានតូចមួយគេដាក់ក្នុងស្រោមបាទ។

**ស៖** ចុះពេលដែលឆ្នាំ-- ខ្ទង់ប្រហែលឆ្នាំ១៩៧៧ ចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ តើលោកអ៊ំមានធ្លាប់ទទួលសំបុត្រពីលោក នួន ជា ជូនទៅ ប៉ុល ពត ដែរឬទេ?

**ឆ៖** បាទ ដែលៗ ពី ប៉ុល ពត ជូន នួន ជា ពី នួន ជា កន្លែង នួន ជា គេជូនមក ប៉ុល ពត វិញ

ដែលឃើញបាទ។

**ស៖** តើសំបុត្រនោះជាសំបុត្រតូចទម្រង់តូច ឬក៏ជាសំបុត្រមានធំប៉ុនក្រដាសសៀវភៅ? ឬក៏ជាសំបុត្រក្រាស់?

**ឆ៖** បាទ ឃើញក្នុងស្រោម គឺស្រោមធំ ហើយក្រាស់ គេសរសេរខ្ទង់ថា ជូន ប៉ុល ពត អ៊ីចឹង ហើយក៏បញ្ជូននាំយកឲ្យ ប៉ុល ពត វិញឃើញក្រាស់ ស្រោមសំបុត្រហ្នឹងក្រាស់បាទ។

**ស៖** តើសំបុត្រក្រាស់ហ្នឹងមាន-- លោកអ៊ំបានឃើញញឹកញាប់ដែរឬទេ ឬក៏យូរៗម្តង?

[១៥:៥១:២១]

**ឆ៖** បាទ ពេលនោះ ខ្ញុំឃើញតែយូរៗម្តងៗ ពេលខ្លះអត់ញឹកញាប់ទេ ហើយពេលខ្លះសំបុត្រស្តើង ពេលខ្លះអាសំបុត្រក្រាស់គឺថា យូរបានចេញម្តងបាទ។

**ស៖** តើអ៊ំមានដឹងទេថាសំបុត្រក្រាស់ហ្នឹងគឺមកពីប្រភពខាងណា?

**ឆ៖** បាទ ខ្ញុំមិនដែលដឹងទេ គ្រាន់តែយកសំបុត្រហ្នឹង ដឹងថាយកសំបុត្រហើយ ប៉ុន្តែមកពីប្រភពណាៗ ខ្ញុំអត់ដែលដឹងទេបាទ។

**ស៖** តើលោកអ៊ំមានស្គាល់លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលស្គាល់ទេបាទ។

**ស៖** តើអ៊ំស្គាល់មន្ទីរ ប-១ ដែរឬទេ?

**ឆ៖** បាទ មន្ទីរ ប-១ ធ្លាប់ដឹងបាទ។

**ស៖** តើលោក ប៉ង់ ធ្លាប់មានទំនាក់ទំនងអ្វីខ្លះជាមួយនឹងមន្ទីរ ប-១ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលដឹងទេបាទ។

**ស៖** តើអ៊ំមានស្គាល់អ្នកណាខ្លះនៅមន្ទីរ ប-១?

**ឆ៖** បាទ ខ្ញុំពួកខ្ញុំនៅ ក-១ អាកន្លែង ប-១ ដូច្នេះ អត់ស្គាល់ទេបាទ។

[១៥:៥៣:១៣]

**ស៖** ចុះអ៊ំមានស្គាល់លោក សួរ ហុង ដែរឬទេ?

**ឆ៖** សួរ ហុងៗ ខ្ញុំស្គាល់ តែឮតែឈ្មោះបាទ។ ឮតែឈ្មោះ។

**ស៖** បាទ ចំណុចក្រោយមួយទៀតដែលខ្ញុំសួរអ៊ំ ហើយខ្ញុំគិតថានឹងមិនចំណាយពេលច្រើនទេ បីបួននាទីទៀតទេ។ អ៊ំនៅ ក-១ តើអ៊ំអាចបញ្ជាក់បានទេថា ក-១ ហ្នឹងមានអគារប៉ុន្មាន? ហើយនៅ

ម៉ុណា?

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ជូន ក-១ គឺអគារហ្នឹងមានពីរជួរៗ ជួរខាងជើង ហើយនិងជួរខាងត្បូងជាប់មាត់ទន្លេបាសាក់បាទ។ សូមបញ្ជាក់ជូនប៉ុណ្ណឹងបាទ។

**ស៖** នៅខាងណាអគារបៀលឌីញ? តើអ៊ំស្គាល់ទេ អគារបៀលឌីញ ដែលគេចំណាំហៅថាអគារបៀលឌីញៗ?

[១៥:៥៤:៣៨]

**ឆ៖** បាទ ខ្ញុំអត់ដែលស្គាល់ទេបាទ។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

[១៥:៥៤:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។

បាទ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរពីរខ្លីៗ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកសាក្សី ខ្ញុំសូមត្រឡប់មកនិយាយអំពីការងាររបស់លោកនៅមន្ទីរក-១ ហើយខ្ញុំចង់ឲ្យលោកនិយាយប្រាប់យើងឲ្យច្បាស់លាស់ជាងនេះទៅទៀត អំពីកិច្ចប្រជុំនៅទីនោះ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថានៅពេលដែល ប៉ុល ពត អវត្តមាននៅទីក្រុងភ្នំពេញ តើអ្នកណាជាប្រធាន-- ជាអ្នកដឹកនាំកិច្ចប្រជុំ?

**លោក អឿន តាន៖**

**ឆ៖** បាទ ពេលកិច្ចការងារប្រជុំ ប្រធានគឺ ប៉ុល ពត អ្នកដឹកនាំប្រជុំបាទ។

**ស៖** តើ ប៉ុល ពត ធ្លាប់អវត្តមានដែរឬទេ ព្រោះថាគាត់ធ្លាប់ទៅបរទេស? ហើយនៅក្នុងកាលៈ

ទេសៈនេះ តើលោកដឹងថាអ្នកណាជំនួស ប៉ុល ពត ដែរឬទេ ដើម្បីដឹកនាំកិច្ចប្រជុំនោះ?

**ឆ៖** បាទ ពេលនោះគឺមានតា នួន ជា ដឹកនាំប្រជុំ ពេលមានការងារគឺត្រូវប្រជុំ គឺ នួន ជា ដឹកនាំបាទ។

**ស៖** បាទ ខ្ញុំសូមត្រឡប់មកនិយាយអំពីអ្វី ដែលយើងនិយាយពាក់ព័ន្ធទៅនឹងទូរលេខ។ ជាបឋម ទូរលេខទាំងអស់នោះ ដែលលោកយកទៅឲ្យ ប៉ុល ពត ហើយនិង នួន ជា តើជាទូរលេខដែលលោកទៅយកខ្លួនឯង ឬក៏គេយកមកឲ្យលោក? ហើយបើសិនជាគេយកមកឲ្យលោក អ្នកណាជាអ្នកយកមកឲ្យលោក?

[១៥:៥៧:៣២]

**ឆ៖** បាទ ខ្ញុំសូមបញ្ជាក់ជូនថា ពេលសារទូរលេខ ដូចបញ្ជាក់ខាងដើមថាកន្លែង ផង់ ហើយនិង យស ហើយ យស និង ផង់ ហ្នឹងគឺចាត់ចែងឲ្យកូនចៅគាត់ កុមារៗតូចហ្នឹងជូនមកដល់កន្លែងខ្ញុំ។ ដល់កន្លែងខ្ញុំហើយ ខ្ញុំជូនឲ្យ ប៉ុល ពត វិញ បាទ។

**ស៖** បើសិនជាមិនច្រឡំទេ ពេល-- ក្នុងចម្លើយលោកលើកមុននេះ យើងអាចនិយាយថា ជាគោលការណ៍ទូរលេខទាំងអស់ដែលយកទៅឲ្យ ប៉ុល ពត ត្រូវផ្តល់ជូនទៅលោក នួន ជា ផងដែរ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ មែនបាទ។

**ស៖** តើទូរលេខមួយចំនួនធ្លាប់មិនផ្ញើជូនទៅអ្នក ដែលត្រូវទទួលទូរលេខនោះដែរឬទេ? តើករណីហ្នឹងធ្លាប់មានកើតឡើងដែរឬទេ?

**ឆ៖** បាទ អត់ដែលមានទេបាទ។

[១៥:៥៩:០៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ លោកសាក្សី ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក អឿន តាន យើងមានពីរបីសំណួរ ចង់សួរលោក។

**សួរបន្តដោយប្រធានអង្គជំនុំ៖**

**ស៖** លោកបានឆ្លើយបញ្ជាក់កាលពីព្រឹកមិញហើយថា ឈ្មោះ ប៉ង់ ជាប្រធានមន្ទីរ៨៧០។

តើប្រធាន-- មន្ទីរ៨៧០ ហ្នឹង និងមន្ទីរក-១ ហ្នឹងខុសគ្នាយ៉ាងដូចម្ដេច?

**លោក អឿន តាន៖**

**ឆ៖** បាទ មន្ទីរ៨៧០ វាខុសគ្នា ក-១ ផ្សេង ហើយ៨៧០ ផ្សេង។ ប៉ុន្តែក្រោមការដឹកនាំទទួលខុសត្រូវរួម គឺ ប៉ង់ បាទ។

[១៦:០០:០០]

**ស៖** មន្ទីរ៨៧០ហ្នឹង មានទីតាំងស្ថិតនៅកន្លែងណាទៅ?

**ឆ៖** បាទ មិនដឹងនៅកន្លែងណាទេ ខ្ញុំភ្លេចបាត់ហើយបាទ។ អត់ចាំ។

**ស៖** លោកចាំទេថា អង្គភាពណាខ្លះដែលស្ថិតនៅក្រោមឱវាទនៅចំណុះឲ្យមន្ទីរ៨៧០?

**ឆ៖** បាទ ពេលនោះគឺមានន៎ែ តាមផ្នែក ក-៧, ក-៣, ក-១ ហើយន៎ែ មានប៉ុណ្ណឹង ខ្ញុំមិនចាំអស់ទេបាទ។ ភ្លេចបាត់ការចងចាំ។

**ស៖** តាមដែលលោកដឹងហ្នឹង គឺលោកបានឆ្លើយព្រឹកមិញហើយថា ឈ្មោះ ប៉ង់ ជាប្រធានមន្ទីរ៨៧០ អ៊ីចឹងពិតមែនដែរទេ?

**ឆ៖** បាទ ពិតមែនហើយបាទ។

[១៦:០១:១៣]

**ស៖** លោកបានឆ្លើយព្រឹកមិញថា ឈ្មោះ ប៉ង់ ហ្នឹងក្រោយមកបាត់ខ្លួន ហើយការបាត់ខ្លួន ប៉ង់ ហ្នឹង នាំឲ្យលោកមានការភ័យខ្លាចផងដែរ។ តើអ៊ីចឹងពិតមែនដែរទេ?

**ឆ៖** បាទ រូបខ្ញុំក៏ក្រោយពីឃើញបាត់ ប៉ង់ ក៏ខ្លួនចេះតែឆ្ងល់ ដូចបានបញ្ជាក់ជូន ចេះតែឆ្ងល់បាត់ម្ង៉ៃពីរថ្ងៃបាត់ បួនថ្ងៃបាត់អត់ឃើញមក ធ្លាប់តែដល់ គឺប្រុច ទៅមកៗចូលមក។ ដល់អ៊ីចឹងខ្លួនផ្ទាល់ក៏ចេះតែសង្ស័យ អ្ហែ មិនដឹងបាត់ទៅណាទេ ប៉ង់ ធ្លាប់រាល់ថ្ងៃចេញចូលៗ ឥឡូវបាត់ទៀត មិនដឹងទៅណាទេ។ នេះការវិភាគរបស់ខ្ញុំ ប៉ុន្តែការភ័យការខ្លាច ភ័យខ្លះ អត់ខ្លះអ៊ីចឹងទៅ គឺប្រឹងធ្វើការតែប៉ុណ្ណឹងទេ។ នេះ ខ្ញុំសូមអស់មតិប៉ុណ្ណឹង។

**ស៖** បាទ អរគុណ។ ហើយចាប់ពីពេលដែល ប៉ង់ បាត់ខ្លួនហ្នឹង លោកចាំទេ កាលបរិច្ឆេទពេលវេលានៅក្នុងឆ្នាំណាដែរ ប្រហែលនៅក្នុងឆ្នាំណាដែរ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេបាទ។

**ស៖** ក្រោយពេល ប៉ង់ បាត់ខ្លួនទៅ តើអ្នកណាឡើងតំណែងធ្វើជាប្រធានមន្ទីរ៨៧០ ជំនួស ប៉ង់?

[១៦:០២:៤៥]

**ឆ៖** បាទ ក្រោយពីបាត់ខ្លួន ប៉ង់ មកគឺថាមានន៉ៃ កែន ហៅ លីន បច្ចុប្បន្នគាត់ស្លាប់បាត់ហើយ បាទ។

**ស៖** បាទ អរគុណ។ ហើយនៅក្នុងមន្ទីរ៨៧០ហ្នឹង តើមានការប្រជុំជីវភាព ទិតៀន ស្វ័យ ទិតៀន ធ្វើទៀងទាត់ដែរឬទេនៅក្នុងអង្គភាពរបស់លោក?

**ឆ៖** បាទ តាមការណែនាំរបស់ ប៉ង់ គឺការដឹកនាំប្រជុំ ក្រុមខ្ញុំក៏ គឺប្រជុំទៀងទាត់ ឧទាហរណ៍ ថាប្រជុំគឺថា ប្រជុំកសាង ណែនាំ អីល្អអីអាក្រក់ អីចំណេញអីខាត អានេះគឺថា ការប្រជុំណែនាំគឺមាន អីចឹង កុំឲ្យប៉ះពាល់ទ្រព្យសម្បត្តិរបស់ប្រជាជន កុំឲ្យប៉ះពាល់សីលធម៌ នេះគឺអប់រំណែនាំគ្នាអីចឹង ធ្វើម៉េចតាមផ្លូវល្អ តាមផ្លូវត្រឹមត្រូវបាទ។

**ស៖** ក្នុងអំឡុងពេលដែលលោកទៅធ្វើការនៅមន្ទីរ៨៧០ គឺនៅក្នុងអង្គភាព ក-១ តើលោកធ្លាប់ បានចូលរួមប្រជុំ ក្រោមការដឹកនាំកិច្ចប្រជុំដោយ លោក ខៀវ សំផន ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលទេបាទ។

**ស៖** សំណួរចុងក្រោយរបស់យើង សួរថា លោកបាននិយាយហើយថាមន្ទីរ៨៧០ហ្នឹងគឺ ប្រធានហ្នឹងគឺឈ្មោះ ប៉ង់ ហើយក្រោយមកផ្លាស់ប្ដូរក្រោយពីបាត់ខ្លួនឈ្មោះ ប៉ង់ គឺឈ្មោះ លីន ជំនួស។ សួរថា តើនៅពីលើ ប៉ង់ មានអ្នកណាទៀតដែលគ្រប់គ្រងនៅមន្ទីរ៨៧០?

**ឆ៖** បាទ ពេលនោះគឺថា មានន៉ៃ កែន ហៅ លីន ជំនួស ប៉ង់ បាទ។

**ស៖** សំណួរយើងអត់ចង់សួរអីចឹងទេ សួរថា កាលពី ប៉ង់ នៅរស់ គាត់ជាប្រធានមន្ទីរ៨៧០។ សួរថាតើមន្ទីរ៨៧០ហ្នឹងមានអ្នកណាផ្សេងទៀត គ្រប់គ្រងពីលើ ប៉ង់ ដែរឬទេ?

[១៦:០៥:០០]

**ឆ៖** បាទ គឺអត់មានទេបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ អរគុណសាក្សី ហើយឥឡូវនេះ កិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះ ដល់ ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី១៤ ខែមិថុនា ឆ្នាំ២០១២ ដោយចាប់ផ្ដើមពីម៉ោង ប្រាំបួនព្រឹក។

សវនាការនៅស្អែកនេះ នឹងបន្តធ្វើដោយការតាំងសំណួរដេញដោលចំពោះសាក្សី អឿន តាន ដោយក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដែលមានឱកាសតាំងសំណួរចំពោះសាក្សីរូបនេះ មុនក្រុមមេធាវីការពារក្តីដទៃទៀត សូមភាគី និងសាធារណជនជ្រាប។

[១៦:០៥:៤៧]

លោក អឿន តាន ការស្តាប់សក្ខីកម្មរបស់លោកមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះត្រូវបន្តធ្វើសវនាការស្តាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះ អង្គជំនុំជម្រះសូមកោះអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ ដូចគ្នានេះដែរ សូមអញ្ជើញមេធាវីប្រឹក្សាសាក្សីមកចូលរួមដើម្បីបន្តប្រឹក្សាសាក្សីក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការនៅថ្ងៃស្អែក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការបញ្ជូនវិលត្រឡប់ទៅកាន់កន្លែងស្នាក់នៅ និងឲ្យនាំគាត់មកត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។ ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

ដោយឡែកលោក អៀង សារី ប្រសិនបើគាត់បង្ហាញជំហរច្បាស់លាស់ ក្នុងការលះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយសុំនៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ តាមរយៈពាក្យសុំលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងដំណើរការសវនាការជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះបានមុនពេលអង្គជំនុំជម្រះចាប់ផ្តើមដំណើរការសវនាការនៅម៉ោងប្រាំបួនព្រឹកនោះ។ អង្គជំនុំជម្រះឲ្យអនុរក្សមន្ទីរឃុំឃាំងទំនាក់ទំនងទទួលព័ត៌មានពីក្រឡាបញ្ជីសវនាការ និងបង្គាប់ឲ្យនាំខ្លួនគាត់មកត្រឹមតែបន្ទប់ឃុំខ្លួនមួយ ដែលរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ហើយអង្គជំនុំជម្រះនឹងពិនិត្យសម្រេចលើសំណើសុំរបស់គាត់ជាមុន មុនពេលពិភាក្សាដេញដោល។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង១៦:០៧នាទី)*